២០១៤ - ២០១៦

២០១៥





# ជឿងសម្តែងមេត្តាករុណា

# CHARITY IN ACTION

និពន្ធដោយលោកអភិបាលអូលីវីយេ ឝ្មីតអឺស្ព្លែរ

# មាតិកា


១. ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់...........................................៤-៩
២. ការនាំជនក្រីក្រឲ្យចូលរួមក្នុងសង្គម..................................... ១០-១៧
៣. ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា...........................................១៨-២៦
៤. មេត្តាករុណា.................................................................២៧-៣៤
៥. គុណធម៌ទាំងបួន...........................................................៣៥-៤០
៦. មេត្តាករុណាក្នុងជីវិតរបស់ខ្ញុំ................................................៤១-៤៦
៧. គម្រោងសកម្មភាព.........................................................៤៧-៥៤
៨. សំណួរដើម្បីរិះគិតបន្ថែម...................................................៥៥-៥៨

# I. " ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ "

ពាក្យថា " ធម៌មេត្តាករុណា " ថាតើមានអត្ថន័យយ៉ាងដូចម្ដេចតាមជំនឿរបស់យើង ដែលស្របតាមព្រះគម្ពីរ។ ក្រោយមក យើងនឹងស្ដាប់សារលិខិតរបស់សម្ដេចប៉ាប ថាតើយើងជាគ្រីស្តបរិស័ទត្រូវធ្វើដូចម្ដេច ដើម្បីនាំយកអ្នកក្រីក្រឲ្យចូលនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ន។ យើងនឹងអធិដ្ឋានរួមគ្នា ដើម្បីប្រមូលអ្វីៗទាំងអស់ ដែលយើងបានរៀន ដែលយើងបានឃើញថ្វាយទៅព្រះជាម្ចាស់ ដែលជាប្រភពនៃធម៌មេត្តាករុណា។

ដើម្បីសម្ដែងមេត្តាករុណានោះ យើងត្រូវការគិតអំពីអត្ថន័យនៃធម៌មេត្តាករុណា គិតអំពីអត្ថន័យនៃសេចក្ដីស្រឡាញ់។ជាទូទៅ ពេលយើងនិយាយអំពីសេចក្ដីស្រឡាញ់ នោះយើងនឹកឃើញភ្លាមអំពីសេចក្ដីស្រឡាញ់ដែលយើងមាននៅក្នុងក្រុមគ្រួសារ សេចក្ដីស្រឡាញ់របស់យើងដល់អ្នកជិត ខាងដល់មិត្តសម្លាញ់...ដែលសេចក្ដីស្រឡាញ់ទាំងនោះណែនាំដោយអារម្មណ៍។

ថ្ងៃនេះ ខ្ញុំសូមចូលនៅក្នុងសេចក្ដីស្រឡាញ់ ដែលព្រះជាម្ចាស់ប្រទានឲ្យយើងជាគ្រីស្តបរិស័ទចូលនៅក្នុងកម្រិតមួយទៀត ដែលមិនទាក់ទងនឹងអារម្មណ៍ ឬនិស្ស័យរបស់យើងទេ ប៉ុន្តែជាសេចក្ដីស្រឡាញ់ដែលលើសពីអ្វីៗទាំងអស់។

**យ៉ូហានទី១(៤,១៦)**

> ១៦ រីឯយើងវិញ យើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមយើង ហើយយើងក៏បានជឿ។ ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ អ្នកណាស្ថិតនៅជាប់នឹងសេចក្ដីស្រឡាញ់ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ។

មូលដ្ឋានដ៏កំពូលនៃសេចក្ដីស្រឡាញ់នេះ មានចែងនៅក្នុងគម្ពីរដំណឹងល្អ "' ១៦ រីឯយើងវិញ យើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងចំណោមយើង ហើយយើងក៏បានជឿ។ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់អ្នកណាស្ថិតនៅជាប់នឹងសេចក្ដីស្រឡាញ់អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ"។(១យហ៤,១៦)

ដូច្នេះព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿរបស់យើងដែលធ្វើឲ្យយើងលែងគិតអំពីសេចក្ដីស្រឡាញ់ ដែលទាក់ទងនឹងអារម្មណ៍របស់ខ្លួន តែជាសេចក្ដី

ស្រឡាញ់ដែលណែនាំឲ្យយើងសម្លឹងមើលព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់វិញ។"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ យើងបានស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ហើយយើងក៏បានជឿតាម"នេះមានន័យថាយើងចូលនៅក្នុងជំនឿជាគ្រីស្តបរិស័ទលែងជាសេចក្តីស្រឡាញ់ទូទៅតាមរបៀបរបស់យើងទៀតហើយ។

## ទុតិយកថា(៦,៤-៥)

៤ អ៊ីស្រាអែលអើយចូរស្តាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើង មួយព្រះអង្គគត់ដែលពិតជាព្រះអម្ចាស់។ ៥ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក អោយអស់ពីចិត្តគំនិត អស់ពីស្មារតីនិងអស់ពីកម្លាំងកាយ។

ប្រសិនយើងមើលក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ នោះយើងឃើញមានធម៌វិន័យដ៏សំខាន់គឺៈ

ទី១ " ៤ អ៊ីស្រាអែលអើយចូរស្តាប់! មានតែព្រះអម្ចាស់ជាព្រះរបស់ យើងតែមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីកម្លាំងកាយ "។

ទី២ " អ្នកត្រូវស្រឡាញ់អ្នកដទៃឲ្យដូចស្រឡាញ់ខ្លួនឯង "។ ធម្មវិន័យទី ១ គឺមានព្រះជាម្ចាស់ជាមូលដ្ឋាន និងធម្មវិន័យទី២ ឲ្យយើងស្រឡាញ់បងប្អូនឯទៀតៗ ដូចស្រឡាញ់ខ្លួនឯងជាមូលដ្ឋាន។

## យ៉ូហានទី១(៤,១៩)

១៩ រីឯយើងវិញ យើងមានចិត្តស្រឡាញ់ ព្រោះព្រះអង្គបានស្រឡាញ់យើងជាមុន។

ទី៣ " ១៩ រីឯយើងវិញ យើងមានចិត្តស្រឡាញ់ ព្រោះព្រះអង្គបានស្រឡាញ់យើងជាមុន"។ ដោយសារព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ បានជាព្រះអង្គបង្កើតយើងជាបុរស ជាស្ត្រីឲ្យមានលក្ខណៈដូចព្រះអង្គ ដែលនេះជាសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ ព្រះអង្គចំពោះយើង ជាព្រះអំណោយទានដែលយើងបានទទួលពីព្រះអង្គ ហេតុនេះហើយបានជាយើងត្រូវតែមានចិត្តស្រឡាញ់ដូចព្រះអង្គ។

## យ៉ូហាន ៣, ១៦

១៦ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ចគឺមិនឲ្យគេវិនាសឡើយ។

ចូរឲ្យយើងគិតអំពីអត្ថន័យ នៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង។ មានអត្ថបទមួយជួយឲ្យយើងកាន់តែយល់ពីសេចក្ដីនេះគឺ "១៦ព្រះជាម្ចាស់ស្រឡាញ់ មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទាន ព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ។ ដោយសារតែសេចក្ដីស្រឡាញ់ ព្រះជាម្ចាស់បានប្រទានព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ ព្រះអង្គគឺព្រះយេស៊ូ ដើម្បីឲ្យយើងមានជីវិតដ៏បរិបូរណ៍"។

ទី៤ ពេលនេះជាឱកាសមួយឲ្យយើងគិតអំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលយើងបានទទួលពីព្រះជាម្ចាស់។ តើយើងទទួលស្គាល់ថាយើងបានទទួលជីវិតពីព្រះជាម្ចាស់ឬទេ? តើយើងបានទទួលជីវិតថ្មីពីព្រះយេស៊ូឬទេ? ទទួលតាមរបៀបណា? នៅពេលណា?។ ក្នុងចំណោមបងប្អូន មានមួយចំនួនធំដែលទើបបានទទួលពិធីជ្រមុជទឹកក្នុងពេលថ្មីៗកន្លងទៅនេះ សូមបងប្អូនគិតថា តើជីវិតរបស់បងប្អូនមានការផ្លាស់ប្រែអ្វីខ្លះ? តើព្រះយេស៊ូជាព្រះសង្គ្រោះមានអត្ថន័យយ៉ាងដូចម្ដេច?។ តើបងប្អូនមានបទពិសោធន៍អ្វី អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះការរស់នៅរបស់បងប្អូន? ឧទាហរណ៍ មានមីងម្នាក់ពិការភ្នែក គាត់ស្គាល់គ្រីស្តបរិស័ទម្នាក់ ហើយគ្រីស្តបរិស័ទនោះបានជួយនាំគាត់មកព្យាបាលភ្នែកនៅភ្នំពេញឲ្យគាត់អាចមើលឃើញវិញ។ តាំងពីពេលនោះមកគាត់ប្រកាសថា គាត់បានទទួលជីវិតថ្មីតាមរយៈគ្រីស្តបរិស័ទម្នាក់នោះ ហើយគាត់បញ្ជាក់ថា ព្រះជាម្ចាស់ស្រឡាញ់គាត់ និងសង្គ្រោះគាត់។ តាមឧទាហរណ៍នេះបញ្ជាក់ថា គាត់មានបទពិសោធដោយផ្ទាល់អំពីព្រះជាម្ចាស់ស្រឡាញ់គាត់។ ដូច្នេះ ប្រសិនបើយើងមិនដែលមានបទពិសោធថា ព្រះជាម្ចាស់ស្រឡាញ់ខ្លួនទេ នោះយើងមុខជានិយាយអំពីព្រះជាម្ចាស់តាមចំណេះដឹង និងតាមបបូរមាត់ប៉ុណ្ណោះ។

## យ៉ូហាន(១៣,១)

១ យេស៊ូជ្រាបថាដល់ពេលកំណត់ ដែលព្រះអង្គត្រូវឆ្លងពីលោកនេះឆ្ពោះ ទៅព្រះបិតាហើយ។ ដោយព្រះអង្គស្រឡាញ់សាវ័ករបស់ព្រះអង្គដែលរស់នៅក្នុងលោក នេះទ្រង់ក៏ស្រឡាញ់គេរហូតដល់ទីបំផុត។

ទី ៥ " ¹ព្រះយេស៊ូឈ្វេងយល់ថា ដល់ពេលកំណត់ ដែលព្រះអង្គត្រូវឆ្លងពីលោកនេះទៅព្រះបិតាវិញហើយ។ ដោយព្រះអង្គស្រឡាញ់សាវ័ករបស់ព្រះអង្គ ដែលរស់នៅក្នុងលោកនេះ ទ្រង់ក៏ស្រឡាញ់គេរហូតដល់ទីបំផុត "។

សូមបងប្អូនមើល អំពីរបៀបដែលព្រះយេស៊ូស្រឡាញ់គេដល់ទីបំផុត ហើយក៏ជារបៀបព្រះអង្គស្រឡាញ់យើងដល់ទីបំផុតដែរ។ សេចក្តីនេះ ណែនាំឲ្យយើងយល់ឃើញថា ព្រះយេស៊ូស្រឡាញ់យើងមិនទាក់ទងនឹងនិស្ស័យឬអារម្មណ៍ទេ គឺព្រះអង្គបានបង្រៀនរបៀបស្រឡាញ់ថ្មីដល់យើង។ មុនសោយទិវង្គត់ ព្រះយេស៊ូបានជួបជុំជាមួយក្រុមសាវ័កក្នុងពិធីជប់លៀងមួយ ពេលនោះព្រះអង្គបានលាងជើងឲ្យក្រុមសាវ័កដើម្បីបង្ហាញថា ព្រះអង្គជាអ្នកបម្រើដោយសុខចិត្តលះបង់ព្រះជន្ម។ ព្រះយេស៊ូបង្ហាញសញ្ញាថាស្រឡាញ់គេដល់ "ទីបំផុត " គឺ៖

ទី១ ព្រះអង្គលាងជើងឲ្យសាវ័កដែលមានន័យថា ខ្លួនព្រះអង្គមិនសំខាន់ទេ សេចក្តីដ៏សំខាន់គឺព្រះអង្គបម្រើអ្នកដទៃ។

ទី២ ព្រះយេស៊ូលើកនំបុ័ង និងពែងស្រាឡើងព្រមទាំងមានព្រះបន្ទូលថា៖ "នេះជារូបកាយ និងជាលោហិតរបស់ខ្ញុំដែលខ្ញុំបូជាសម្រាប់អ្នករាល់គ្នា"ដែលមានន័យថាព្រះអង្គមិនគិតអំពីខ្លួនឯង តែព្រះអង្គគិតដល់ក្រុមសាវ័ក ចង់ឲ្យគេមានកម្លាំងបន្តផ្តល់សក្ខីភាពអំពីជីវិតដែលគេបានទទួលពីព្រះអង្គ។ សេចក្តីនេះ ចូលនៅក្នុងសេចក្តីស្រឡាញ់ដ៏កំពូល ដែលមិនទាក់ទងនឹងនិស្ស័យ និងអារម្មណ៍ តែជាសេចក្តីស្រឡាញ់ដោយសុខចិត្តបម្រើ ដោយលះបង់ខ្លួនផ្ទាល់សម្រាប់អ្នកដទៃ។

ទី៣ ជាកំពូលនៃសេចក្តីស្រឡាញ់ គឺព្រះយេស៊ូសោយទិវង្គត់នៅលើឈើឆ្កាង។ ពេលព្រះយេស៊ូមានព្រះបន្ទូលថា៖ " នេះជារូបកាយ នេះជាលោហិត..." នេះគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ប៉ុន្តែពេលព្រះអង្គសោយទិវង្គត នោះលែងជានិមិត្តរូបទៀតហើយ។

មុនសោយទិវង្គត ព្រះយេស៊ូមានព្រះបន្ទូលតែមួយគត់ថា៖ " ខ្ញុំលើកលែងទោសឲ្យគេ..."។ ព្រះយេស៊ូមិនអន់ចិត្ត មិនស្អប់អ្នកធ្វើគត់ព្រះអង្គទេ ព្រះអង្គលើកលែងទោសឲ្យគេ។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ជាសេចក្តីស្រឡាញ់មួយយ៉ាងពិសេស ដែលយើងអាចមើលឃើញជាក់ស្តែងបាន គឺនៅពេលព្រះយេស៊ូដាក់ព្រះកាយជាអ្នកបម្រើ ដោយព្រះអង្គលាងជើង និងដោយបូជាព្រះជន្មនៅលើឈើឆ្កាងដើម្បីប្រទានជីវិតឲ្យយើង។ សេចក្តីស្រឡាញ់ដូចនេះ គឺជាសេចក្តីស្រឡាញ់តាមរបៀបព្រះជាម្ចាស់ ដែលណែនាំឲ្យយើងទៅជាអ្នកបម្រើ ដែលលះបង់ចោលខ្លួនឯង ដើម្បីឲ្យអ្នកដទៃមានសុមង្គល។

## យ៉ូហាន ១៣.៣៤

៣៤ខ្ញុំឲ្យវិន័យថ្មីដល់អ្នករាល់គ្នាគឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។

សេចក្តីស្រឡាញ់នេះស្របតាមធម្មវិន័យនៃសម្ព័ន្ធមេត្រីចាស់ដែលឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកដទៃដូចស្រឡាញ់ខ្លួនឯង។ "ប៉ុន្តែតាមសម្ព័ន្ធមេត្រីថ្មី សូមឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា"។

យើងមិនស្រឡាញ់គ្នាដូចយើងស្រឡាញ់ខ្លួនឯងទេ តែយើងស្រឡាញ់គ្នាតាមរបៀបព្រះយេស៊ូ ដែលស្ម័គ្រចិត្តបូជាព្រះជន្មសម្រាប់យើង។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ព្រះអង្គស្រឡាញ់ខ្ញុំ និងណែនាំឲ្យខ្ញុំស្រឡាញ់អ្នកឯទៀតៗដោយលះបង់ ដោយបម្រើដើម្បីឲ្យគេមានសុភមង្គល។ យើងត្រូវតែអនុវត្តសេចក្តីនេះ នៅក្នុងជីវិតរបស់យើង។

## កូរិនថូសទី១(១៣,៤-៨)

៤ អ្នកមានចិត្តស្រឡាញ់តែង តែអត់ធ្មត់ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតបំប៉ោងឡើយ។ ៥ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ ៦ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ ៧ អ្នកមានចិត្តស្រឡាញ់ អត់ឱនឲ្យក្នុងគ្រប់កាលៈទេសៈ ជឿក្នុងគ្រប់កាលៈទេសៈ សង្ឃឹមក្នុងគ្រប់កាលៈទេសៈ ហើយទ្រាំទ្រក្នុងគ្រប់កាលៈទេសៈ។ ៨ សេចក្តីស្រឡាញ់មិនបរាជ័យឡើយ តែការថ្លែង *ព្រះបន្ទូលមុខជាត្រូវអស់ខ្លឹមសារ ការនិយាយភាសាចម្លែកអស្ចារ្យ *នឹងត្រូវចប់ រីឯចំណេះក៏នឹងអស់ខ្លឹមសារទៅដែរ។

សន្តៈប៉ូល បានបំភ្លឺយើងអំពីសេចក្តីស្រឡាញ់ថា៖ " អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់ មិនវាយឫកខ្ពស់ មិនអួតបំប៉ោងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនឲ្យក្នុងគ្រប់កាលៈទេសៈ ជឿក្នុងគ្រប់កាលៈទេសៈ សង្ឃឹមក្នុងគ្រប់កាលៈទេសៈ ហើយទ្រាំទ្រក្នុងគ្រប់កាលៈទេសៈ។ សេចក្តីស្រឡាញ់មិនបរាជ័យឡើយ។ ការថ្លែងព្រះបន្ទូលមុខជាត្រូវអស់ខ្លឹមសារ ការនិយាយភាសាចម្លែកអស្ចារ្យ នឹងត្រូវចប់ រីឯចំណេះក៏នឹងអស់ខ្លឹមសារទៅដែរ"។ ទាំងនេះ ជាសេចក្តីស្រឡាញ់ ដែលទាក់ទងនឹងអារម្មណ៍ធម្មជាតិរបស់យើង។

សន្តៈប៉ូល ក៏បានបំភ្លឺយើងអំពីសេចក្តីស្រឡាញ់តាមរបៀបរបស់ព្រះយេស៊ូ ដែលព្រះអង្គបានប្រទានមកយើងតាមសញ្ញាសម្គាល់ផ្សេងៗដូចជា៖ លាងជើង កាច់នំប៉័ង និងលើកស្រាឡើង នៅទីបំផុតជាក់ស្តែង គឺព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង ដែលយើងជាគ្រីស្តបរិស័ទត្រូវតែចូលបន្តិចម្តងៗនៅក្នុងសេចក្តីស្រឡាញ់តាមរបៀបថ្មីនោះរបស់ព្រះអង្គ។ ទោះបីគ្រប់គ្នាដឹងច្បាស់ថា មិនអាចប្រព្រឹត្តតាមសេចក្តីស្រឡាញ់របស់ព្រះយេស៊ូបានដោយស្រួលក៏ដោយ ក៏យើងត្រូវតែប្រព្រឹត្តតាមពេញអស់មួយជីវិតរបស់យើង គឺមិនមែនតែ៣ឆ្នាំនៃឆ្នាំមេត្តាករុណាប៉ុណ្ណោះទេ។

យើងជាគ្រីស្តបរិស័ទ ត្រូវសួរខ្លួនឯងថា៖ តើខ្ញុំមានសេចក្តីស្រឡាញ់ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរឬទេ? បន្ទាប់មកយើងត្រូវកែចិត្តគំនិតរបស់យើង។ សន្តីតេរេសា នៃព្រះកុមារយេស៊ូ គាត់ស្រឡាញ់ព្រះយេស៊ូខ្លាំងណាស់ គាត់ដឹងថាព្រះយេស៊ូក៏ស្រឡាញ់គាត់យ៉ាងខ្លាំងដែរ។ គាត់ចង់ក្លាយជាដូនជីតាំងពីនៅតូច ហើយនៅថ្ងៃទទួលព្រះកាយលើកទីមួយ គាត់មានអារម្មណ៍ថាដូចជាព្រះយេស៊ូថើបគាត់ ចាប់ដៃគាត់ដើម្បីឲ្យគាត់អាចទៅមុខបានរហូតដល់ថ្ងៃដែលគាត់ស្លាប់ ដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់គាត់។ រយៈពេល ២០ឆ្នាំដែលសន្តីតេរេសារស់នៅ និងតាមអត្ថបទរបស់សន្តៈប៉ូល ដែលចែងអំពីសេចក្តីស្រឡាញ់នោះណែនាំឲ្យគាត់ភ្ញាក់ស្មារតីគិតថា ពិតមែននៅក្នុងព្រះសហគមន៍ដែលជាមាតា នោះគាត់ត្រូវតែធ្វើជាសេចក្តីស្រឡាញ់សម្រាប់អ្នកដទៃតាមសេចក្តីស្រឡាញ់ ដែលព្រះយេស៊ូបានបង្រៀនយើង គឺជាសេចក្តីស្រឡាញ់ ដែលលះបង់ចោលប្រយោជន៍របស់ខ្លួន ដើម្បីឲ្យអ្នកដទៃមានសុភមង្គល។ ដូច្នេះយើងជាគ្រីស្តបរិស័ទ មិនស្រឡាញ់ដោយសារតែធម្មវិន័យ ប៉ុន្តែយើងស្រឡាញ់ព្រោះជាលក្ខណៈនៃជីវិតរបស់យើង គឺយើងដូចព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។

យើងដែលជាគណៈកម្មការសង្គហៈ យើងជាក្រុមយុវជន យើងជាអ្នកធ្វើការតាមអង្គការមនុស្សធម៌ យើងជាសាសនទូត យើងត្រូវតែបង្ហាញចេញនូវសេចក្តីស្រឡាញ់ ដែលយើងបានទទួលពីព្រះជាម្ចាស់ ដែលព្រះអង្គណែនាំឲ្យយើងចេះស្រឡាញ់ តាមរបៀបព្រះអង្គ។ នេះជារបៀបថ្មី ដែលត្រូវឲ្យចូលនៅក្នុងជីវិតរបស់យើង តាមរបៀបដែលយើងមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ និងតាមរបៀបដែលយើងអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងផង។ សេចក្តីស្រឡាញ់ជាព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ខ្ញុំទទួលសេចក្តីស្រឡាញ់ថ្មីនេះនៅក្នុងជីវិតរបស់ខ្ញុំ គឺខ្ញុំសុខចិត្តបម្រើ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីណែនាំឲ្យអ្នកដទៃមានសេចក្តីសង្ឃឹម ដូចព្រះជាម្ចាស់បានយាងមកបង្ហាញឲ្យយើងឃើញជាក់ស្តែងតាមរយៈព្រះយេស៊ូ ដែលព្រះអង្គជាអ្នកបម្រើ និងដែលសោយទិវង្គត។

ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ព្រះអង្គក៏ណែនាំឲ្យស្រឡាញ់អ្នកដទៃដូចព្រះអង្គស្រឡាញ់ខ្ញុំ។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ដូច្នេះខ្ញុំក៏ជាសេចក្តីស្រឡាញ់ដែរ។ អាម៉ែន។

# II. " ការនាំជនក្រីក្រឲ្យចូលរួមក្នុងសង្គម "

## អំណរសប្បាយដែលហូរមកពីដំណឹងល្អ( ពាក្យដាស់តឿនរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ )

យើងផ្ញើជីវិតលើព្រះគ្រីស្ដដែលដាក់ខ្លួនជាអ្នកក្រីក្រ ព្រះអង្គគង់នៅតែក្បែរអ្នកក្រីក្រ និងនៅក្បែរអស់អ្នកដែលត្រូវគេដាក់ដោយឡែកពីសង្គមជានិច្ច។ ដោយយើងមានជំនឿបែបនេះ យើងនៅតែបារម្ភចំពោះការអភិវឌ្ឍទាំង ស្រុងរបស់អស់អ្នកដែលសង្គមមិនរវីរវល់។ ( E.G. 186 )

ខ្ញុំសូមណែនាំឲ្យយើងរិះគិតជាមួយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ តាមរយៈសារលិខិតដែលមានចំណងជើងថា " អំណរសប្បាយនៃដំណឹងល្អ "។ ក្នុងសារលិលិខិតនេះ មានមួយជំពូកដែលនិយាយអំពី " ការនាំជនក្រីក្រឲ្យចូលរួមនៅក្នុងសង្គម " ដែលមានចែងថា៖ " យើងផ្ញើជីវិតលើព្រះគ្រីស្ដដែលដាក់ខ្លួនជាអ្នកក្រីក្រ ព្រះអង្គគង់នៅតែក្បែរអ្នកក្រីក្រ និងនៅក្បែរអស់អ្នកដែលត្រូវគេដាក់ដោយឡែកពីសង្គមជានិច្ច។ ដោយយើងមានជំនឿបែបនេះ យើងនៅតែបារម្ភ ចំពោះការអភិវឌ្ឍទាំងស្រុងរបស់អស់អ្នកដែលសង្គមមិនរវីរវល់"។
ពេលយើងស្ដាប់ឮសេចក្ដីទាំងនេះ អ្វីដែលយើងនឹកទៅដល់គឺ៖

ទីមួយ គឺយើងគិតទៅដល់ព្រះយេស៊ូដែលបានចាប់កំណើតជាមនុស្ស និងព្រះយេស៊ូបានជ្រើសរើស និងរស់នៅជាមួយអ្នកក្រីក្រ និងអ្នកតូចតាច។ ព្រះយេស៊ូយាងពីភូមិមួយទៅភូមិមួយទៀត ដើម្បីនាំដំណឹងល្អទៅដល់ជនក្រីក្រ។ ព្រះយេស៊ូជាមូលហេតុទីមួយ ដែលណែនាំឲ្យយើងមានស្នាដៃ។ ព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ព្រះយេស៊ូបានរស់នៅក្នុងជីវិតជាអ្នកក្រីក្រ ទោះបីព្រះយេស៊ូជាព្រះជាម្ចាស់ក៏ដោយ។ ពេលប្រសូត ព្រះអង្គប្រសូតនៅក្នុងក្រោលគោ ពេលសោយទិវង្គត ព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង ជារបៀបដែលគេសម្លាប់ជនឧក្រិដ្ឋនៅសម័យព្រះអង្គ ដូច្នេះពេញមួយជីវិតរបស់ព្រះយេស៊ូ គឺព្រះអង្គភ្ជាប់ជាមួយមនុស្សតូចតាចជានិច្ច។ នេះជាមូលហេតុដែលនាំឲ្យយើងជាគ្រីស្ដបរិស័ទ ភ្ជាប់ការរស់នៅរបស់ខ្លួនជាមួយមនុស្សតូចតាចដែរ។

ទីពីរ យើងគិតអំពីមនុស្សដែលសង្គមមិនរវីរវល់។

ទីបី យើងគិតអំពីជំនឿរបស់យើង និងដោយសារជំនឿ នោះណែនាំឲ្យយើងបារម្ភចំពោះការអភិវឌ្ឍសម្រាប់ព្រះសហគមន៍។ ការអភិវឌ្ឍមានន័យថា គឺយើងមិនគិតតែអំពី

រូបកាយរបស់មនុស្សតែប៉ុណ្ណឹង តែយើងគិតថា តើអំពីបុគ្គលជាអ្វី?។ តាមជំនឿរបស់យើង បុគ្គលមានន័យថាមានរូបកាយ មានប្រាជ្ញា មានវិញ្ញាណ មានការទាក់ទងជាមួយអ្នកដទៃ។ ការអភិវឌ្ឍទាំងស្រុងមានន័យថាអភិវឌ្ឍគ្រប់ផ្នែក ដែលមានទាំងរូបកាយ ប្រាជ្ញា ស្មារតីដើម្បីឲ្យទៅជាមនុស្សពេញលក្ខណៈ។ មនុស្សម្នាក់ៗមានសុភមង្គលមិនគ្រាន់ តែមានម្ហូបអាហារ មានសុខភាពល្អ មានការងារធ្វើប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានទំនាក់ទំនងជាមួយអ្នកដទៃនៅក្នុងសង្គមដែលគេរស់នៅនោះ ទើបគេមានសេចក្ដីសុខដ៏ពិតប្រាកដ មិនមែនអភិវឌ្ឍតែរូបកាយប៉ុណ្ណោះទេ។ ឧទាហរណ៍៖ នៅប្រទេសឥណ្ឌាពីសម័យមុន មានមនុស្សជាច្រើនដេកស្លាប់នៅតាមផ្លូវដោយគ្មានឱកាសបានទទួលការព្យាបាលពីមន្ទីរពេទ្យទេ ដោយសារគេគ្មានលុយ នេះជារបៀបដែលសង្គមមិនរវីរវល់នឹងគេ។ អ្នកម្ដាយតេរេសាចាប់អារម្មណ៍ នឹងសភាពការណ៍នេះ ហើយបានជួយដល់ពួកគេទាំងនោះ។ ទោះបីជាគាត់មិនអាចសង្គ្រោះពួកគេឲ្យបានជាគ្រប់គ្នាក៏ដោយ ប៉ុន្តែក៏គាត់ជួយពួកគេឲ្យស្លាប់ដោយមានកិត្តិយសដែរ ដោយឲ្យមានមនុស្សនៅថែរក្សាគេ ឬនៅក្បែរគេនៅពេលគេជិតផុតដង្ហើម។

## ១ តើអ្វីទៅជាភាពក្រីក្រ?

ព្រះជាម្ចាស់ បានត្រាស់ហៅយើងជាគ្រីស្តបរិស័ទ ឲ្យយកតម្រាប់តាមព្រះបរមគ្រូ គឺថាឲ្យយកចិត្តទុកដាក់នឹងបងប្អូនក្រីក្រឲ្យប៉ះពាល់ភាពក្រីក្ររបស់គេ ឲ្យផ្ទុកភាព ក្រីក្រនេះលើខ្លួនយើង និងឲ្យប្រព្រឹត្តកិច្ចការជាក់ច្បាស់ដើម្បីសម្រាលភាពក្រីក្ររបស់គេ។
យើងអាចយល់ថា មានភាពកម្សត់ទុគ៌តបីយ៉ាងប្លែកពីគ្នា៖

- ភាពកម្សត់ទុគ៌តខ្វះសម្ភារៈ
- ភាពកម្សត់ទុគ៌តខ្វះសីលធម៌
- ភាពកម្សត់ទុគ៌តខាងវិញ្ញាណ

ព្រះជាម្ចាស់បានត្រាស់ហៅយើងជាគ្រីស្តបរិស័ទ ឲ្យយកតម្រាប់តាមព្រះបរមគ្រូ ដោយឲ្យយកចិត្តទុកដាក់សម្រាលភាពក្រីក្ររបស់អ្នកក្រីក្រ។ ភាពកម្សត់ទុរគតរបស់មនុស្សយើងមានបី គឺទីមួយខ្វះសម្ភារៈ ទីពីរខ្វះសីលធម៌ និងទីបីខ្វះជីវិតខាងវិញ្ញាណ។ សេចក្ដីនេះណែនាំឲ្យយើងយល់អំពីភាពក្រីក្របានទូលំទូលាយជាងពេលមុន។ យើងយល់ឃើញថា អ្នកមានទ្រព្យសម្បត្តិក៏អាចទៅជាអ្នកក្រីក្របានដែរ គឺគេអាចក្រីក្រខាងសីលធម៌ ប្រសិនបើគេខ្វះ

ទំនាក់ទំនងជាមួយអ្នកតូចតាច ឬគេអាចក្រីក្រខាងវិញ្ញាណ ប្រសិនបើគេគ្មានអ្វីដែលអាចបំភ្លឺជីវិតរបស់គេ។ ចំពោះយើងដែលមានព្រះជាម្ចាស់ និងសាសន៍ដទៃដែលមានព្រះរបស់គេនោះយើងមានជីវិតខាងវិញ្ញាណដែលផ្ដល់សេចក្ដីសង្ឃឹម និងណែនាំយើងខាងសីលធម៌ដែរ។ ពេលយើងនិយាយពីភាពក្រីក្រ នោះមនុស្សទាំងអស់មិនអាចទៅជាអ្នកមានបានទេ ប្រសិនបើយើងខ្វះផ្នែកណាមួយនោះ។

## ២ ជាធ្លុងតែមួយជាមួយព្រះជាម្ចាស់យើងលឺការទួលអង្វររបស់អ្នកក្រីក្រ

### អំណរសប្បាយដែលហូរមកពីដំណឹងល្អ (ពាក្យដាស់តឿនរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ)

187. ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្ដបរិស័ទម្នាក់ៗ និងត្រាស់ហៅសហគមន៍នីមួយៗឲ្យទៅជាគ្រឿងឧបករណ៍របស់ព្រះអង្គ ដើម្បីរំដោះនិងលើកស្ទួយជនក្រីក្រ។ ធ្វើដូច្នេះ អ្នកក្រីក្រអាចចូលរួមយ៉ាងពេញលេញក្នុងសង្គមបាន។ យើងត្រូវតែយកចិត្តទុកដាក់ស្ដាប់សូរសម្រែករបស់ជនក្រីក្រ ហើយសង្គ្រោះគេទៀតផង។ បើយើងបើកគម្ពីរមកអានទើបយើងឃើញថាព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណា ទ្រង់សព្វព្រះហឫទ័យស្ដាប់សូរសម្រែករបស់ជនកម្សត់ទុគ៌ត។ " យើងបានឃើញទុក្ខលំបាករបស់ប្រជារាស្ត្រយើងនៅស្រុកអេស៊ីប យើងក៏បានឮសម្រែករបស់គេ ព្រោះតែមេត្រួតត្រាវាយដំដែរ។ យើងដឹងអំពីទុក្ខវេទនារបស់ គេហើយ។ ដូច្នេះយើងចុះមក រំដោះគេឲ្យរួចពីកណ្ដាប់ដៃរបស់ជនជាតិអេស៊ីប ។ ឥឡូវនេះ យើងចាត់អ្នកឲ្យទៅ " (សេរីភាព ៣,៧.៨.១០)។

ព្រះអង្គយកព្រះហឫទ័យទុកដាក់នឹង "ជនជាតិអ៊ីស្រាអែលដែលស្រែកអង្វរ ព្រះអង្គក៏ចាត់អ្នកសង្គ្រោះម្នាក់មកសង្គ្រោះគេ " (វរ ៣,១៥)។ ប្រសិនបើយើងធ្វើមិនដឹងមិនឮ ទោះយើងជាគ្រឿងឧបករណ៍របស់ព្រះជាម្ចាស់ ដើម្បីស្ដាប់សូរសម្រែករបស់ជនក្រីក្រក៏ដោយ ក៏យើងពិតជាស្ថិតនៅខាងក្រៅគម្រោងការ ប្រកបដោយព្រះហឫទ័យសប្បុរសរបស់ព្រះអង្គដែរ ដ្បិត " ប្រសិនបើអ្នកក្រីក្រចោទប្រកាន់អ្នកនៅចំពោះព្រះភ័ក្ត្ររបស់ព្រះអម្ចាស់ អ្នកមុខជាត្រូវទទួលទោសមិនខាន " (ទុតិយកថា ១៥,៩)។

អ្នកគ្មានសាមគ្គីចំពោះអ្នកក្រដែលខ្វះខាត នោះអ្នកក៏មិនអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរ " ប្រសិនបើមនុស្សម្នាក់ដាក់បណ្ដាសាកូន ក្នុងពេលគេពិបាកចិត្ត ព្រះអម្ចាស់ដែលបានប្រតិស្ឋានគេមុខជាទ្រង់ព្រះសណ្ដាប់ពាក្យអង្វររបស់គេពុំខាន"(បេនស៊ីរ៉ាក់៤,៦)។

មានសំណូមពរបុរាណនៅតែចោទជានិច្ចថា " ប្រសិនបើនរណាម្នាក់មានសម្បត្តិលោកីយ៍ ហើយឃើញបងប្អូនរបស់ខ្លួនខ្វះខាត តែបែរជាមិនអាណិតអាសូរគេទេនោះ ធ្វើដូចម្ដេចនឹងឲ្យសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ស្ថិតនៅក្នុងខ្លួនអ្នកនោះកើត! "(១យហ៣,១៧)។

188. ព្រះសហគមន៍បានទទួលស្គាល់ថា គ្រីស្តបរិស័ទត្រូវតែស្ដាប់សូរសម្រែករបស់អ្នកក្រខ្សត់ទុកជាភារកិច្ច ដែលមានសារៈសំខាន់ គឺជាភារកិច្ចមកពីព្រះជាម្ចាស់ដែលបានប្រណីសន្ដោសរំដោះយើងម្នាក់ៗពីខាងក្នុង។ ហេតុនេះហើយបានជាភារកិច្ចនេះ មិនមែនជាបេសកកម្មរបស់មួយក្រុមតូចដោយឡែកពីគេប៉ុណ្ណោះទេ គឺជាភារកិច្ចរបស់ព្រះសហគមន៍ទាំងមូល។"ដំណឹងល្អស្ដីអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់និងសេចក្ដីស្រឡាញ់ចំពោះមនុស្សលោក ណែនាំព្រះសហគមន៍ឲ្យស្ដាប់សូរសម្រែករបស់មនុស្សដែលចង់បានយុត្តិធម៌។ព្រះសហគមន៍ក៏ចង់តបឆ្លើយនឹងសូរសម្រែកនោះឲ្យអស់ពីសមត្ថភាពដែរ"។ដោយនឹកគិតអំពីសេចក្ដីទាំងនេះ យើងអាចយល់អត្ថន័យព្រះបន្ទូលរបស់ព្រះយេស៊ូមកក្រុមសាវ័កថា៖"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ!" (មក ៦,៣៧) គឺគ្រីស្តបរិស័ទត្រូវរួមសហការគ្នា ដើម្បីរកដំណោះស្រាយ មូលហេតុកប់ទុកក្នុងរចនាសម្ពន្ធសេដ្ឋកិច្ច ដែលបណ្ដាលឲ្យមានមនុស្សមួយចំនួនធ្លាក់ខ្លួនជាអ្នកក្រ។ គ្រីស្តបរិស័ទក៏ត្រូវរួមសហការអភិវឌ្ឍទាំងស្រុងរបស់អស់អ្នកក្រ។

191. អស់លោកគង្វាលត្រូវលើកទឹកចិត្តគ្រីស្តបរិស័ទ ឲ្យស្ដាប់សូរសម្រែករបស់ជនក្រីក្រនៅគ្រប់ទីកន្លែង និងនៅគ្រប់ពេលវេលា ដូចអស់លោកអភិបាលនៅប្រទេសប្រេស៊ីលបានបញ្ជាក់យ៉ាងច្បាស់ថា៖"រៀងរាល់ថ្ងៃយើងចង់រួមអំណរសប្បាយ និងសេចក្ដីសង្ឃឹមរួមទុក្ខព្រួយ និងកង្វល់របស់ប្រជាជននៅប្រទេសប្រេស៊ីលយើងនេះ ជាពិសេសរបស់ប្រជាជន ដែលរស់នៅខាងជាយទីក្រុង និងតាមជនបទ ជាជនដែលត្រូវបានអ្នកមានដកយកសិទ្ធិរបស់ខ្លួន។ អ្នកទាំងនោះគ្មានស្រែចម្ការ គ្មានផ្ទះនៅ គ្មានអាហារបរិភោគ សន្តិភាពគេមិនល្អ។ យើងឃើញភាពកម្សត់ទុគ៌តរបស់គេ យើងស្ដាប់សូរសម្រែករបស់គេ តែនៅពេលជាមួយគ្នានេះ យើងទាស់ចិត្តដោយដឹងច្បាស់ថា មានអាហារគ្រប់គ្រាន់សម្រាប់ចិញ្ចឹមមនុស្សទាំងអស់។ គេឃ្លានបាយកើតទុរភិក្សបណ្ដាលមកពីមានចែកចាយទ្រព្យសម្បត្តិ និងផលទុនមិនត្រឹមត្រូវ។ សភាពការណ៍នេះកាន់តែធ្ងន់ធ្ងរ ដោយគេខ្វះខ្នាយភោគផលជាទូទៅ។

192. ប៉ុន្ដែ យើងមានបំណងលើសពីនេះទៅទៀត យើងក៏បន់ស្រន់ហួសពីនេះទៅទៀតដែរ។ យើងមិនគ្រាន់តែនិយាយថា មនុស្សទាំងអស់ត្រូវមានអាហារបរិភាគគ្រប់គ្រាន់

ឬរស់នៅយ៉ាងសមគួរប៉ុណ្ណោះទេ តែយើងចង់ឲ្យមនុស្សទាំងអស់ស្គាល់ភាពសម្បូរណ៍ក្នុងគ្រប់វិស័យ គឺឲ្យគេមានលទ្ធភាពអាចអប់រំកូនចៅរបស់គេ បានឲ្យគេអាចព្យាបាលខ្លួនបាន ហើយជាពិសេសឲ្យគេមានការងារធ្វើ។ យើងដឹងថា មនុស្សបញ្ជាក់កិត្តិយសនៃជីវិតរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ដោយខ្លួនបំពេញការងារមួយដោយសេរីភាព ជាការងារដែលនាំឲ្យបង្កើតអ្វីៗជាថ្មី នាំឲ្យគេចូលរួមជាមួយអ្នកដឹកនាំ និងឲ្យរួមសាមគ្គីជាមួយអ្នកដទៃ។ ប្រសិនបើគេមានប្រាក់បៀវត្សត្រឹមត្រូវតាមយុត្តិធម៌ គេក៏មានលទ្ធភាពចូលទៅកាន់ទ្រព្យសម្បត្តិឯទៀតៗ ដែលមនុស្សទូទៅត្រូវតែប្រើប្រាស់បានដែរ។

យើងរិះគិតអំពីអ្នកតូចតាច ដែលសង្គមមិនរវីរវល់ និងមិនចង់មើលទៅគេ។ តើធ្វើដូចម្ដេចដើម្បីឲ្យយើងយល់ថា ការយកចិត្តទុកដាក់ដល់គេ គឺជាបេសកកម្មរបស់យើងជាគ្រីស្តបរិស័ទ និងជារបស់ព្រះសហគមន៍យើង? " ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទម្នាក់ៗ និងត្រាស់ហៅសហគមន៍នីមួយៗផងដែរ ឲ្យទៅជាឧបករណ៍របស់ព្រះអង្គ ដើម្បីរំដោះនិងដើម្បីលើកស្ទួយជនក្រីក្រ " (ដស៣,៧.៨.១០)។

សេចក្ដីនេះសំខាន់ណាស់ដែលបងប្អូនត្រូវយល់ឲ្យបានច្បាស់ គឺទីមួយ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទម្នាក់ៗ និងទីពីរ ព្រះអង្គត្រាស់ហៅព្រះសហគមន៍នីមួយៗដែរ។ សូមកុំឲ្យយើងបាត់ខ្លួនពីក្នុងសហគមន៍ ដ្បិតយើងទៅជាព្រះសហគមន៍ ក៏ដោយសារយើងម្នាក់ៗរួមគ្នា។ ព្រះសហគមន៍របស់យើងមានក្រុមសង្គហៈ ដែលណែនាំឲ្យយើងជួយអ្នកក្រីក្រ ដូច្នេះចូរឲ្យយើងម្នាក់ៗចូលរួមនៅក្នុងកិច្ចការសង្គហៈនេះ ដោយមិនឲ្យយើងទម្លាក់កិច្ចការនេះ លើគេ។ សូមកុំឲ្យយើងម្នាក់ៗ គិតថាមិនអីទេ នៅក្នុងព្រះសហគមន៍មានក្រុមសង្គហៈ ហើយទុកឲ្យគេធ្វើទៅ...ផ្ទុយទៅវិញ សូមឲ្យយើងម្នាក់ៗ ចូលរួមក្នុងព្រះសហគមន៍ជួយអ្នកក្រីក្រ ដែលមាននៅគ្រប់ទីកន្លែង។ ដូច្នេះទាំងព្រះសហគមន៍ អង្គការមនុស្សធម៌ ក្រុមបងប្រុសបងស្រី និងយើងផ្ទាល់ខ្លួនម្នាក់ៗដែរ ត្រូវភ្ញាក់ស្មារតី ដើម្បីមើលនូវអ្វីៗ ដែលបានកើតឡើង នៅជុំវិញយើង ដើម្បីយើងចូលនៅក្នុងទុក្ខលំបាករបស់បងប្អូនយើង ដ្បិតយើងជាឧបករណ៍របស់ព្រះជាម្ចាស់ដើម្បីរំដោះ និងដើម្បីលើកស្ទួយអ្នកក្រីក្រ។ ព្រះយេស៊ូសង្គ្រោះយើង ដើម្បីឲ្យយើងក្លាយជាអ្នកសង្គ្រោះអ្នកដទៃ ឲ្យអ្នកក្រីក្រអាចចូលក្នុង សង្គមបានយ៉ាងពេញលេញ។ សូមឲ្យយើងយល់ថា យើងមានសង្គមតែមួយ ដែលមានមនុស្សខុសៗគ្នា តែជាមនុស្សដែលចេះសហការនិងសាមគ្គីគ្នា។ តើអ្នកណាជាបងប្អូនរបស់ខ្ញុំ? គឺមនុស្សទាំងអស់ជាពិសេសអ្នកក្រីក្រ ជាបងប្អូនរបស់ខ្ញុំ...។

សព្វថ្ងៃខ្ញុំគិតថាមានសង្គមពីរ មួយជាសង្គមដែលអភិវឌ្ឍយ៉ាងលឿន និងមួយទៀតជាសង្គមដែលគ្មានអ្វីសោះ។ ផ្សារទំនើបអ៊ីអននៅភ្នំពេញ និងផ្សារទំនើបនៅកន្លែងឯទៀតៗ

ជាសង្គមដែលអភិវឌ្ឍយ៉ាងលឿន មានយុវជនយុវនារីជាច្រើនដែលគេចូលចិត្ត។ ប៉ុន្តែនៅជុំវិញទីក្រុងភ្នំពេញ មានមនុស្សជាច្រើននាក់ដែលរស់នៅក្នុងស្ថានភាពដ៏លំបាកលំបិន។ នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទដែលត្រូវគិតថា តើយើងធ្វើដូចម្តេចដើម្បីឲ្យសង្គមទាំងពីរចូលគ្នា ដើម្បីឲ្យអ្នកដែលគ្មានអ្វីសោះអាចចូលរួមបន្តិចម្តងៗនៅក្នុងសង្គមអភិវឌ្ឍនេះ។ គ្រប់សកម្មភាពដែលយើងធ្វើគឺដើម្បីអភិវឌ្ឍមនុស្សទាំងស្រុងឲ្យគេមានជីវិតយ៉ាងពិតប្រាកដដើម្បីឲ្យគេចូលនៅក្នុងសង្គមតែមួយ។ យើងគឺជាស្ពានដើម្បីឲ្យមនុស្សបង្កើតទំនាក់ទំនងជាមួយគ្នា។

" យើងបានឃើញទុក្ខលំបាករបស់ប្រជារាស្ត្រយើង នៅស្រុកអេស៊ីប យើងក៏បានឮសម្រែករបស់គេ "។ ចូរចាប់អារម្មណ៍ចំពោះសេចក្តីទាំងពីរនេះគឺ " យើងបានឃើញ និងយើងបានឮ "។ ក្នុងឆ្នាំមេត្តាករុណានេះ ចូរឲ្យយើង "ឃើញ និងឲ្យយើងឮ" មុននឹងយើងធ្វើអ្វីៗទាំងអស់។ បុរសសាម៉ារីមុននឹងគាត់ធ្វើអ្វីៗ ទាំងអស់នោះ គាត់បានឃើញ និងគាត់បានឮសម្រែករបស់អ្នកដែលត្រូវរបួសនៅតាមផ្លូវ។ ឯមនុស្សពីរនាក់ទៀត ដែលដើរមុន គេមិនបានឃើញ និងមិនបានឮអ្វីទេ(ដស ៣,៧.៨.២០)។

ដូច្នេះមុនគិតអំពីសកម្មភាពឲ្យយើងឃើញឲ្យយើងឮថាតើមានអ្វីខ្លះ ដែលយើងបានចាប់អារម្មណ៍។ បាបធំជាងគេ គឺនៅពេលណា ដែលយើងលែងចាប់អារម្មណ៍ចំពោះ អ្នកដទៃ។ ចូរឲ្យយើងចេះមើលឃើញ និងស្តាប់ឮសម្លេងអ្នកដទៃ។ យើងជាគ្រីស្តបរិស័ទម្នាក់ៗ ត្រូវការមើលឃើញ និងឮ។

"ដូច្នេះយើងចុះមក រំដោះគេឲ្យរួចពីកណ្តាប់ដៃ របស់ជនជាតិអេស៊ីប"។ ដោយសារឃើញ និងឮនោះព្រះជាម្ចាស់បានរំដោះប្រជាជនអ៊ីស្រាអែលដោយចាត់លោកម៉ូសេ ឲ្យបំពេញកិច្ចការនោះ។ ដូច្នេះលោកម៉ូសេជា ឧបករណ៍ដើម្បីសង្គ្រោះពួកគេ។ ចំពោះយើងវិញក៏ត្រូវធ្វើជាឧបករណ៍របស់ព្រះជាម្ចាស់ ដូចលោកម៉ូសេដែរ ប្រសិនបើយើងមិនធ្វើជាឧបករណ៍របស់ព្រះជាម្ចាស់ទេ យើងទៅជាអ្នកមានបាប យើងត្រូវទទួលទោសមិនខាន។ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីសម្តែងធម៌មេត្តាករុណារបស់ព្រះអង្គ។ យើងសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដោយសារយើងជឿលើព្រះអង្គ។ ពេលយើងស្ថិតនៅក្នុងការកាត់ក្តីមានសំណួរតែមួយគឺ តើប្អូនបានស្រឡាញ់ ឬអត់?(ដស ៣,៧.៨.១០)។

ជីវិតអស់កាលជានិច្ចរបស់យើង ចាប់ផ្តើមពីថ្ងៃនេះ ដោយត្រៀមខ្លួនដើម្បីឆ្លើយនឹងសំណួរថា តើបានស្រឡាញ់ ឬក៏ទេ?។ " អ្នកគ្មានសាមគ្គីចំពោះអ្នកក្រដែលខ្វះខាត អ្នកនោះក៏មិនអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរ "*(បស ៤,៦ )។*

ពេលណាយើងស្រឡាញ់អ្នកដទៃ គឺយើងស្រឡាញ់ព្រះជាម្ចាស់។ នេះជាមូលដ្ឋាននៃទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ ព្រះសហគមន៍ គឺជាការចូលរួមពីគ្រីស្តបរិស័ទម្នាក់ៗ ដែលម្នាក់ៗទទួលបេសកកម្មពីព្រះជាម្ចាស់ ដោយផ្ទាល់មិនមែនដោយទូទៅនោះទេ។

ដំណឹងល្អស្តីអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់និងសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្សលោក ណែនាំព្រះសហគមន៍ឲ្យស្តាប់សូរសម្រែករបស់ មនុស្សដែលចង់បានយុត្តិធម៌។ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ក នៅចំពោះមុខមហាជន ៥០០០ នាក់ដែលគ្មានអ្វីបរិភោគថា៖

"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ..." គឺព្រះអង្គចង់បង្រៀន ថាសូមកុំបោះបង់ចោលពួកគេ ត្រូវតែស្រឡាញ់ និងថែរក្សាពួកគេ។ សម្រាប់យើងបូជាចារ្យបព្វជិត បព្វជិតា ជាគង្វាលដ៏សប្បុរសតាមរបបព្រះយេស៊ូ ថាតើយើងធ្វើដូចម្តេចដើម្បីផ្តល់ម្ហូបអាហារឲ្យគេ?។ (មក ៦,៣៧)

តាមមហាសន្និបាតវ៉ាទីកង់ទីពីរបានបញ្ជាក់ថា ប្រសិនបើយើងមិនផ្តល់ម្ហូបអាហារដល់គេតាមព្រះបន្ទូលនេះទេ នោះយើងគឺជាឃាតករ។ សេចក្តីនេះពិតជាដាស់ស្មារតីដល់ព្រះសហគមន៍ទាំងមូល ដល់គ្រីស្តបរិស័ទទាំងអស់ ឲ្យចេះទទួលខុសត្រូវដោយសារយើងទទួលបេសកកម្មពីព្រះជាម្ចាស់ ដោយសារយើងជាឧបករណ៍របស់ព្រះជាម្ចាស់ ប្រសិនបើយើងមិនឆ្លើយតបនឹងបេសកកម្មនេះទេ នោះយើងទៅជាឃាតករពិតមែន។

សព្វថ្ងៃក្នុងពិភពលោកទាំងមូល មានមនុស្សរាប់លាននាក់បានស្លាប់ដោយសារខ្វះអាហារ ដូច្នេះសូមកុំឲ្យយើងខ្ជះខ្ជាយអាហារដែលយើងមាន ដោយគិតទៅដល់អ្នកនៅជុំវិញយើងដែលគ្មានអាហារបរិភោគ។ រៀងរាល់ថ្ងៃ ចូរឲ្យយើងមានចិត្តគំនិត ចូលរួមក្នុងអំណរសប្បាយ សេចក្តីសង្ឃឹម និងទុក្ខព្រួយរបស់ប្រជាជននៅប្រទេសប្រេស៊ីល ជាពិសេសរបស់ប្រជាជនយើង ដែលរស់នៅជាយទីក្រុង និងដែលរស់នៅតាមជនបទ ត្រូវបានពួកអ្នកមានអំណាច អ្នកមានលុយដកយកកម្មសិទ្ធិរបស់គេទាំងបំពាន បណ្តាលឲ្យពួកគេធ្លាក់ខ្លួនជាអ្នកក្រីក្រ គ្មានស្រែចម្ការធ្វើ គ្មានផ្ទះស្នាក់នៅ គ្មានអាហារបរិភោគ រស់នៅខ្វះសន្តិភាពទាំងផ្លូវកាយ និងចិត្ត។ ចំពោះយើងមិនគ្រាន់តែឲ្យមនុស្សទាំងអស់មានអាហារបរិភាគគ្រប់គ្រាន់ និងរស់នៅយ៉ាងសមគួរប៉ុណ្ណោះទេ ប៉ុន្តែយើងចង់ឲ្យមនុស្សទាំងអស់ស្គាល់ភាពសម្បូរណ៍ក្នុងគ្រប់វិស័យគឺឲ្យគេមានលទ្ធភាពបញ្ជូនកូនចៅរបស់គេទៅរៀនឲ្យទទួលបានចំណេះដឹងពិតប្រាកដ ឲ្យគេមានថវិការសម្រាប់ព្យាបាលខ្លួននៅពេលមានជំងឺ ហើយជាពិសេសឲ្យគេមានការងារធ្វើប្រកបដោយប្រាក់ឈ្នួលត្រឹមត្រូវ...។

នៅពេលយើងនិយាយអំពីការអភិវឌ្ឍអ្នកក្រីក្រ និងមនុស្សតូចតាចដែលគ្មានតម្លៃនៅក្នុងសង្គម នោះយើងមិននិយាយតែអំពីម្ហូបអាហារទេ គឺយើងនិយាយទាំងគ្រប់ផ្នែកទាំងអស់។ យើងមិនជួយអ្នកក្រីក្រដើម្បីទទួលបុណ្យកុសល ប៉ុន្តែយើងជួយដោយសារជាលក្ខណៈរបស់យើងដែលជាសេចក្តីស្រឡាញ់ ដូចព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ចូរឲ្យយើងគិត និង អនុវត្តជាក់ស្តែងនូវខ្លឹមសារនៃការអភិវឌ្ឍរបស់យើង ដើម្បីឲ្យព្រះសហគមន៍កាតូលិក

របស់យើងនៅភូមិភាគភ្នំពេញទៅជាព្រះសហគមន៍ ដែលបង្ហាញយ៉ាងជាក់ស្តែង នូវមេត្តាករុណាធម៌របស់ព្រះជាម្ចាស់ពិតមែន។

## ៣ យើងត្រូវស្មោះត្រង់នឹងដំណឹងល្អ កុំឲ្យខិតខំយ៉ាងឥតប្រយោជន៍

### អំណរសប្បាយដែលហូរមកពីដំណឹងល្អ(ពាក្យដាស់តឿនរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ)

193. ពេលយើងរំភើបចិត្តយ៉ាងជ្រៅដោយឃើញអ្នកដទៃរងទុក្ខ យើងពិតជាយល់ឃើញយ៉ាងច្បាស់ថា ត្រូវស្តាប់សូរសម្រែករបស់អ្នកក្រីក្រជាកំហិត។ សូមអានការប្រៀនប្រដៅដែលមានចែងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្តីអំពីមេត្តាករុណា សូមបណ្តោយឲ្យព្រះបន្ទូលទាំងនោះលាន់ឮឡើងយ៉ាងខ្លាំងរំពងក្នុងការរស់នៅរបស់ព្រះសហគមន៍។ ក្នុងគម្ពីរដំណឹងល្អមានប្រកាសថា ៖"អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះនៅតាមផ្លូវទៅកាន់សេចក្តីសុខសាន្តបាន ដ្បិតព្រះជាម្ចាស់នឹងមេត្តាករុណាដល់គេដែរ!" (មថ ៥,៧)។ គ្រីស្តទូតយ៉ាកុបបង្រៀនថា អ្នកមានចិត្តមេត្តាករុណា ចំពោះអ្នកដទៃក៏អាចរួចខ្លួននៅពេលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក៖ "បងប្អូនត្រូវនិយាយ និងប្រព្រឹត្តឲ្យស្របតាមវិន័យដែលផ្តល់សេរីភាព គឺមានតែវិន័យនោះហើយ ដែលនឹងវិនិច្ឆ័យបងប្អូន។ អ្នកគ្មានមេត្តាករុណា ព្រះជាម្ចាស់ក៏នឹងវិនិច្ឆ័យទោសគេ ដោយឥតមេត្តាករុណាដែរ។ អ្នកមានមេត្តាករុណាមិនខ្លាចព្រះអង្គវិនិច្ឆ័យទោសឡើយ"។ (យក ២,១២-១៣)។ ក្នុងអត្ថបទនេះ គ្រីស្តទូតយ៉ាកុបថ្លែងតាមគំនិតដ៏ប្រសើរបំផុតខាងព្រះវិញ្ញាណរបស់ជនជាតិយូដា ក្រោយពេលគេវិលត្រឡប់មកពីជាប់ជាឈ្លើយសង្គ្រាមវិញ។ នៅសម័យនោះ គេយល់ឃើញថា ធម៌មេត្តាករុណាអាចសង្គ្រោះមនុស្សលោកយ៉ាងពិសេស ដូចមានចែងថា៖ "ចូរប្រព្រឹត្តអំពើសុចរិត ដើម្បីឲ្យបានរួចពីបាប ចូរសម្តែងមេត្តាករុណាដល់អ្នកក្រីក្រទៅ ដើម្បីឲ្យបានរួចពីបទល្មើសនិងបានអាយុវែង " (ដន ៤,២៤)។ អ្នកនិពន្ធសំណេរស្តីអំពីព្រះប្រាជ្ញាញាណក៏មានគំនិតដដែលនោះ ហើយចែងអំពីទានទុកជាកិច្ចដ៏ជាក់លាក់សម្តែងមេត្តាករុណា ចំពោះអស់អ្នកដែលខ្វះខាតថា ៖"ការចែកទានរំដោះមនុស្សឲ្យរួចពីសេចក្តីស្លាប់ហើយជម្រះគេឲ្យរួចពីអំពើបាបគ្រប់យ៉ាង។អ្នកធ្វើទានរមែងមានអាយុវែង" (តប ១២,៩)។ លោកបែនស៊ីរ៉ាក់ បញ្ចេញយោបល់ដដែល ដោយប្រើនិមិត្តរូបដូចតទៅ៖" ទឹកពន្លត់ភ្លើងដែលឆេះសន្ធោសន្ធៅយ៉ាងណា ការដាក់ទានក៏លុបលាងបាបយ៉ាងនោះដែរ (បស៣,៣០)។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ក៏មានចែងសេចក្តីដដែលនោះថា ៖"ជាបឋមត្រូវមានចិត្តស្រឡាញ់គ្នាទៅវិញទៅមកជានិច្ច ដ្បិតសេចក្តីស្រឡាញ់ រមែងគ្របបាំងអំពើបាបដ៏ច្រើនលើសលប់" (១ សល ៤,៨)។

# III. " ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា "

## អំណរសប្បាយដែលហូរមកពីដំណឹងល្អ( ពាក្យដាស់តឿនរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្វូ)

197. ព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់អ្នកក្រីក្រយ៉ាងពិសេស រហូតដល់ព្រះអង្គ " ដាក់ខ្លួនជាអ្នកក្រ " ( ២ ករ៨,៩ ) ។ មានអ្នកក្រីក្រ មានឥទ្ធិពលយ៉ាងខ្លាំងតាម ប្រវត្តិសាស្ត្រនៃការសង្គ្រោះរបស់យើងជានិច្ច។ ការសង្គ្រោះនេះមកដល់យើង ដោយមាននាងម៉ារីសុខចិត្តទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នាងជាស្ត្រីដ៏ទន់ទាបម្នាក់ រស់នៅក្នុងភូមិដាច់ស្រយាលនៅជាយមហាចក្រភព។នាងរាប់ព្រះយេស៊ូទុកជាព្រះសង្គ្រោះរបស់យើង ដែលទើបកើតដាក់ក្នុងស្នូកសត្វ ហើយមានសត្វនៅជុំវិញ ដូចកូនអ្នកក្រជាងគេធ្លាប់កើតនៅសម័យនោះ។ លោកយ៉ូសែបយកលលកមួយគូមកថ្វាយក្នុងព្រះវិហារ ដើម្បីលោះព្រះឱរស គឺលោកយកតង្វាយរបស់អ្នកក្រមកថ្វាយព្រោះអ្នកក្រគ្មានលទ្ធភាពទិញកូនចៀមបានទេ( លក២,២៤ ; លវ ៥,៧ ) ។ ព្រះយេស៊ូចម្រើនវ័យឡើងក្នុងផ្ទះពលករម្នាក់ និងបានធ្វើការចិញ្ចឹមជីវិតដោយផ្ទាល់ព្រះអង្គ។ ពេលព្រះអង្គចាប់ផ្តើមប្រកាសដំណឹងអំពីព្រះជាម្ចាស់យាងមកគ្រងរាជ្យ មានមហាជនអ្នកក្រីក្រដើរតាមព្រះអង្គ ហើយទ្រង់សម្តែងសេចក្តីដែលព្រះអង្គមានព្រះបន្ទូលដោយផ្ទាល់ព្រះអង្គថា៖ " ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ "។ (លក៤,១៨) ។ ព្រះអង្គក៏បញ្ជាក់ថាព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាចំពោះអ្នកដែលកើតទុក្ខវេទនា និងជនក្រីក្រ៖ "អ្នករាល់គ្នាជាជនក្រខ្សត់អើយ! អ្នកនៅតាមផ្លូវទៅកាន់សេចក្តីសុខសាន្តបាន ដ្បិតព្រះជាម្ចាស់នឹងគ្រងរាជ្យលើអ្នករាល់គ្នាហើយ (លក ៦,២០) ។ ព្រះអង្គបានរួមរស់ជាមួយគេ ៖ "កាលយើងឃ្លានអ្នករាល់គ្នាបានឲ្យអាហារយើងបរិភោគ" (មថ ២៥,៣៥) ។ ព្រះអង្គតែងប្រៀនប្រដៅថា ចិត្តមេត្តាករុណាចំពោះអ្នកក្រីក្រ ពិតជាកូនសោដែលបើកទ្វារនៃស្ថានបរមសុខ។

គ្រីស្តបរិស័ទម្នាក់ៗ និងព្រះសហគមន៍ ត្រូវរួមគ្នាទៅជាឧបករណ៍របស់ព្រះជាម្ចាស់ដើម្បីណែនាំ និងសង្គ្រោះបងប្អូនរបស់យើង និងសង្គមរបស់យើង។ យើងបីដូចជាលោកម៉ូសេយើងមានតួនាទីមួយយ៉ាងពិសេស គឺនាំការសង្គ្រោះដល់បងប្អូនឯទៀតៗ ជាពិសេសគឺដល់បងប្អូនអ្នកក្រីក្រឲ្យគេទទួលជីវិតថ្មី ឲ្យគេទទួលបាននូវការអភិវឌ្ឍន៍ទាំងស្រុង គឺអភិវឌ្ឍទាំង

រូបកាយ ទាំងវិញ្ញាណ ទាំងចំណេះដឹង ទាំងប្រាជ្ញា ដើម្បីឲ្យគេមានវត្តមាននៅក្នុងសង្គមដូចមនុស្សឯទៀតៗដែរ។ ដូច្នេះ យើងជាគ្រីស្តបរិស័ទត្រូវតែចូលរួមនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដោយយើងធ្វើតាមសមត្ថភាព និងដោយអស់ពីសមត្ថភាពរបស់យើង។ យើងជាលោកម៉ូសេដ៏តូចមួយ យើងជាព្រះយេស៊ូដ៏តូចមួយអង្គទៀត យើងជាព្រះសង្គ្រោះដ៏តូចមួយអង្គទៀត...។

ឧទាហរណ៍អំពីអ្នកម្តាយតេរេសា អំពីលោកឪពុកដាញ៉ែល ដែលពួកគាត់បានជួយដោយអស់ពីសមត្ថភាពដល់អ្នកក្រីក្រ ដោយសារពួកគាត់ បានមើលឃើញវត្តមានរបស់ព្រះយេស៊ូដែលគង់នៅជាមួយអ្នកក្រីក្រ។ យើងមិនមែន ជាអ្នកម្តាយតេរេសា មិនមែនជាលោកឪពុកដាញ៉ែលទេ ប៉ុន្តែយើងគឺជាយើង គឺយើងម្នាក់ៗ ដែលជួយអ្នកក្រីក្រដោយអស់ពីសមត្ថភាពដែលយើងមាន ដើម្បីនាំសេចក្តីសង្ឃឹម និងអំណរសប្បាយដល់អ្នកដទៃ ដោយយល់ឃើញថាបងប្អូនអ្នកក្រីក្រទាំងអស់នោះ ក៏មានទីតាំងមួយយ៉ាងពិសេសនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ដែរ។

# ១ អំពីភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា

## អំណរសប្បាយដែលហូរមកពីដំណឹងល្អ( ពាក្យដាស់តឿនរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ )

198. ព្រះសហគមន៍បានជ្រើសរើសបម្រើអ្នកក្រីក្រលើសគេទាំងអស់ ស្របតាមព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់នោះគឺ"ជម្រើសបម្រើអ្នកក្រីក្រជាអាទិភាពពិសេសម៉្យាងក្នុងការប្រព្រឹត្តតាមសេចក្តីស្រឡាញ់របស់គ្រីស្តបរិស័ទ។ ការបង្រៀនបញ្ជូនបន្ត របស់ព្រះសហគមន៍ទាំងមូលក៏បញ្ជាក់អាទិភាពនោះដែរ"។សម្តេចប៉ាបបេណេឌិកតូទី១៦តែងបង្រៀនថាជម្រើសបម្រើអ្នកក្រីក្រ " ជាប់ពាក់ព័ន្ធនឹងជំនឿចំពោះព្រះគ្រីស្ត ជាព្រះដែលដាក់ខ្លួន ជាអ្នកក្រ ដើម្បីជាប្រយោជន៍ដល់យើង គឺដើម្បីឲ្យយើងមានសម្បត្តិសួគ៌ជាច្រើនដោយភាពក្រីក្ររបស់ព្រះអង្គ"។ ហេតុនេះ ហើយបានជាខ្ញុំចង់ឲ្យព្រះសហគមន៍រស់នៅបែបអ្នកក្រ ដើម្បីបម្រើអ្នកក្រ។ អ្នកក្រអាចបង្រៀនសេចក្តីជាច្រើនមកយើង។ គេមានគំនិតទូទៅអំពីជំនឿដូចគ្រីស្តបរិស័ទឯទៀតៗ។ លើសពីនេះទៅទៀត គេស្គាល់ព្រះគ្រីស្តដែលរងទុក្ខលំបាកថែមទៀត ព្រោះគេរងទុក្ខលំបាកដូចព្រះអង្គដែរ។ យើងទាំងអស់ត្រូវបណ្តោយខ្លួនឲ្យអ្នកក្រនាំដំណឹងល្អមកយើងជាចាំបាច់។ ការប្រកាសដំណឹងល្អបែបថ្មីដាស់តឿនយើងឲ្យទទួលស្គាល់ថា ការរស់នៅរបស់គេពិតជាកម្លាំងដែលសង្គ្រោះមនុស្សលោក យើងត្រូវយកគេមកដាក់នៅកណ្តាលដំណើរនៃព្រះសហគមន៍។ ព្រះជាម្ចាស់ត្រាស់ហៅយើង ឲ្យទទួលស្គាល់ព្រះគ្រីស្តក្នុងរូបគេឲ្យយើងជួយតវ៉ាការពារគេ និងឲ្យទៅជាមិត្តសម្លាញ់របស់គេ ឲ្យស្តាប់គេនិយាយ ឲ្យយល់ចិត្តគំនិតរបស់គេ និងឲ្យទទួលព្រះប្រាជ្ញាញាណដ៏អាថ៌កំបាំង ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យចែកចាយឲ្យយើងតាមរយៈគេដែរ។

នៅក្នុងសារលិខិតរបស់សម្តេចប៉ាបបានបញ្ជាក់ថា ដំណឹងល្អគឺជាអំណរសប្បាយ។ ព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់អ្នកក្រីក្រយ៉ាងពិសេស រហូតដល់ព្រះអង្គដាក់ខ្លួនជាអ្នកក្រីក្រ។ យើងជួយអ្នកក្រីក្រ គឺមិនមែនដោយសារ យើងមានចិត្តល្អ មិនមែនដោយសារយើងមានចិត្តអាណិតមេត្តាករុណា តែដោយសារយើងមានព្រះយេស៊ូ ដែលជាមូលហេតុរបស់យើង ។នៅពេលយើងមើលព្រះយេស៊ូនោះយើងត្រូវមើលអំពីរបៀបដែលព្រះអង្គប្រសូត និងព្រះអង្គសោយទិវង្គត។ សម្តេចប៉ាបបានរំឭកយើងថា ព្រះនាងម៉ារីបានប្រសូតព្រះយេស៊ូនៅត្រង់កន្លែងដ៏ក្រីក្របំផុតគឺក្រោលសត្វ និងបន្ទាប់មកព្រះនាងនាំព្រះកុមារមករស់នៅភូមិ

ណាសារ៉ែត។ ព្រះយេស៊ូមិនមែនជាអ្នកមានទេ ព្រះអង្គធ្លាប់ជាជាងឈើ ដែលមានឪពុកមានរបរចិញ្ចឹមជីវិតជាជាងឈើ ដែលមានទំនាក់ទំនងជាមួយប្រជាជនឯទៀតៗយ៉ាងជិតស្និទ្ធ។ ក្រោយមកព្រះយេស៊ូបានយាងមកស្រុកកាលីឡេ និងបានប្រកាសនូវសេចក្តីដ៏សំខាន់ជាលើកទីមួយថា " ព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកជិតដល់ហើយ"។

ព្រះយេស៊ូបានអានអត្ថបទគម្ពីររបស់លោកអេសាយដែលចែងថា ' ខ្ញុំមកដើម្បីរំដោះអ្នកដែលជាប់ឃុំឃាំងឲ្យមានសេរីភាព អ្នកខ្វាក់ឲ្យមើលឃើញ អ្នកក្រីក្រឲ្យស្តាប់ឮដំណឹងល្អ..." ។ សព្វថ្ងៃព្រះបន្ទូលនេះកើតទៅជារូបរាងដោយសារព្រះយេស៊ូជាដំណឹងល្អដោយសារព្រះយេស៊ូជាព្រះសង្គ្រោះ ព្រះអង្គប្រោសអ្នកខ្វាក់ អ្នកពិការ អ្នកបាប អ្នកដែលគ្មានសេចក្តី សង្ឃឹមអ្នកដែលមានជំងឺច្រើនឆ្នាំឲ្យមានសង្ឃឹមឡើងវិញ ព្រះអង្គស្រឡាញ់ក្មេងៗ ស្រឡាញ់លោកសាខេជាអ្នកបាប... នេះជាជីវិតរបស់ព្រះយេស៊ូជាមួយអ្នកដទៃ និងជាចុងក្រោយបំផុតព្រះអង្គលះបង់ចោលអ្វីៗទាំងអស់ ដោយបម្រើ ដោយលើកលែងទោស និងដោយបូជាព្រះជន្ម។ សេចក្តីទាំងនេះ រំឭកឲ្យយើងចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូ ដោយសារព្រះអង្គបានចូលទៅក្នុងជីវិតរបស់យើងរួចទៅហើយ។ ព្រះជាម្ចាស់របស់យើងមិនដែលនៅឆ្ងាយពីយើង ប៉ុន្តែជាព្រះជាម្ចាស់ដែលចាប់កំណើតជាមនុស្ស និងធ្វើដំណើររួមជាមួយយើង។

ពេលអធិដ្ឋាន យើងមានព្រះកាយព្រះគ្រីស្តជាវត្តមានរបស់ព្រះយេស៊ូ ដែលគង់នៅជមួយយើងជារបៀបដែលព្រះអង្គស្រឡាញ់យើង និងណែនាំឲ្យយើងស្រឡាញ់អ្នកដទៃ ដូចព្រះអង្គស្រឡាញ់យើងដែរ។

សម្តេចប៉ាបបាន រំឭកយើងថា៖ " ចិត្តមេត្តាករុណាចំពោះអ្នកក្រីក្រ គឺជាកូនសោរដើម្បីបើកទ្វារនៃស្ថានបរមសុខ..."។

អនាគតដ៏អស្ចារ្យរបស់យើងម្នាក់ៗ នៅស្ថានបរមសុខ គឺនៅពេលនេះដែលយើងត្រូវតែរៀបចំកូនសោរដើម្បីបើកទ្វារនៃស្ថានបរមសុខនោះ ហើយកូនសោរនោះ គឺជាចិត្តមេត្តាករុណាដ៏ពិតប្រាកដចំពោះអ្នកក្រីក្រ។ ដូច្នេះចូរឲ្យយើងជាគ្រីស្តបរិស័ទ មានចិត្តឲ្យស្របតាមព្រះហឫទ័យរបស់ព្រះយេស៊ូ ព្រះអង្គមានព្រះហឫទ័យយ៉ាងណា យើងក៏ត្រូវមានចិត្តយ៉ាងនោះ។

ហេតុនេះហើយចូរឲ្យយើងស្រឡាញ់អ្នកក្រីក្រ ដូចព្រះយេស៊ូដែលស្រឡាញ់អ្នកក្រីក្រ។ តើខ្ញុំមានចិត្តមេត្តាករុណាយ៉ាងណា ចំពោះអ្នកក្រីក្រ ?។

ចំពោះយើង មេត្តាករុណាដែលយើងមាន គឺមិនមែនយើងអាណិតគេទើបយើងជួយគេនោះទេ មេត្តាករុណារបស់យើង គឺដោយសារព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ និងខ្ញុំជាសេចក្តីស្រឡាញ់ដូចព្រះជាម្ចាស់។ មេត្តាករុណារបស់ខ្ញុំ គឺណែនាំឲ្យគេអភិវឌ្ឍន៍ទាំងស្រុង មានន័យថាឲ្យជីវិតរបស់គេ ទៅជាជីវិតពេញលក្ខណៈ។

## ២ ធ្វើដូចម្តេចដើម្បីឲ្យអ្នកក្រីក្រចូលរួមនៅក្នុងសង្គម

យើងជាគ្រីស្តបរិស័ទត្រូវតែជាស្ពានដូចលោកម៉ូសេ ដែលណែនាំប្រជាជនចេញពីប្រទេសអេស៊ីប ឲ្យឆ្លងកាត់សមុទ្រក្រហមរួចផុតពីពីទាសភាព ចូលទៅកាន់ទឹកដីដែលមានសេរីភាពយ៉ាងអស្ចារ្យ ដែលជាបុណ្យទីមួយនៃសាសនាយូដា។ ចំពោះបុណ្យចម្លងរបស់យើង គឺព្រះយេស៊ូដែលសោយទិវង្គត ឆ្លងសេចក្តីស្លាប់និងមានព្រះជន្មរស់ឡើងវិញ ដូច្នេះចូរឲ្យយើងធ្វើខ្លួនទៅជាស្ពាន ដើម្បីឲ្យអ្នកក្រីក្រឆ្លងផុតពីភាពងងឹត ទៅមានជីវិតភ្លឺស្វាង។ ជីវិតភ្លឺស្វាងមានន័យថាគេអាចចូលរួមយ៉ាងសកម្មនៅក្នុងសង្គមទាំងមូល គេទៅជាមនុស្សពេញលក្ខណៈ គេមិនមែនជាមនុស្សមានអាហារបរិភោគដើម្បីតែឆ្អែត មានទីលំនៅដើម្បីតែស្នាក់នៅ ប៉ុន្តែគេមានលទ្ធភាពបញ្ជូនកូនចៅឲ្យទៅសិក្សា គេក៏មានការងារធ្វើទទួលប្រាក់ចំណូលយ៉ាងត្រឹមត្រូវផងដែរ។ ហេតុនេះហើយ បានជាសម្តេចប៉ាប សូមឲ្យព្រះសហគមន៍រស់នៅតាមរបៀបក្រីក្រដើម្បីបម្រើអ្នកក្រីក្រ។

ចំពោះខ្ញុំ ខ្ញុំសូមឲ្យបងប្អូននាំយកសេចក្តីទាំងប៉ុន្មានដែលបងប្អូនបានស្តាប់ឮបញ្ជូនបន្តដល់បងប្អូនឯទៀតៗផង ទាំងបំផុសសំណួរថា ' តើយើងធ្វើដូចម្តេច ដើម្បីទៅជា អ្នកក្រីក្រដែលជួយអ្នកក្រីក្រ ?"។ សូមឲ្យលោកឪពុក បងប្រុស បងស្រី អ្នកដឹកនាំគណៈកម្មការយុវជនទាំងអស់រិះគិតថា " តើព្រះសហគមន៍ក្រីក្រដើម្បីបម្រើអ្នកក្រីក្រ មានអត្ថន័យយ៉ាងដូចម្តេចសម្រាប់យើងនៅប្រទេស កម្ពុជា ? ។ តើធ្វើដូចម្តេច ដើម្បីឲ្យជីវិតរបស់យើងភ្ជាប់ទៅនឹងរបៀបរស់នៅ របស់ព្រះយេស៊ូ ?"។ ពេលនេះ ខ្ញុំមានចំណុចពីរដ៏សំខាន់សម្រាប់ជូនដល់បងប្អូន គឺ៖

ទី១ យើងមិនគ្រាន់តែប្តេជ្ញាចិត្តធ្វើកិច្ចការ និងធ្វើកម្មវិធីក្នុងគោលបំណងលើកស្ទួយកិត្តិយសដើម្បីជួយដល់អ្នកក្រីក្រតែប៉ុណ្ណោះទេ។

ទី២ គឺព្រះវិញ្ញាណក៏មិនជំរុញឲ្យយើងធ្វើកិច្ចការជាច្រើនហួសហេតុពេកដែរ តែព្រះអង្គជំរុញយើងឲ្យចាប់អារម្មណ៍នឹងអ្នកដទៃ ដែលគេមក "រួបរួមជាមួយនឹងព្រះអង្គ"។ ចំណុចទាំងពីរនេះណែនាំឲ្យយើងចូលយ៉ាជ្រៅ នៅក្នុងការបង្កើតទំនាក់ទំនងជាមួយអ្នកក្រីក្រ។ យើង

ជាគណៈកម្មការសង្គហៈ ក្រុមយុវជន បូជាចារ្យ បព្វជិតបព្វជិតា កុំភ្លេចថា បើយើងជួយអង្ករដល់គ្រួសារក្រីក្រមួយ ហើយយើងគ្មានទំនាក់ទំនងជាមួយគេទេនោះ តើការណ៍នោះនឹងមានប្រយោជន៍អ្វី?។ ប្រសិនបើយើងសាងសង់ផ្ទះឲ្យក្រុមគ្រួសារមួយ ប៉ុន្តែបើយើងមិនបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមគ្រួសារនោះទេ តើមានប្រយោជន៍អ្វី?។ ប្រសិនបើយើងចេញលុយព្យាបាលអ្នកជំងឺក្រីក្រម្នាក់ តែបើយើងមិនបានទៅសួរសុខទុក្ខគេ គ្មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគេទេ តើមានប្រយោជន៍អ្វី?។

អំពើបាបដែលធំជាងគេគឺការមើលមិនឃើញ និងស្តាប់មិនឮអំពីទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ ចាប់អារម្មណ៍ មានន័យថាយើងមើលឃើញ យើងស្តាប់ឮ និងយើងបង្កើតទំនាក់ទំនង ជាមួយគេ។ យើងត្រូវតែបង្កើតទំនាក់ទំនង ដោយសារយើងចាប់អារម្មណ៍ពីគេ។ ប្រសិនបើយើងធ្វើសកម្មភាពយ៉ាងច្រើន តែយើងឥតបង្កើតទំនាក់ទំនង យើងឥតស្គាល់គេទេ នោះគ្មានន័យទេ។

សម្តេចប៉ាបបានជំរុញយើង គឺឲ្យយើងចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងពិតប្រាកដចំពោះអ្នកក្រីក្រ។ ការយកចិត្តទុកដាក់នឹងគេ នោះនឹងជំរុញឲ្យយើងចង់រកប្រយោជន៍សម្រាប់គេយ៉ាងសកម្ម។

## អំណរសប្បាយដែលហូរមកពីដំណឹងល្អ(ពាក្យដាស់តឿនរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ)

199. យើងមិនគ្រាន់តែប្តេជ្ញាចិត្តធ្វើកិច្ចការ និងកម្មវិធីក្នុងគោលបំណងលើកស្ទួយកិត្តយសរបស់គេ និងជួយគេប៉ុណ្ណោះទេ ព្រះវិញ្ញាណក៏មិនជំរុញយើងឲ្យធ្វើកិច្ចការជាច្រើនហួសហេតុដែរ តែព្រះអង្គជំរុញឲ្យយើងចាប់អារម្មណ៍នឹងអ្នកដទៃ ដែលព្រះអង្គចាត់ទុកថា"រូបរួមជាមួយព្រះអង្គ"។ អ្នកដែលចាប់អារម្មណ៍នឹងអ្នកក្រីក្រចាប់ផ្តើមយកចិត្តទុកដាក់យ៉ាងពិត ប្រាកដចំពោះគេ។ ប្រសិនបើខ្ញុំយកចិត្តទុកដាក់នឹងគេ ខ្ញុំក៏ចង់រកប្រយោជន៍សម្រាប់ គេយ៉ាងសកម្ម។ ហេតុនេះហើយបានជា ត្រូវលើកតម្កើងសេចក្តីដ៏សប្បុរសផ្ទាល់របស់អ្នកក្រ ត្រូវលើកតម្កើងរបៀបរស់នៅរបស់គេ និងលើកតម្កើងវប្បធម៌របស់គេ ព្រមទាំងលើកតម្កើងរបៀបគេរស់នៅតាមជំនឿដែរ។ អ្នកមានចិត្តស្រឡាញ់យ៉ាងពិតប្រាកដ ត្រូវតែនឹកស្ញើងស្ងាច់ស្ងើចសរសើរអ្នកដែលខ្លួនស្រឡាញ់នោះ។ ដូច្នេះយើងមិនបម្រើគេដោយ យើងត្រូវការបម្រើគេទេ ឬដោយចង់អួតខ្លួនដែរ តែយើងបម្រើគេ ព្រោះគេល្អហួសពីអាការៈខាងក្រៅ ដែលមនុស្សមើលឃើញ។ " យើងផ្តល់អំណោយដល់មនុស្សម្នាក់ មកពីយើងស្រឡាញ់គេ "។ ពេលយើងស្រឡាញ់អ្នកក្រ យើងដូចជាវាយតម្លៃគេយ៉ាងខ្ពស់ណាស់។ សេចក្តីស្រឡាញ់បែបនេះ នាំឲ្យ

យើងជ្រើសរើសបម្រើអ្នកក្រលើសគេទាំងអស់ យ៉ាងពិតប្រាកដតាមរបៀបប្លែកពីអ្នកកាន់តាមមនោគមវិជ្ជាណាមួយ ទោះជាមនោគមវិជ្ជាណាក៏ដោយ យើងក៏ប្លែកពីអ្នកទាំងអស់ ដែលមានបំណងប្រើអ្នកក្រីក្រ ដើម្បីបម្រើផលប្រយោជន៍របស់ខ្លួនគេផ្ទាល់ ឬដើម្បីបម្រើផលប្រយោជន៍នយោបាយវិញ។ យើងអាចជួយជូនដំណើរអ្នកក្រយ៉ាងត្រឹមត្រូវ តាមផ្លូវណែនាំឲ្យរំដោះខ្លួនគេបាន លុះត្រាតែយើងរស់នៅក្បែរគេយ៉ាងពិតប្រាកដ និងដោយយើងមានចិត្តស្រឡាញ់។ ប្រសិនបើដូច្នេះ អស់អ្នកក្រីក្រនឹងយល់ឃើញថា ក្នុងគ្រប់សហគមន៍គ្រីស្តបរិស័ទក៏ដូចជាគេនៅក្នុងផ្ទះរបស់គេដែរ។ របៀបរស់នៅបែបនេះ ប្រហែលបង្ហាញដំណឹងល្អស្តីអំពីព្រះជាម្ចាស់គ្រងរាជ្យយ៉ាងច្បាស់ជាងគេនិងស័ក្តិសិទ្ធិជាងគេ។ ប្រសិនបើព្រះសហគមន៍មិនជ្រើសរើសបម្រើអ្នកក្រីក្រលើសគេទាំងអស់ ប្រហែលមនុស្សលោកមិនយល់ការប្រកាសដំណឹងល្អទេ ឬដំណឹងល្អគ្រាន់តែក្លាយទៅជាពាក្យសម្តី ដែលហូរហែរតាមរបៀបសង្គមនាបច្ចុប្បន្នតែងតែប្រាប់យើងជារៀងរាល់ថ្ងៃប៉ុណ្ណោះ។ រីឯការប្រកាសដំណឹងល្អនេះ សម្តែងសេចក្តីស្រឡាញ់លើសអ្វីៗទាំងអស់។

ខ្ញុំចាប់អារម្មណ៍អំពីគេ ខ្ញុំស្គាល់ជីវិតរបស់គេ នោះនាំឲ្យខ្ញុំយល់អំពីមូលហេតុនៃបញ្ហារបស់គេ ហើយក៏នាំឲ្យខ្ញុំចាប់ផ្តើមរកផ្លូវដើម្បីជួយគេ ដើម្បីឲ្យគេរីកចម្រើនរួមជាមួយគ្នា ដើម្បីរំដោះគេពីការដាច់ដោយឡែកឲ្យចូលរួមក្នុងសង្គមវិញ។

ចំពោះយើងជាគ្រីស្តបរិស័ទ ពេលណាយើងចូលនៅក្នុងទំនាក់ទំនងជាមួយអ្នកតូចតាច នោះបន្តិចម្តងៗ ណែនាំឲ្យយើងចេះអាណិតមេត្តាដល់គេតាមរបៀបព្រះជាម្ចាស់ "អ្នកមានចិត្តស្រឡាញ់យ៉ាងពិតប្រាដ ត្រូវតែស្ទឹងស្មាធិ៍ស្ញើចសរសើរអ្នកដែលខ្លួនស្រឡាញ់នោះ។ ដូច្នេះ យើងមិនបម្រើគេ ដោយយើងត្រូវការបម្រើគេទេ ឬដោយចង់អួតខ្លួនដែរ តែយើងបម្រើគេ ព្រោះគេល្អហួសពីអាការៈខាងក្រៅដែលមនុស្សមើលឃើញ..."។

យើងផ្តល់អំណោយដល់មនុស្សណាម្នាក់ គឺដោយសារយើងស្រឡាញ់ និងមានចិត្តមេត្តាករុណាដល់គេដូចព្រះជាម្ចាស់ដែលមានព្រះហឫទ័យមេត្តាករុណា។ ហេតុដូច្នោះហើយពេលនោះយើងត្រូវតែអធិដ្ឋានសម្រាប់គេដោយសម្លឹងមើលទៅព្រះយេស៊ូ ដើម្បីឲ្យគេបានទទួលសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដមែន។ យើងមិនជួយដើម្បីជួយ យើងមិនបម្រើដើម្បីបម្រើ យើងមិនជួយដើម្បីបានការសរសើរ ឬបានមេដាយ ប៉ុន្តែយើងជួយនៅក្នុងសេចក្តី

ស្រឡាញ់ ហើយសេចក្តីស្រឡាញ់នោះចេញមកពីយើងអធិដ្ឋាន ដែលបន្តិចម្តងៗនាំឲ្យយើងបង្កើតទំនាក់ទំនងយ៉ាងពិតប្រាកដ ដើម្បីឲ្យយើងជួយនៅក្នុងចិត្តស្រឡាញ់ ចិត្តមេត្តាករុណាដែលមកពីព្រះជាម្ចាស់ដែលនាំឲ្យយើងស្រឡាញ់គេដូចព្រះជាម្ចាស់ស្រឡាញ់គេដែរ។ "យើងអាចជួយជូនដំណើរអ្នកក្រយ៉ាងត្រឹមត្រូវ តាមផ្លូវដែលណែនាំឲ្យគេរំដោះខ្លួនបាន លុះត្រាតែយើងរស់នៅក្បែរគេ និងដោយសារយើងមានចិត្តស្រឡាញ់យ៉ាងពិតប្រាកដ។ ប្រសិនបើដូច្នេះមែននោះ អស់អ្នកក្រីក្រនឹងយល់ឃើញថា គ្រប់សហគមន៍គ្រីស្តបរិស័ទ គឺជាផ្ទះជាកន្លែងរបស់ពួកគេដែរ"។ តើត្រូវធ្វើដូចម្តេច ដើម្បីឲ្យអ្នកក្រីក្រទទួលស្គាល់ថាព្រះសហគមន៍របស់យើង ក៏ជាផ្ទះរបស់ពួកគេ ដែលគេហ៊ានចេញចូលដូចជាគ្រួសារតែមួយ ដូចជា ផ្ទះតែមួយរបស់គេ និងរបស់យើងដែរ?។

ព្រះសហគមន៍កាតូលិក គឺជាផ្ទះរបស់យើង និងពិតមែនជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់។ពេលគេចេញចូលក្នុងព្រះសហគមន៍របស់យើង មិនមែនមានន័យថាយើងបង្ខំឲ្យគេទៅជាគ្រីស្តបរិស័ទទេ តែយើងគោរពសេរីភាពរបស់គេ។ ឧទាហរណ៍៖ នៅខេត្តតាកែវ យើងមានកម្មវិធីមនុស្សធម៌មួយនៅក្នុងភូមិសុខសាន្ត ដែលមួយឆ្នាំបួនដង យើងមានរៀបចំកម្មវិធីមួយហៅថា *"យើងរួមគ្នាកសាងសន្តិភាព"* ដោយយើងបានអញ្ជើញអ្នកភូមិនៅជុំវិញឲ្យចូលរួមជាមួយ ដើម្បីយើងលេង យើងញ៉ាំជាមួយអ្នកជំងឺ អ្នកពិការដោយអំណរសប្បាយ។ ពេលណាទំនាក់ទំនងរបស់យើងណែនាំឲ្យអ្នកដែលយើងជួយមានអារម្មណ៍កក់ក្តៅ ដូចជាគេនៅផ្ទះរបស់គេដែរ នោះពិតមែនពេលនោះ គឺយើងបានចូលនៅក្នុងគម្រោងការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ហើយ។

ដូច្នេះសរុបសេចក្តីមក ទីមួយព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ទីពីរព្រះជាម្ចាស់ណែនាំឲ្យខ្ញុំទៅជាសេចក្តីស្រឡាញ់ ទីបីព្រះជាម្ចាស់ណែនាំឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក និង ឲ្យយើងណែនាំឲ្យអ្នកតូចតាច ដែលជាដៃគូយ៉ាងពិសេសរបស់ព្រះជាម្ចាស់ ទៅជាមិត្តសម្លាញ់របស់យើងដែរ ដោយសារយើងបានមើលឃើញយើងបានស្តាប់ពួ និងយើងបានបង្កើតទំនាក់ទំនងជាមួយគេ។ ដូច្នេះនាក់ទំនងដែលយើងបានបង្កើត គឺជាទំនាក់ទំនងនៅក្នុងសេចក្តីស្រឡាញ់ដែលយើងបានទទួលពីការអធិដ្ឋាន ដែលជួយឲ្យមនុស្សដែលយើងចង់ជួយមានជីវិតថ្មី គឺមានន័យថាគេអភិវឌ្ឍខ្លួនគេទាំងស្រុង។

## អំណរសប្បាយដែលហូរមកពីដំណឹងល្អ (ពាក្យដាស់តឿនរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ)

200. ខ្ញុំសូមផ្ញើពាក្យដាស់តឿននេះជូនមកសមាជិកនៃព្រះសហគមន៍កាតូលិក។ ហេតុនេះ ខ្ញុំសូមនិយាយទាំងព្រួយថា អ្នកក្រីក្រកើតទុក្ខដោយយើងប្រកាន់គេ បណ្ដាលមកពីយើងមិនចាប់អារម្មណ៍នឹងគេខាងវិញ្ញាណ។ អ្នកក្រីក្រភាគច្រើន យកចិត្តទុកដាក់យ៉ាងពិសេសអំពីជំនឿ គេត្រូវការព្រះជាម្ចាស់យ៉ាងខ្លាំង។ យើងមិនអាចធ្វេសប្រហែស ជូនព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះគេ ធ្វេសប្រហែសនាំពររបស់ព្រះអង្គដល់គេ ធ្វេសប្រហែសនាំព្រះបន្ទូលដល់គេ ធ្វេសប្រហែសធ្វើអគ្គសញ្ញាជូនគេ ព្រមទាំងធ្វេសប្រហែសផ្ដល់យោបល់អំពីផ្លូវ ដែលនាំឲ្យជំនឿរបស់គេចម្រើនឡើងយ៉ាងល្អប្រសើរ។ ជម្រើសបម្រើសជនក្រីក្រលើសគេទាំងអស់ នាំឲ្យយើងចាប់អារម្មណ៍នឹងគេខាងផ្លូវ សាសនាទុកជាអាទិភាពយ៉ាងពិសេស។

ប្រសិនបើព្រះសហគមន៍របស់យើងទៅជាក្រុមគ្រួសាររបស់គេ ទៅជាផ្ទះរបស់គេ ណែនាំឲ្យគេមានអំណរសប្បាយ នោះយើងពិតជានៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ពិតមែន។ សម្ដេចប៉ាបមានប្រសាសន៍ថា៖ " ខ្ញុំសូមនិយាយទាំងព្រួយថា អ្នកក្រីក្រកើតទុក្ខដោយសារយើងប្រកាន់គេ មិនចាប់អារម្មណ៍នឹងគេខាងវិញ្ញាណ..." នៅពេលណាគេស្រេកទឹក មិនមែនគេស្រេកទឹកធម្មតានោះទេ តែគេស្រេកទឹកដែលមកពីព្រះជាម្ចាស់ ដែលជាទឹកខាងសីលធម៌ ជាទឹកខាងសម្ភារៈ និងជាទឹកខាងវិញ្ញាណដែរ។

ដូច្នេះការអភិវឌ្ឍពិតៗ មិនមែនការអភិវឌ្ឍតាមរយៈធ្វើផ្លូវ ធ្វើស្ពាន ប៉ុន្តែការអភិវឌ្ឍខាងចិត្តគំនិត ដែលយើងធ្វើអ្វីៗទាំងអស់ ដោយរួមជាមួយព្រះជាម្ចាស់ និងដើម្បីព្រះជាម្ចាស់។

# IV. " មេត្តាករុណា "

## លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨២២. សេចក្តីស្រលាញ់ជាគុណធម៌ដែលជាព្រះអំណោយទាន។ ដោយសារសេចក្តីស្រលាញ់យើង ស្រលាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ ដើម្បីព្រះអង្គផ្ទាល់ហើយយើងស្រលាញ់អ្នកដទៃដូចខ្លួនឯង ដោយសារសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់។

ពេលនេះយើងនិយាយអំពី ធម៌មេត្តករុណា យើងគិតជ្រៅអំពីមេត្តាករុណា អត្ថបទចេញពីសៀវភៅអប់រំលទ្ធិកាតូលិក ទាក់ទងនឹងមេត្តាករុណា " សេចក្តីស្រលាញ់ជាគុណធម៌ដែលជាព្រះអំណោយទាន។ ដោយសារសេចក្តីស្រលាញ់ យើងស្រលាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ ដើម្បីព្រះអង្គផ្ទាល់ ហើយយើងស្រលាញ់អ្នកដទៃ ដូចខ្លួនឯង ដោយសារសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ "។

មានចំណុចមួយចំនួន ដើម្បីចូលយ៉ាងជ្រៅក្នុងជីវិត របស់យើងជាគ្រីស្តបរិស័ទ៖

សេចក្តីស្រលាញ់ ជាគុណធម៌ដែលជាព្រះអំណោយទាន ដោយហេតុនេះ នៅពេលដែលយើងទទួលពាក្យនេះ យើងយល់ថាសេចក្តីស្រលាញ់មិនមែនអ្វីដែលកើតចេញពីខ្លួនឯងកើតចេញពីអារម្មណ៍ ឬនិស្ស័យរបស់អ្នកឡើយ។ តែអ្វីដែលធ្វើអោយយើងចូលយ៉ាងជ្រៅនៅពេលយើងនិយាយសេចក្តីស្រលាញ់សម្រាប់យើងដែលជាគ្រីស្តបរិស័ទគឺ ចំណុចទីមួយមុនគេបង្អស់គឺជា អំណោយទាន គឺជាការជូដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។ សេចក្តីស្រលាញ់មិនមែនអ្វីដែលយើងបង្កើតខ្លួនឯងនៅក្នុងចិត្តរបស់ខ្ញុំ តែវាជាអំណោយទានដែលខ្ញុំទទួលពីព្រះជាម្ចាស់។ នៅក្នុងសាសនាយើង ពេលយើងនិយាយអំពីសេចក្តីស្រលាញ់ មិនមែននិយាយតែរឿងអារម្មណ៍ឬនិស្ស័យតែប៉ុណ្ណឹង តែសេចក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់។ សេចក្តីស្រលាញ់ណែនាំអោយខ្ញុំ ទីមួយស្រលាញ់ព្រះជាម្ចាស់ និងទីពីរស្រលាញ់អ្នកដទៃ។ ចំណុចទីមួយដែលយើងត្រូវរិះគិតរួមគ្នានិងអរព្រះគុណព្រះជាម្ចាស់គ្រប់ពេលវេលា នោះគឺសេចក្តីស្រលាញ់មិនមែនសេចក្តីស្រលាញ់ដែលខ្ញុំបង្កើតផ្ទាល់ខ្លួន ប៉ុន្តែជាការជូមួយយ៉ាងពិសេស ជាអំណោយទានយ៉ាងពិសេសដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់។ ហេតុដូចនេះពេលព្រឹកមុនធ្វើអ្វីៗទាំងអស់ កុំភ្លេចជម្រាបសួរព្រះជាម្ចាស់ និងអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានសេចក្តីស្រលាញ់អោយយើងសម្រាប់ពេញមួយថ្ងៃ។

## លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨២៣. ព្រះយេស៊ូបានធ្វើអោយសេចក្តីស្រលាញ់ទៅជាវិន័យថ្មី (យហ ១៣,៣៤)។ ដោយស្រលាញ់ មិត្តសម្លាញ់របស់ព្រះអង្គ " រហូតដល់ទីបំផុត" (យហ ១៣,១) ព្រះអង្គក៏សម្តែងសេចក្តីស្រលាញ់របស់ព្រះបិតា ដែលព្រះអង្គទទួល។ ដោយស្រលាញ់គ្នាទៅវិញទៅមក សាវ័កយកតម្រាប់តាមសេចក្តីស្រលាញ់របស់ព្រះយេស៊ូ ដែលពួកគេទទួលទុកក្នុងខ្លួន។ ហេតុនេះហើយ បានជាព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។ចូរទុកសេចក្តីស្រឡាញ់របស់ខ្ញុំអោយស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ"(យហ ១៥,៩) ឬ៖ " វិន័យរបស់ខ្ញុំមានដូចតទៅនេះ គឺអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" (យហ ១៥,១២)។

នេះណែនាំអោយយើងបង្កើតទំនាក់ទំនងនៅក្នុងរបៀបថ្មី គឺក្នុងអត្ថបទមួយបានសរសេរថា៖ ព្រះយេស៊ូបានធ្វើអោយសេចក្តីស្រលាញ់ទៅជាវិន័យថ្មី(យហ ១៣,៣៤)។ ដោយស្រលាញ់មិត្តសម្លាញ់របស់ព្រះអង្គ " រហូតដល់ទីបំផុត " (យហ ១៣,១) ព្រះអង្គបានសម្តែងសេចក្តីស្រលាញ់របស់ព្រះបិតាដែលព្រះអង្គទទួល ដោយស្រលាញ់គ្នាទៅវិញទៅមក ហើយសាវ័កយកដម្រាប់តាមសេចក្តីស្រលាញ់របស់ព្រះយេស៊ូ ដែលពួកគេទទួលមកទុកក្នុងខ្លួន។ហេតុនេះហើយបានជាព្រះយេស៊ូមានព្រះបន្ទូលថា៖ខ្ញុំស្រលាញ់អ្នករាល់គ្នាដូចព្រះបិតាស្រលាញ់ខ្ញុំដែរ ចូរទុកសេចក្តីស្រលាញ់របស់ខ្ញុំអោយស្ថិតនៅជាប់និងអ្នករាល់គ្នាចុះ(យហ ១៥,៩) ។វិន័យរបស់ខ្ញុំមានដូចតទៅ៖គឺអ្នករាល់គ្នាត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ(យហ ១៥,១២) ។

សេចក្តីស្រលាញ់គឺជាអំណោយទានយ៉ាងពិសេស ដែលយើងបានទទួលពីព្រះជាម្ចាស់ ហើយយើងត្រូវការអរព្រះគុណព្រះអង្គរាល់ថ្ងៃ។ តែសេចក្តីស្រលាញ់ដែលខ្ញុំបានទទួលមិនមែនគ្រាន់តែជាទ្រឹស្តស្តីមួយប៉ុណ្ណោះទេ ប៉ុន្តែយើងទទួលដោយមើលឃើញព្រះយេស៊ូសិន។ ខ្ញុំទទួលសេចក្តីស្រលាញ់ ដោយមើលឃើញពីរបៀបដែលព្រះយេស៊ូស្រលាញ់ របៀបដែលព្រះយេស៊ូស្រលាញ់ គឺជាសេចក្តីស្រលាញ់ដែលព្រះយេស៊ូទទួលផ្ទាល់ពីព្រះបិតា។ ហេតុនេះហើយបង្ហាញអោយយើងឃើញថា របៀបដែលយើងស្រលាញ់គឺជារបៀបដែលយើងទទួលពីព្រះបិតារួចស្រាប់ហើយ។ ប្រហែលវាជាការឃោសនាអប់រំឬទស្សនៈពិសេស ដែលយើងពិបាកយល់ តែយើងបានយល់ច្បាស់ដោយសារយើងមានព្រះយេស៊ូ តើជាសេចក្តីស្រលាញ់របៀបណា? គឺជាសេចក្តីស្រលាញ់របៀបព្រះយេស៊ូ។ ដើម្បីទទួលសេចក្តីស្រលាញ់ពីព្រះជា

ម្ចាស់ យើងត្រូវស្រលាញ់ព្រះយេស៊ូ ប្រសិនបើយើងមិនស្រលាញ់ព្រះយេស៊ូ យើងមិនអាចស្រលាញ់អ្នកដទៃបានទេ។ យើងត្រូវការទទួលវិន័យរបស់ព្រះយេស៊ូថ្មីគឺ៖

ទីមួយ៖ ស្រលាញ់ព្រះបិតាអោយអស់ពីកម្លាំងកាយ កម្លាំងចិត្តប្រាជ្ញានិងស្មារតី

ទីពីរ៖ ត្រូវស្រលាញ់អ្នកដទៃអោយដូច ស្រលាញ់ខ្លួនឯង នេះគឺជាធម្មវិន័យថ្មីរបស់ព្រះយេស៊ូ។ដោយសារតែព្រះយេស៊ូរំលឹកអំពីសម្ព័ន្ធមេត្រីចាស់ តែជាមួយព្រះយេស៊ូយើងចូលក្នុងសម្ព័ន្ធមេត្រីថ្មីវិន័យថ្មីគឺ៖ អ្នករាល់គ្នាត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ។ ដូច្នេះយើងលែងមើលឃើញយើងផ្ទាល់ខ្លួន តែយើងមើលឃើញព្រះយេស៊ូ។

## លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨២៥ . ព្រះគ្រីស្តបានសោយទិវង្គត ដោយសារសេចក្តីស្រលាញ់របស់ព្រះអង្គចំពោះយើងក្នុងគ្រាដែលយើងនៅជា"សត្រូវ"របស់ព្រះអង្គនៅឡើយ(រម៥,១០)។ព្រះអម្ចាស់សូមយើងអោយស្រលាញ់ដូចព្រះអង្គ រហូតដល់ស្រលាញ់ខ្មាំងសត្រូវរបស់យើង (មថ ៥,៤៤) អោយយើងទៅជាបងប្អូនរបស់អ្នកដទៃ(លក ១០,២៧-៣៧) ស្រលាញ់កូនក្មេង (មក ៩,៣៧) និងជនក្រីក្រដូចព្រះអង្គផ្ទាល់ (មថ ២៥,៤០.៤៥)។ គ្រីស្តទូតប៉ូលរៀបរាប់អំពីសេចក្តីស្រលាញ់យ៉ាងអស្ចារ្យ៖ "អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួតអាងឡើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនគ្រប់កាលៈទេសៈ ជឿគ្រប់កាលៈទេសៈ សង្ឃឹមគ្រប់កាលៈទេសៈ ហើយទ្រាំទ្រគ្រប់កាលៈទេសៈ" (១ករ ១៣,៤-៧)។

ពាក្យ(ដូច)ជាពាក្យតូចមួយ តែធ្វើអោយមានអត្ថន័យថ្មីមែនទែន ហេតុនេះសូមសូមគូសចំណាំពាក្យនេះ ដើម្បីអោយពាក្យដូចនេះណែនាំយើងអោយយល់ថា ពេលខ្ញុំស្រលាញ់ខ្ញុំត្រូវការមើលរបៀបព្រះយេស៊ូ ។ ១៨២៥ ព្រះយេស៊ូបានសោយទិវង្គត់ ដោយសារសេចក្តីស្រលាញ់របស់ព្រះអង្គចំពោះយើង ក្នុងគ្រាដែលយើងនៅជាសត្រូវរបស់ព្រះអង្គនៅឡើយ(រម ៥,១០)។ ព្រះអម្ចាស់ សូមយើងអោយស្រលាញ់ ដូចព្រះអង្គរហូតដល់ស្រលាញ់ខ្មាំងសត្រូវរបស់យើង (មថ ៥,៤៤) អោយយើងទៅជាបងប្អូនរបស់អ្នកដទៃ(លក ១០,២៧-៣៧)។

ហេតុនេះសូមយើងយល់ពីសេចក្តីស្រលាញ់របស់ព្រះយេស៊ូ។ អ្វីដែលចេញពីធម្មជាតិរបស់យើង គឺពេលចាប់អារម្មណ៍និងអ្នកណាយើងស្រលាញ់អ្នកនោះ ឬចូលចិត្តអ្នកណាយើងស្រលាញ់អ្នកនោះ។ តែជាមួយព្រះយេស៊ូ យើងត្រូវតែឈ្នះអ្វីដែលមកពីធម្មជាតិរបស់យើង ដើម្បីអោយសេចក្តីស្រលាញ់របស់យើង ទៅជាសេចក្តីស្រលាញ់យ៉ាងទូលំទូលាយ ហើយណែនាំអោយយើងស្រលាញ់ខ្មាំងសត្រូវ។ ព្រោះថាធម្មជាតិរបស់យើង មិនដែលស្រលាញ់សត្រូវនោះទេ ហេតុនេះសូមយើងបិទភ្នែកហើយរលឹកមើលថា តើយើងមានខ្មាំងសត្រូវដែររឺទេ? ហើយសូមគិតថា តើខ្ញុំមានសមត្ថភាពស្រលាញ់សត្រូវរបស់ខ្ញុំដែររឺទេ? គឺចំពោះមនុស្សដែលធ្វើអោយយើងឈឺចាប់ ជិះជាន់សង្កត់សង្កិន និងមនុស្សដែលធ្វើអោយយើងអស់សង្ឃឹម ក៏ដូចជាកត្តាផ្សេងៗទៀត តើយើងមានសមត្ថភាពស្រលាញ់គាត់ដែរឬទេ? អ្វីទាំងនេះគឺប្រហែលជាតាមនិស្ស័យផ្ទាល់ខ្លួនមិនបាន តាមអារម្មណ៍មិនបាន តែតាមអំណោយទានរបស់ព្រះជាម្ចាស់គឺពិតជាបាន។ ដោយសារសេចក្តីស្រលាញ់ដែលមកពីព្រះជាម្ចាស់ យើងមានសមត្ថភាពដើម្បីស្រលាញ់ខ្មាំងសត្រូវ ហេតុដូចនេះយើងនិងឡើងដល់កំពូល ចំពោះអំណោយទានដែលមកពីព្រះជាម្ចាស់។ តែយើងធ្វើយ៉ាងណាដើម្បីដល់កំពូល គឺយើងមើលព្រះយេស៊ូរបៀបដែលព្រះយេស៊ូស្រលាញ់ ឆ្លុះក្នុងរូបភាពនៃមេត្តាករុណា គឺព្រះយេស៊ូសម្រើដោយលាងជើងអោយសាវ័គ្គ និងរូបមួយទៀតគឺព្រះយេស៊ូបានជួយលាងរបួសដល់អ្នកដំណើរ។ នេះបញ្ជាក់ថាព្រះយេស៊ូបម្រើដោយសេចក្តីស្រលាញ់ ហើយសេចក្តីសេចក្តីស្រលាញ់នេះ គឺជាសេចក្តីស្រលាញ់ដែលទូលំទូលាយយ៉ាងកំពូល ដោយសារណែនាំអោយយើងត្រូវតែស្រលាញ់ មិនមែនស្រលាញ់តែមិត្តសំលាញ់របស់យើង បងប្អូនរបស់យើងតែយើងក៏ត្រូវតែស្រលាញ់សត្រូវ និងស្រលាញ់មនុសដែលយើងមិនស្គាល់។ ជាហេតុយើងអធិដ្ឋានរាល់ពេលព្រឹក ដើម្បីជម្រាបសួរព្រះជាម្ចាស់ហើយ ដើម្បីយើងសូមអំណោយទានថែមទៀតអំពីសេចក្តីស្រលាញ់។ យើងត្រូវការទទួលនូវនៅក្នុងការអធិដ្ឋានរបស់យើង សម្រាប់មនុស្សទាំងអស់នៅក្នុងពិភពលោកទាំងមូលទោះបីយើងមិនស្គាល់។ បន្ទាប់មកទៀតយើងនឹកឃើញខ្មាំងសត្រូវរបស់យើងមានប៉ុន្មានដើម្បីអោយយើងសូមព្រះជាម្ចាស់ធ្វើដូចម្តេចអោយយើងចេះស្រលាញ់ខ្មាំងសត្រូវរបស់យើង នៅក្នុងសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ មិនមែននៅក្នុងអារម្មណ៍របស់យើងផ្ទាល់ដែលមកពីធម្មជាតិរបស់យើង ណែនាំអោយយើងស្អប់ខ្មាំងសត្រូវរបស់ខ្លួន។

គ្រីស្តទូតប៉ូលបានរៀបរាប់អំពីសេចក្តីស្រលាញ់យ៉ាងអស្ចារ្យគឺ៖ អ្នកមានសេចក្តីស្រលាញ់តែងតែមានចិត្តអត់ធ្មត់ ជួយយកធុរៈអ្នកគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រលាញ់ មិនវាយឫកខ្ពស់ មិនអួតអាងឡើយ។ អ្នកមានចិត្តស្រលាញ់ មិនប្រព្រឹត្តិអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនម្ងម៉ៅ មិនចងគំនុំ មិនអបអរនិងអំពើរទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រលាញ់ អត់ឱនគ្រប់កាលៈទេសៈ ជឿគ្រប់កាលៈទេសៈ សង្ឃឹមគ្រប់កាលៈទេសៈ ហើយគាំទ្រគ្រប់កាលៈទេសៈ(១ករ ១៣,៤-៧)។

អត្ថបទនេះយើងត្រូវតែអានម្តងហើយម្តងទៀត ដើម្បីអោយចូលជ្រៅនៅក្នុងចិត្តយើង។ ព្រោះថាអ្វីទាំងនេះគឺយើងនិយាយស្រួល តែពេលយកមកអនុវត្តន៍ គឺពិតជាពិបាក ហេតុនេះ យើងត្រូវការកែប្រែក្នុងដួងចិត្តរបស់យើង កែប្រែធម្មជាតិរបស់យើង។ ព្រោះធម្មជាតិរបស់យើងគឺណែនាំអោយយើងចង្អៀតចង្អល់គិតអំពីសេចក្តីសុខផ្ទាល់ខ្លួនធម្មជាតិរបស់យើងណែនាំអោយយើង ស្រលាញ់តែមិត្តសំលាញ់របស់យើង។ ដូចព្រះយេស៊ូធ្លាប់មានព្រះបន្ទូលថា៖ ប្រសិនបើយើងគ្រាន់តែជប់លាងជាមួយមិត្តសំលាញ់របស់យើង ហើយអញ្ជើញតែមិត្តសំលាញ់របស់យើងមានប្រយោជន៍អ្វី? តែយើងត្រូវការអញ្ជើញអ្នកដែលយើងមិនស្រលាញ់។

ធម្មជាតិរបស់យើងណែនាំអោយយើងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ហើយពេលខ្លះ យើងក៏គិតដល់គ្រួសាររបស់យើងដែរ។ ចំពោះសេចក្តីស្រលាញ់ ដែលជាអំណោយទានមកពីព្រះជាម្ចាស់ ដើម្បីអោយយើងកែប្រែសេចក្តីស្រលាញ់ដែលមកពីធម្មជាតិ ដើម្បីកែប្រែរបៀបធម្មតារបស់យើង ដែលយើងធ្វើជាប្រចាំ។ ហើយនេះជាអ្វីដែលយើងទទួលពីព្រះជាម្ចាស់ ហើយយើងក៏ត្រូវតែស្តាប់និងពិនិត្យមើលថា តើខ្ញុំមានចិត្តអត់ធ្មត់ឬអត់? តើខ្ញុំសប្បាយចិត្តពេលខ្ញុំធ្វើខុសរឺអត់? តើខ្ញុំសប្បាយចិត្តពេលគេពិបាករឺអត់? ប្រសិនបើយើងសប្បាយចិត្តនោះ គឺមានន័យថាយើងមិនទាន់កែប្រែនោះទេ។ តើខ្ញុំស្បាយចិត្តនៅពេលអ្នកដទៃរីកចម្រើន? ប្រសិនបើអត់នោះ មានន័យថាយើងមិនទាន់ធ្វើតាមព្រះយេស៊ូនោះទេ។ តើខ្ញុំមានសេចក្តីសង្ឃឹមគ្រប់ពេលវេលារឺអត់? តើខ្ញុំមានជំនឿគ្រប់ពេលវេលាលើព្រះជាម្ចាស់ រឺអត់? សំនួរ ទាំងនេះយើងត្រូវការមើលវាជារៀងរាល់ថ្ងៃ ទោះបីជាក្មេងឬចាស់ក៏ដោយ។ ដោយសារតែជីវិតរបស់ យើងគឺជាផ្លូវមួយ ដែលយើងធ្វើដំណើរយើងធ្វើដំណើរជាមួយព្រះយេស៊ូ ហើយដំណើរជីវិតរបស់យើងប្រៀបដូចជាផ្លូវ ដែលយើងបានធ្វើដំណើររួមគ្នាជាដំណើរបូជនីចរណ៍ មានទាំងក្តៅ ហត់អស់កម្លាំង ផ្លូវពិបាក ជាហូហែរ តែអ្វីទាំងនេះល្អដើម្បីធ្វើអោយយើងយល់អំពីផ្លូវជីវិតរបស់យើង។ ផ្លូវជីវិតរបស់យើង គឺមិនមែនជាផ្លូវដែលស្អាតនោះទេ គឺផ្លូវជីវិតរបស់យើងពេលខ្លះមានថ្មមានភក់ មានគ្រលុក មានស្ពាន តែពេលខ្លះក៏មានកន្លែង

ល្អខ្លះដែរ ពេលយើងធ្វើដំណើរពេលខ្លះធ្វើអោយយើងដួល ហើយផ្លូវនោះហើយប្រៀបបីដូចជាជីវិតរបស់យើងសព្វថ្ងៃ។ ហើយយើងត្រូវដឹងថា ផ្លូវលំបាកទាំងនោះ គឺប្រៀបដូចជាផ្លូវជីវិតរបស់យើងមែន តែផ្លូវជីវិតដែលព្រះជាម្ចាស់គង់នៅ។ ព្រះជាម្ចាស់គង់នៅគ្រប់ពេលវេលាផ្លូវកាន់តែពិបាកខ្លាំង គឺព្រះជាម្ចាស់គង់នៅទីនោះ ដោយហេតុនេះសូមអោយយើងជឿនិងមានជំនឿ លើព្រះជាម្ចាស់គ្រប់កាលៈទេសៈ ទោះបីជាពេលលំបាក សប្បាយ ស្រួល អំណរ សូមអោយ យើងជឿថាព្រះជាម្ចាស់គង់នៅ។ នៅពេលដែលយើងដើរធ្វើអោយឆ្លងកាត់នូវការលំបាកខ្លះនិងស្រួលខ្លះនៅតាមផ្លូវរហូតដល់ទិសដៅដែលយើងតម្រង់មកទៅ។នៅពេលដែលយើងដើរដល់ទិសដៅដូចជាយើងមកដល់ព្រះសហគមន៍កាតូលិកកំពង់គោនោះ គឺជាការជំនះពីធម្មជាតិរបស់យើងហើយព្រោះថា ធម្មជាតិរបស់យើងគឺចង់បានអ្វីដែលស្រួល។ ជីវិតរបស់យើងគឺជាការតស៊ូដើម្បីឈ្នះអ្វីដែលមកពីធម្មជាតិរបស់យើង នៅពេលដែលយើងទទួលបានជោគជ័យហើយគឺយើងពិតជាសប្បាយរីករាយណាស់ ព្រោះយើងដឹងថាជាបទពិសោធន៍មួយយ៉ាងពិសេសដែលព្រះជាម្ចាស់គង់នៅជាមួយយើង។

## លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨២៦ .គ្រីស្តទូតប៉ូលបន្ថែមទៀតថា៖ "បើសិនជាខ្ញុំគ្មានសេចក្តីស្រលាញ់ទេ ខ្ញុំជាមនុស្សឥតបានការអ្វីទាំងអស់ " ហើយទោះបីខ្ញុំមានព្រះអំណោយទានពិសេស ចេះបម្រើគេ ទោះបីខ្ញុំមានគុណធម៌..." បើសិនជាខ្ញុំ គ្មានសេចក្តីស្រលាញ់ទេនោះ ក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ " ( ១ករ ១៣,១-៤ ) ។ សេចក្តីស្រលាញ់ជាគុណធម៌ ដ៏ប្រសើរលើស គុណធម៌ឯទៀតៗទាំងអស់ ។សេចក្តីស្រលាញ់ជាគុណធម៌ទីមួយនៃគុណធម៌ដែលមកពីព្រះជាម្ចាស់៖"ឥឡូវនេះមានគុណធម៌បីយ៉ាងស្ថិតនៅ គឺជំនឿ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់។ ប៉ុន្តែក្នុងចំណោមគុណធម៌បីយ៉ាងនោះ មានតែសេចក្តីស្រឡាញ់ទេ ដែលប្រសើរជាងគេបំផុត" ( ១ករ១៣,១៣ ) ។

នៅពេលនេះសូមយើងគិតថាវាជាបទពិសោធន៍ ដែលព្រះជាម្ចាស់គង់នៅជាមួយយើងនិងធ្វើដំណើរជាមួយយើង។ យើងត្រូវគិតទៅលើលិខិតរបស់គ្រីស្តទូតប៉ូល នៅចំណុចមួយថា៖ បើសិនបើខ្ញុំគ្មានសេចក្តីស្រលាញ់ទេ ខ្ញុំជាមនុស្សឥតបានការអ្វីទាំងអស់ ហើយទោះបីខ្ញុំមានព្រះអំណោយទានពិសេស ចេះបម្រើគេ ទោះបីខ្ញុំមានគុណធម៌ បើសិនជាខ្ញុំគ្មានសេចក្តីស្រលាញ់ទេនោះ ក៏គ្មានប្រយោជន៍ អ្វីដល់ខ្ញុំដែរ( ១ករ១៣,១-៤ ) ។

សេចក្តីស្រលាញ់ ជាគុណធម៌ដ៏ប្រសើរលើសគុណធម៌ឯទៀតៗទាំងអស់ សេចក្តីស្រលាញ់ជាគុណធម៌ទីមួយនៃគុណធម៌ដែលមកពីព្រះជាម្ចាស់។ ឥលូវនេះ យើងបានរិះគិតកន្លងមក នៅពេលធ្វើដំណើរអំពីគុណធម៌ដ៏កំពូល គឺធម៌មេត្តាករុណា បន្ទាប់មកទៀតយើងបានរិះគិតទៅលើគុណធម៌ទាំងបួនគឺការប្រុងប្រយ័ត្នសុច្ចរិតចិត្តក្លាហាននិងការចេះទប់ចិត្ត។

ដកស្រង់ចេញពីអត្ថបទពីមហាសន្និបាតវ៉ាទីកង់ទីពីរនៅត្រង់ចំណុចមួយ ដែលមានចំណងជើងថា ព្រះសហគមន៍ជាពន្លឺនៃមនុស្សលោក។ បាននិយាយថា៖ ធ្វើដូចម្តេចដើម្បីអោយសេចក្តីស្រលាញ់ដែលខ្ញុំបានលើកឡើងពីខាងដើម យើងអាចទទួលនៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ? ហើយនៅក្នុងនោះក៏មានចំណុចសំខាន់មួយឃ្លាដែរយើងត្រូវចងចាំជានិច្ចគឺ៖ គេក៏ត្រូវទទួលអគ្គសញ្ញាជាញឹកញាប់ ជាពិសេសរួមក្នុងអគ្គសញ្ញាអរព្រះគុណ និងពិធីគោរពប្រណិប័តនានាដើម្បីគោរពបម្រើព្រះអង្គ គេត្រូវយកចិត្តទុកដាក់និងព្យាយាមអធិដ្ឋាន សុខចិត្តលះបង់ខ្លួនឯង បម្រើបងប្អូនយ៉ាងសកម្ម ព្រមទាំងប្រព្រឹត្តតាមព្រហ្មវិហារធម៌ទាំងប៉ុន្មានផង។ សូមយើងទទួល និងចងចាំក្នុងចិត្តរបស់យើងនូវចំណុចសំខាន់មួយចំនួនគឺ៖

ទី១៖ ចូលរួមអគ្គសញ្ញាអរព្រះគុណ នោះគឺពិធីអភិបូជាហេតុនេះយើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់ចូលរួមអភិបូជា ព្រមទាំងអគ្គសញ្ញានានាដើម្បីទទួលជីវិតពីព្រះជាម្ចាស់។ ដោយសារតែអារម្មណ៍ពីធម្មជាតិ គឺផ្ទុយពីអ្វីដែលមកពីព្រះជាម្ចាស់មាន ហេតុនេះយើងត្រូវការទទួលកម្លាំងពីព្រះជាម្ចាស់។ កម្លាំងនេះមកពីអគ្គសញ្ញានានា ព្រោះថាគ្រប់ពេលវេលាដែលយើងរួលរួមអភិបូជាណែនាំអោយយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលណែនាំអោយយើងស្គាល់ព្រះយេស៊ូថែមទៀត ពេលយើងទទួលព្រះកាយព្រះគ្រីស្តណែនាំអោយយើងទៅជារូបកាយតែមួយរួមជាមួយព្រះជាម្ចាស់។

ទី២៖គឺអោយយើងយកចិត្តទុកដាក់និងព្យាយាមអធិដ្ឋាន ដើម្បីជំរាបសួរព្រះជាម្ចាស់ និងអរព្រះគុណព្រះអង្គ សម្រាប់អ្វីៗគ្រប់យ៉ាង។

ទី៣៖ លះបង់ខ្លួនឯង ជាចំណុចដែលនិយាយអំពីសន្តប៉ូល ប្រសិនបើយើងមិនសុខចិត្តលះបង់ចោលខ្លះៗ តស៊ូ ចិត្តអត់ធ្មត់ នោះយើងមិនអាចទៅរួចបានទេ។ ព្រោះថាការតស៊ូ គឺសំខាន់ណាស់សម្រាប់ជីវិតយើងម្នាក់ៗ តែយើងម្នាក់ៗបែរជាគិតថាការតស៊ូមិនសំខាន់សោះ ព្រោះយើងមិនចង់តស៊ូនៅក្នុងជីវិតយើងប៉ុន្មាននោះទេ។ ព្រោះតែសង្គមនាពេលបច្ចុប្បន្ននេះ មិនណែនាំអោយយើងតស៊ូអ្វីសោះ សង្គមបច្ចុប្បន្ននេះណែនាំអោយយើងតែទទួលនូវអ្វីដែល

ស្រួល ហេតុនេះសូមយើងព្យាយាមនិងតស៊ូនៅក្នុងជីវិតរបស់យើងជាប្រចាំ។ ចំពោះអ្នកដែលរកការងារសព្វថ្ងៃ យើងមិនចង់ចាប់ផ្តើមដោយប្រាក់ខែ១០០$ តែយើងចង់ចាប់ផ្តើមដោយប្រាក់ខែ៥០០$ ខុសហើយយើងកុំលោភលន់។ ដែលណែនាំអោយយើងមិនចេះតស៊ូ ជីវិតរបស់យើងដូចជណ្តើរយើងកុំទៅជាន់ទី១០ ដោយមិនឆ្លងកាត់ជាន់ទីមួយទីពីរទីបី។ ដោយលះបង់ចោល និងបម្រើបងប្អូនយ៉ាងសកម្ម ព្រមទាំងប្រព្រឹត្តតាមព្រហ្មវិហារធម៌ទាំងប៉ុន្មានផង។ប្រសិនបើយើងមិនបម្រើនិងយកចិត្តទុកដាក់ចំពោះអ្នកដទៃទេនោះជីវិតរបស់យើងមិនទៅមុខបានឡើយ ដើម្បីស្គាល់គុណធម៌ផ្សេងៗដែលព្រះសហគមន៍ណែនាំអោយយើងដើរតាមដើម្បីតស៊ូ និងដើម្បីរីកចម្រើននៅក្នុងជីវិតរបស់យើងផ្ទាល់។

# V. " គុណធម៌ទាំងបួន "

ទី១ យើងឃើញមានផ្លូវខ្លះមាន ដីខ្លះ ថ្មខ្លះ កៅស៊ូខ្លះ ដើម្បីអោយយើងដឹងថានេះជានិមត្តរូបនៃដំណើរជីវិតរបស់យើងម្នាក់ៗ។ ដូច្នេះ ធម៌មេត្តាករុណា គឺជាអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់ទីមួយ។ ទី២ ដើម្បីពន្យល់ពាក្យមេត្តាករុណា យើងត្រូវការមើលព្រះយេស៊ូផ្ទាល់ ដើម្បីអោយមេត្តាករុណា ដែលយើងកំពុងនិយាយទៅជាទ្រឹស្តីមួយ គំនិតមួយដ៏អស្ចារ្យ ប៉ុន្តែយើងមិនដឹងត្រូវអនុវត្តយ៉ាងមិច។ ដូច្នេះយើងត្រូវការ មើលព្រះយេស៊ូផ្ទាល់ជាព្រះយេស៊ូ ដែលជាគំនូរសំរាប់យើង ដោយសារព្រះយេស៊ូមានព្រះបន្ទូលថា សូមស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ។ មើលព្រះយេស៊ូផ្ទាល់ ដោយស្តាប់ព្រះគម្ពីរដំណឹងល្អ ដើម្បីស្តាប់រឿងដែលទាក់ទងនឹងព្រះយេស៊ូ។ ទីបី យើងត្រូវការអនុវត្តនៅក្នុងជីវិតដើម្បីទទួលសេចក្តីស្រលាញ់ដ៏ពេញលក្ខណៈ។ ដើម្បីទទួលបានសេចក្តីស្រលាញ់ដ៏ពេញលក្ខណៈ យើងមានមធ្យោបាយនានា គឺទីមួយចូលរួមយ៉ាងសកម្ម នៅក្នុងអគ្គសញ្ញានានា។ ទីពីរ គឺយើងត្រូវអធិដ្ឋាន ទីបីគឺលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន និង ទីបួនគឺបម្រើគេ ។ យើងចែកបួនគុណធម៌តូចសំខាន់ដែរ ដើម្បីជួយអោយជីវិតរបស់យើងរីកចម្រើន៖

ទីមួយមានការប្រុងប្រយ័ត្ន ទីពីរមានភាពសុចរិត ទីបីមានចិត្តក្លាហាន ទីបួនមានការចេះទប់ចិត្ត នេះគឺជាអ្វីដែលខ្ញុំចង់ពន្យល់ខ្លះៗ ជួយអោយយើងមានគំនិតថ្មីៗដើម្បីដឹកនាំជីវិតរបស់យើងជាប្រចាំ។

## ១ ការប្រុងប្រយ័ត្ន

### លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨០៦. អ្នកចេះរិះគិតពិចារណា រៀបចំប្រាជ្ញាអោយរិះគិតគ្រប់កាលទេសៈអំពីអ្វីដ៏ល្អយ៉ាងពិតប្រាកដ ហើយជ្រើសរើសមធ្យោបាយត្រឹមត្រូវ ដើម្បីបំពេញអ្វីដ៏ល្អនេះ។ "មនុស្សឆ្លាតមិនធ្វើអ្វីដោយឥតគិតពិចារណាឡើយ" (សុភ ១៤,១៥)។ "ត្រូវគិតអោយវែងឆ្ងាយ និងភ្ញាក់ស្មារតីឡើង ទើបអធិដ្ឋានកើត" (១ពត្រ ៤,៧)។ ក្រោយពីលោកអារីសតូត សន្តថូម៉ាសសរសេរថា៖ "អ្នកចេះរិះគិតពិចារណាចេះបំពេញកិច្ចការតាមវិន័យត្រឹមត្រូវ"។ មនុស្ស ចេះរិះគិតពិចារណាមិនអៀនបៀន មិនភ័យខ្លាច មិនប្រើកលល្បិច ឬមិនលាក់លៀម ឡើយ។ គេហៅ គុណធម៌នេះថា auriga virtutum៖ គុណធម៌នេះណែនាំគុណធម៌ផ្សេងៗទៀត ដោយប្រុងប្រយ័ត្ន។ មនុស្សដែលមិនថ្វេសប្រហែសវិនិច្ឆ័យ ក្រោយពីបានរិះគិតពិចារណា។ អ្នកចេះរិះគិតពិចារណាសម្រេច និងណែនាំអាក្បកិរិយារបស់ខ្លួនតាមការវិនិច្ឆ័យនេះ។ ដោយសារគុណធម៌នេះ យើងប្រតិបត្តិតាមគោលការណ៍សីលធម៌ ដោយគ្មានកំហុសចំពោះករណីពិសេស ហើយយើងលែងសង្ស័យអំពីអ្វីដ៏ល្អដែលត្រូវបំពេញ និងអ្វីដ៏អាក្រក់ដែល ត្រូវចៀសវាង។

ការប្រុងប្រយ័ត្នដោយគិតពិចារណា ពេលយើងទទួលអគ្គសញ្ញាលាបថ្វាស មុននឹងលោកអភិបាលដៅព្រះវិញ្ញាណដ៏វិសុទ្ធ ដោយមានពាក្យអធិដ្ឋានមួយនៅក្នុងពាក្យអធិដ្ឋាននេះ យើងថាព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំអោយយើងចេះគិតពិចារណាថា អ្វីដែលល្អនិងមិនល្អ។ អោយយើងចេះទទួលខុសត្រូវ អ្វីដែលល្អនិងអ្វីដែលមិនល្អ។ សម្រាប់ដឹកនាំជីវិតរបស់យើង មនុស្សយើងត្រូវគិតពិចារណាដោយប្រុងប្រយ័ត្ន អ្វីដែលល្អនិងមិនល្អ សម្រាប់ជីវិតរបស់យើង គ្រប់ពេលវេលាយើងត្រូវការសំរេចចិត្ត។ ដូចច្នេះ ពីមួយថ្ងៃទៅមួយថ្ងៃ យើងត្រូវការមានការសម្រេចចិត្តដោយប្រយ័ត្នផង ដើម្បីធ្វើការសម្រេចចិត្តតាមរបៀបត្រឹមត្រូវ។ នេះជាអ្វីដែលយើងត្រូវសុំពីព្រះជាម្ចាស់ និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបងប្អូនបានទទួលហើយជួយបំភ្លឺយើង។ គ្រប់ពេលវេលាមុនយើងសម្រេចចិត្ត យើងត្រូវការធ្វើប្រុងប្រយ័ត្នដើម្បីគិតពិចារណា តើខ្ញុំធ្វើល្អឬមិនល្អ? តើខ្ញុំធ្វើបានឬមិនបាន?។ នៅក្នុងព្រះគម្ពីរមានរឿងមួយដែរ មានម្នាក់ដែលចង់ទៅធ្វើសង្គ្រាម ប៉ុន្តែមុនទៅធ្វើសង្គ្រាម គាត់ភ្លេចរាប់ចំនួនកូនទាហានរបស់គាត់ តើមានល្មមឬអត់? ដូច្នេះ ពេលគាត់ចេញធ្វើសង្គ្រាម គេបំផ្លាញគាត់និងគេឈ្នះគាត់ ដោយសារគាត់មានទាហានតិចពេក។ គ្រប់សកម្មភាពដែលយើងត្រូវធ្វើ យើងត្រូវគិតគ្រប់ការសំរេចចិត្តរបស់យើង យើងត្រូវគិតពិចារណា តើយើងធ្វើល្អឬមិនល្អ?។ ដូចជាប្រលងបាក់ឌុបឆ្នាំនេះ ជាប់តិចណាស់ហើយវាក៏ជាលទ្ធផលនៃការសំរេចចិត្តដែរ អ្នកដែលធ្លាក់ច្រើនដូចនេះ ដោយសារប៉ុន្មានឆ្នាំកន្លងមកមិនបានយកចិត្តទុកដាក់រៀន។ មុនយើងសំរេចចិត្តយើងត្រូវប្រុងប្រយ័ត្នដោយការប្រុងប្រយ័ត្នដោយគិតពិចារណា។

## ២ សុចរិត

### លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨០៧ .អ្នកសុចរិត មានបំណងមោះមុតដ៏ស្ថិតស្ថេរ ដើម្បីថ្វាយទៅព្រះជាម្ចាស់ និងផ្តល់ដល់អ្នកដទៃ នូវអ្វីៗដែលត្រូវតែថ្វាយ និងផ្តល់អោយ។ គេហៅសេចក្តីសុចរិតចំពោះព្រះជាម្ចាស់ថាជា " គុណធម៌នៃសាសនា"។ ចំពោះមនុស្សវិញ សេចក្តីសុចរិតនាំអោយចេះគោរពសិទ្ធិ របស់មនុស្ស និងបង្កើតភាពសុខដុមក្នុងទំនាក់ទំនង រវាងគ្នានិងគ្នា ដែលលើកទឹកចិត្តអោយមានយុត្តិធម៌ចំពោះមនុស្ស និងចំពោះផលប្រយោជន៍រួម។ ក្នុងគម្ពីរដ៏វិសុទ្ធ អ្នកសុចរិតប្លែកពីគេ ព្រោះចិត្តគំនិត និងរបៀបរស់នៅរបស់គាត់ត្រឹមត្រូវ និងទៀងត្រង់ចំពោះអ្នកដទៃ។ " ពេលវិនិច្ឆ័យទោស កុំកាត់ក្តីដោយអយុត្តិធម៌ កុំរើសមុខនរណាអោយសោះ គឺកុំយោគយល់អ្នកតូច ឬ អ្នកធំ តែត្រូវវិនិច្ឆ័យអោយជនរួមជាតិរបស់អ្នក ដោយយុត្តិធម៌ " (លវ ១៩,១៥)។ "បងប្អូនដែលជាម្ចាស់ ចូរប្រព្រឹត្តអំពើណាដែលសុចរិត និងយុត្តិធម៌ដល់ទាសកររបស់ខ្លួនដោយដឹងថា បងប្អូនផ្ទាល់ ក៏មានម្ចាស់មួយព្រះអង្គនៅស្ថាន បរមសុខដែរ"(កូឡ ៤,១)។

សុច្ចរិត យើងស្គាល់មនុស្សសុច្ចរិតឬអត់? ព្រះយេស៊ូគឺជាអ្នកសុច្ចរិតដល់កំពូល។ ប៉ុន្តែយើងមាននៅក្នុងព្រះគម្ពីរ ពីរនាក់យ៉ាងតិចដែលយើងនឹកឃើញភ្លេច គឺមានលោកតាអាប្រាហាំ និងលោកយ៉ូសែប អ្នកទាំងពីរគឺជាមនុស្សសុច្ចរិត។ មនុស្សសុច្ចរិតមានន័យថា គឺជាមនុស្សមានចិត្តស្មោះ ទីមួយចំពោះព្រះជាម្ចាស់ និងទីពីរចំពោះអ្នកដទៃ។ ចំពោះ ព្រះជាម្ចាស់មានន័យថា ដោយគោរពព្រះជាម្ចាស់គ្រប់ពេលវេលា ដោយស្រលាញ់ព្រះជាម្ចាស់គ្រប់ពេលវេលា និងដោយយកព្រះជាម្ចាស់ធ្វើជាគោលដើម្បីដឹកនាំជីវិតរបស់យើង។ ទីពីរមនុស្សសុច្ចរិតគឺជាមនុស្សដែលគោរពសិទ្ធិរបស់អ្នកដទៃ ដោយគោរពថាមនុស្ស ទាំងអស់មានសិទ្ធិស្មើៗគ្នា និងមានតំលៃថ្លៃថ្នូរ នេះជារបៀបរបស់លោកតាអាប្រាំហាំ និងលោកយ៉ូសែប។ យើងចាំលោកយ៉ូសែបជាមនុស្សសុច្ចរិតហេតុនេះហើយគាត់ចង់លែងព្រះនាងម៉ារីដោយស្ងៀមស្ងាត់។ដោយសារគាត់ភ្ញាក់ ហេតុអ្វីបានជាព្រះនាងម៉ារីមានផ្ទៃពោះ? ដោយសារអ្នកទាំងពីរមិនទាន់បានរៀបការនឹងគ្នា គាត់មិនចង់អោយព្រះនាងម៉ារីខ្មាស់គេ គាត់ជាមនុស្សសុច្ចរិតហេតុនេះគាត់លែងព្រះនាងម៉ារីដោយស្ងាត់ៗ។ សុច្ចរិតមានន័យថា ចេះគោរពអ្នកដទៃនិងចេះគោរពព្រះជាម្ចាស់។ យើងត្រូវការគិត តើជីវិតរបស់យើង តើខ្ញុំសុច្ចរិតដល់ណា? តើខ្ញុំមានចិត្តស្មោះចំពោះព្រះជាម្ចាស់ឬទេ? តើខ្ញុំចេះគោរពមនុស្សទាំងអស់ឬទេ?

ដោយសារមនុស្សទាំងអស់មានតំលៃថ្លៃថ្នូរដូចៗគ្នា ព្រះជាម្ចាស់បានបង្កើតគេដូចព្រះជាម្ចាស់បានបង្កើតខ្ញុំ។ " ពេលវិនិច្ឆ័យទោស កុំកាត់ក្តីដោយអយុត្តិធម៌ កុំរើសមុខនរណាអោយសោះ គឺកុំយោគយល់អ្នកតូច ឬអ្នកធំ តែត្រូវវិនិច្ឆ័យអោយជនរួមជាតិរបស់អ្នក ដោយយុត្តិធម៌"។

យើងត្រូវយល់ថា មនុស្សទាំងអស់មានសេចក្តីថ្លៃថ្នូរតាមសមត្ថភាពរបស់គេ។អោយយើងទៅជាមនុស្សសុច្ចរិត ទៅជាមនុស្សដែលមានចិត្តស្មោះចំពោះព្រះជាម្ចាស់ និងមានចិត្តស្មោះចំពោះអ្នកដទៃ។ យើងមិនអាចមើលតែសំបកខាងក្រៅបានទេ យើងមិនអាចសំគាល់បានថាមនុស្សនោះល្អឬមិនល្អ។ មនុស្សនេះទុកចិត្ត មនុស្សនេះមិនទុកចិត្ត ប៉ុន្តែអត់ទាន់ស្គាល់គេទេ នេះអោយយើងប្រុងប្រយ័ត្នក្នុងការជ្រើសរើស។ ប៉ុន្តែផ្ទុយទៅវិញ អោយយើងនៅជាមួយគេទាំងអស់ដោយសេចក្តីសុច្ចរិតដោយទុកចិត្តគេដោយវិនិច្ឆ័យគេតាមសេចក្តីត្រឹមត្រូវតែម្តង។

# ៣ ចិត្តក្លាហាន

## លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក

១៨០៨. អ្នកមានចិត្តក្លហាន មានចិត្តមោះមុតដ៏ស្ថិតស្ថេរនៅតែទៅរកអ្វីដ៏ល្អ ទោះបីមានទុក្ខលំបាកយ៉ាង ណាក៏ដោយ។ សេចក្តីចិត្តក្លាហានពង្រឹងការសម្រេចចិត្តអោយតស៊ូប្រឆាំងនឹងការល្បួង និងពុះពារឧបសគ្គក្នុងការរស់នៅប្រកបដោយសីលធម៌។អ្នកមានចិត្តក្លាហានអាចជម្នះការភ័យខ្លាច សូម្បីតែសេចក្តីស្លាប់ ហើយអាច ប្រឈមមុខទល់នឹងសេចក្តីលំបាក និងការបៀតបៀនផងដែរ។ អ្នកមានចិត្តក្លាហានអាចលះបង់ និងបូជាជីវិត ដើម្បីមូលហេតុដ៏ត្រឹមត្រូវ។ " ព្រះអម្ចាស់ជាកម្លាំងរបស់ខ្ញុំ ខ្ញុំច្រៀងថ្វាយព្រះអង្គ ព្រះអង្គសង្គ្រោះខ្ញុំ" (ទន ១១៨,១៤)។ " អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរតាំងចិត្តក្លាហានឡើង! ខ្ញុំបានឈ្នះលោកនេះ" (យហ ១៦,៣៣)។

សេចក្តីស្រលាញ់ ដោយយើងខិតខំលះបង់ចោល ប្រសិនបើអត់មានចិត្តក្លាហាននេះ យើងតស៊ូមិនបានទេ។ ចិត្តក្លាហាន ដែលណែនាំអោយយើងមានចិត្តតស៊ូបាននៅក្នុងជីវិតរបស់យើង បើអត់ ការតស៊ូយើងអត់មានព្រំដែនឡើយ។ ដូចនេះ យើងត្រូវការមានការតស៊ូ មានការតស៊ូណែនាំអោយយើងគោរពព្រំដែន ព្រំដែនដែលសំខាន់បំផុតសំរាប់យើងជាគ្រីស្តបរិស័ទ គឺជាធម្មវិន័យ"ការស្រលាញ់គ្នាទៅវិញទៅមក"។ប្រសិនបើ យើងមិនយកព្រំដែននេះនៅក្នុងសេចក្តីស្រលាញ់ សេរីភាពរបស់យើងអត់មានន័យ។ មនុស្សទូទៅសេរីភាព គឺធ្វើតាមចិត្ត ប៉ុន្តែតាមពិតសម្រាប់យើងជាគ្រីស្តបរិស័ទ សេរីភាពមិនមែនជាការធ្វើតាមចិត្តទេ។ មុនយើងធ្វើតាមចិត្ត យើងត្រូវដាក់ព្រំដែនមួយយ៉ាងសំខាន់ គឺសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ។ ដូច្នេះ មុនខ្ញុំធ្វើអ្វីខ្លះខ្ញុំត្រូវការពិនិត្យមើល តើខ្ញុំស្រលាញ់គេឬខ្ញុំធ្វើបាបគេ? តើខ្ញុំមើលងាយគេឬ ខ្ញុំណែនាំអោយគេរីកចម្រើន? តើខ្ញុំណែនាំអោយគេមានជីវិតសុភមង្គល ឬណែនាំអោយគេអស់សង្ឃឹម? ហើយនេះជាព្រំដែនសំរាប់យើង។ ដូច្នេះ ការប្រសិនបើយើងអត់មានចិត្តក្លាហាន យើងភ្លេចខ្លួនហើយធ្វើតាមចិត្ត។ តែផ្ទុយទៅវិញ សេចក្តីក្លាហានដែលយើងសុំពីព្រះជាម្ចាស់ ជួយយើងដើម្បីអោយយើងតស៊ូនៅក្នុងជីវិត ដើម្បីអោយយើងចេះស្រលាញ់តាមរបៀបព្រះយេស៊ូយ៉ាងពិតប្រាកដ។

ដូចយើងច្រៀង ព្រះអម្ចាស់ជាកំលាំងរបស់ខ្ញុំ ខ្ញុំច្រៀងថ្វាយព្រះអង្គ ព្រះអង្គសង្គ្រោះខ្ញុំ នេះជាបទតេហ្សេមួយ។ អ្នកមានចិត្តក្លាហានអាចជម្នះការភ័យខ្លាច សូម្បីតែសេចក្តីស្លាប់ ហើយអាចប្រឈមមុខទល់នឹងសេចក្តីលំបាក និងការបៀតបៀនផងដែរ។

នេះជាសេចក្ដីក្លាហាន ពេលយើងនឹងឃើញជីវិតរបស់គ្រីស្ដបរិស័ទពីដើម នៅក្នុងប្រទេសកម្ពុជា នឹកឃើញដល់គ្រីស្ដបរិស័ទនៅសម័យប៉ុលពត គ្រីស្ដបរិស័ទយើងគេមានសេចក្ដីក្លាហាន ដូចជាលោកអភិបាលឆ្នាសាឡាស លោក អភិបាលទេព្វ អ៊ឹម លោកបូជាចារ្យផ្សេងៗ បងស្រីបងប្រុស គ្រីស្ដបរិស័ទដែលបានសុខចិត្តតស៊ូនៅក្នុងជំនឿរបស់ពួកគេ។ នៅសម័យនេះ យើងអត់ចេះតស៊ូប៉ុន្មានទេដោយសារ យើងមានសេរីភាពក្នុងការកាន់សាសនាតាមរៀងៗខ្លួន។ ប៉ុន្តែយើងត្រូវការតស៊ូ ដោយមានសេចក្ដីក្លាហាន បង្ហាញជំនឿរបស់យើង បង្ហាញស្រលាញ់ ដែលយើងមានចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ។ គ្រប់កន្លែងដែលយើងនៅ យើងជាសិស្សសាលា យើងជានិស្សិត ជាអ្នកធ្វើការ យើងត្រូវការបង្ហាញជំនឿរបស់យើង ដែលជាគ្រីស្ដបរិស័ទ។ យើងមិនជាមនុស្សដែលដើរតាមខ្យល់ទេ យើងត្រូវការធ្វើតាមខ្យល់ដែលមកពីព្រះជាម្ចាស់ គឺជាខ្យល់នៃសេចក្ដីក្លាហាន ដែលណែនាំអោយយើងសុខចិត្តបង្ហាញថាផ្លូវនេះមិនល្អ ផ្លូវនេះល្អ។ សម្រាប់យើងជាគ្រីស្ដបរិស័ទ គ្រប់ពេលវេលា គុណធម៌នីមួយៗវាជួយគ្នាទៅវិញទៅមក។ ទីមួយ គិតពិចារណាដោយប្រុងប្រយ័ត្ន ទីពីរ សុចរិត ទីបីសេចក្ដីក្លាហាន។ នេះជួយគ្នាទៅវិញទៅមក នៅក្នុងគ្រប់កាលៈទេសៈ នៃជីវិតរបស់យើង។ មួយថ្ងៃទៅមួយថ្ងៃ យើងធ្វើដូចម្ដេចដើម្បីយកព្រះយេស៊ូ ជាគំរូនៅក្នុងសេចក្ដីស្រលាញ់ និងហ៊ានបង្ហាញជំនឿរបស់យើង ដូចមរណសាក្សីរបស់យើងដែលបានសុខចិត្តស្លាប់។

## ៤ ការចេះទប់ចិត្ត

### លិទ្ធិនៃគ្រីស្ដសាសនាតាមព្រះហគមន៍កាតូលិក

១៨០៩. អ្នកចេះទប់ចិត្ត ចេះតមការសប្បាយ និងនាំអោយមានលំនឹងក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិនៃលោកនេះ។ គុណធម៌នេះ នាំអោយគេចេះគ្រប់គ្រងកិលេសតណ្ហា និងការប៉ងប្រាថ្នាដោយមានកំណត់ព្រំដែនតាមសេចក្ដីទៀងត្រង់។ អ្នកចេះទប់ចិត្តតម្រូវចិត្តថ្លើមទៅរកអ្វីដ៏ល្អនឹង និង "មិនបណ្ដោយតាមសន្ទុះចិត្តលោភលន់ និងតណ្ហាឡើយ" (បសរ ៥,២) (បសរ ៣៧,២៧-៣១)។ គម្ពីរសម្ពន្ធមេត្រីចាស់ឧស្សាហ៍សរសើរអ្នកចេះទប់ចិត្តថាៈ "មិនបណ្ដោយខ្លួនទៅតាមតណ្ហា ហើយមិនធ្វើតាមចិត្តប៉ងប្រាថ្នារបស់កូនឡើយ " (បសរ ១៨,៣០)។ ក្នុងសម្ពន្ធមេត្រីថ្មី គេហៅអ្នកចេះទប់ចិត្តនេះថាជា អ្នកមាន " ចិត្តធ្ងន់ " ចេះ " ស្ងប់ស្ងៀម "។ " ត្រូវរស់នៅក្នុងលោកនេះ ដោយមានចិត្តធ្ងន់ សុចរិត និងគោរពប្រណិប័តន៍ព្រះជាម្ចាស់ " (តទ ២,១២)។ យើងមានរបៀបរស់នៅត្រឹមត្រូវនៅពេលដែលយើងស្រលាញ់ព្រះជាម្ចាស់អស់ពីចិត្ត អស់ពីព្រលឹង និង ដោយប្រព្រឹត្តកិច្ចការទាំងអស់ចំពោះព្រះអង្គ។យើងថ្វាយទៅព្រះអង្គសេចក្ដីស្រលាញ់សុទ្ធសាធ (ដោយចេះស្ងប់ចិត្ត) ដែលគ្មានវេទនាអាចមករញ្ជួយ (ដែលមកពីចិត្តក្លាហាន) ដែលធ្វើតាមតែព្រះអង្គ (នេះគឺជាសេចក្ដីសុចរិត) ហើយដែលប្រុងស្មារតី កុំអោយចាញ់កលល្បិច និងភាពកុហកឡើយ (នេះគឺជាការចេះរិះគិតពិចារណា) (សន្តអូគូស្តាំង)។

យើងត្រូវរស់នៅក្នុងលោកនេះដោយមានចិត្តធូន់ ដោយមានចិត្តសុច្ចរិត និងមានចិត្តគោរពប្រតិបត្តិព្រះជាម្ចាស់។ នេះវាចូលនៅក្នុងការតស៊ូមួយទៀត គឺយើងត្រូវការជឿទប់ចិត្តអ្វីដែលយើងឃើញយើងមិនចង់បានភ្លាម។ យើងចេះទុបចិត្ត ដើម្បីអោយជីវិតរបស់យើងបំពេញគោលការណ៍ និងគោលដៅដែលយើងចង់បាន។ បងប្អូនជានិស្សិតនៅទីក្រុងភ្នំពេញ យើងដឹងហើយមានការល្បួងច្រើនណាស់ ដូច្នេះយើងត្រូវការនឹកថា ព្រះសហគមន៍ណែនាំអោយយើងចេះទប់ចិត្ត ដើម្បីយកតែសេចក្តីត្រូវការរបស់យើងពិតៗ។

យើងដឹងថា គុណធម៌បួនដែលចូលគ្នា មានការគិតពិចារណាប្រុងប្រយ័ត្ន សុចរិត សេចក្តីក្លាហាន ទប់ចិត្ត ទាំងបួនចូលគ្នា ដើម្បីអោយយើងទៅជាធម៌មេត្តាករុណាដល់កំពូល។ យើងត្រូវគិតពីសំនួរ តើខ្ញុំប្រើប្រាស់គុណធម៌ទាំងនេះក្នុងជីវិតប្រចាំថ្ងៃយ៉ាងដូចម្តេច?។

អត្តទស្សនៈរបស់យើង គឺមើលជីវិតរបស់ព្រះយេស៊ូហើយខិតខំធ្វើតាមព្រះយេស៊ូ ដោយសារនេះជាកំពូលនៃជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដើម្បីទៅជាសន្តសន្តិ។ ដោយដឹងថាសន្តសន្តិបុគ្គល មិនមែនតែអ្នកដែលមានឈ្មោះជាផ្លូវការ ដូចយើងបានទទួលឆ្នាំនេះសន្តយ៉ូហានប៉ូលទី២ សន្តយ៉ូហាន២៣ ប៉ុន្តែជាយើងដែលឥតមានឈ្មោះ ដែលបានតស៊ូនៅក្នុងធម៌មេត្តាករុណារបស់ព្រះអង្គ ដោយមានការប្រុងប្រយ័ត្ន មានចិត្តសុច្ចរិក មានចិត្តក្លាហាន និងការទប់ចិត្តតាមសមត្ថភាពយើងតាមសេចក្តីស្រលាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ ដើម្បីធ្វើជាសន្តសន្តិបុគ្គល។ កុំទន្ទឹងរងចាំទទួលរង្វាន់ពីលោកីយ៍ ប៉ុន្តែព្រះជាម្ចាស់ដឹងអំពីអ្វីដែលយើងគិតអ្វីដែលយើងបានធ្វើអស់ពីកម្លាំងកាយចិត្ត ដើម្បីស្រលាញ់ដូចព្រះយេស៊ូ។អាម៉ែន។

# VI. " មេត្តាករុណាក្នុងជីវិតរបស់ខ្ញុំ "

យើងនឹកឃើញដល់ព្រះយេស៊ូ ដែលបានលីឈើឆ្កាង និងព្រះយេស៊ូដែលណែនាំអោយយើងលីឈើឆ្កាងនៅក្នុងជីវិតរបស់យើង។ បទពិសោធន៍នៅក្នុងខ្លួនរបស់យើង មានឥទ្ធិពលនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ នៅក្នុងការអធិដ្ឋាន នៅក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ។ នៅឆ្នាំ១៩៥០ ដែលមានលោកបូជាចារ្យគាត់ឈ្មោះ លោកតាវ៉ាន់ណេ។ គាត់បានកើតនៅក្នុងឆ្នាំ១៩១៤ គាត់បានមកប្រទេសកម្ពុជា នៅឆ្នាំ១៩៤៦ ដោយធ្វើដំណើរតាមកប៉ាល់ទឹករយៈពេល១ខែជាង។ លោកអភិបាល អោយគាត់ទទួលព្រះសហគមន៍ព្រះមាតា ដែលនៅក្បែរនឹងផ្សារតូច នៅខាងជើងស្ពានជ្រោយចង្វារ មុនមកដល់ព្រះវិហារផ្សារតូចនៅខាងឆ្វេងដៃ មានមណ្ឌលសុខភាព ដែលនៅក្នុងមណ្ឌលសុខភាពនេះ គឺមានរ៉ូងភ្នំព្រះនាងម៉ារី ទីនោះគឺព្រះសហគមន៍ព្រះមាតា ដែលជាព្រះសហគមន៍ខ្មែរពីដើម។ ក្រោយមក លោកតាមកដល់កំពង់គោ សម័យនោះមានតែពីរបីគ្រួសារ និងគាត់ស្នាក់នៅទីក្រុងកំពង់ធំ និងមកម្តងៗនៅទីនេះ។ ១ឆ្នាំក្រោយមក គាត់បានសំរេចចិត្តគាត់នៅទីនេះតែម្តង គាត់បានស្នាក់នៅទីនេះជាមួយប្រជាជន។ គាត់បានចាប់ផ្តើមប្រកាសដំណឹងល្អ គាត់បានណែនាំកូនក្មេង មនុស្សចាស់ នៅទីនេះទាំងអស់អោយស្គាល់ព្រះយេស៊ូ។ នៅទីនេះបាន ណែនាំកូនចៅជំនាន់ក្រោយអោយស្គាល់ព្រះជាម្ចាស់និងបន្តិចម្តងៗក៏ចាប់ផ្តើមមានច្រើនគ្រួសារនៅទីនេះ។ លោកតាវ៉ាន់ណេ គាត់បានឃើញច្បាស់ នៅទីនេះពិបាករស់នៅ ដោយសារនៅសម័យនោះអត់មានផ្លូវកៅស៊ូទេ ហើយនៅទីនេះលិចទឹកដល់ព្រះវិហារនេះ ពួកគេបានជិះកាណូត ជិះទូក ដើម្បីមកព្រះវិហារ។ លោកតាបានជួយដល់ពួកគេ អោយធ្វើកសិកម្មយ៉ាងច្បាស់លាស់ ដោយបានជីកប្រឡាយ នៅឆ្នាំ១៩៥៣គាត់បានទិញត្រាក់ទ័រមួយដើម្បីជួយធ្វើស្រែ និងគាត់បានបង្រៀនធ្វើស្រែនៅពេលព្រឹក និងនៅពេលរសៀល គាត់បង្រៀនក្មេងៗអោយចេះបើកត្រាក់ទ័រ។ បន្តិចម្តងៗបងប្អូន បានរីកចម្រើនផ្នែកកសិកម្មនេះទាំងអស់។

នៅឆ្នាំ១៩៧៥ ចាប់ផ្តើមមានសង្គ្រាមមានសម័យប៉ុលពត សម័យលុនណុល គេបានយកគាត់ចេញពីទីនេះដើម្បីទៅភ្នំពេញវិញ។ នៅពេលនោះមានខ្មែរសេរីគេចាប់គាត់ និងគេកាត់ត្រចៀកគាត់ ក្រោយមកគេចាប់គាត់ឃុំប៉ុន្មានថ្ងៃនៅទីនេះដែរ ក្រោយមកគេបានដោះស្រាយ នឹងគេបានលែងគាត់ នេះបញ្ជាក់ថាគាត់មានជីវិតពិសេសភ្ជាប់ជាមួយប្រជាជននៅទីនោះ។ តាមពិតនៅទីនេះមានមរណៈសាក្សីដែរ ពីឆ្នាំ១៩៧៧ និង ១៩៧៨ មានគ្រីស្តបរិស័ទច្រើនដែលបានស្លាប់ជាច្រើននៅទីនេះ។

ដើម្បីបង្ហាញពីការតស៊ូរបស់យើង ការលះបង់របស់លោកតាវ៉ាន់ណៃណែនាំអោយមានផ្លែ។ ជីវិតលោកតាវ៉ាន់ណៃ គាត់នៅក្នុងជុំរុំ គាត់បានជួយប្រជាជនក្នុងជុំរុំនៅក្នុងប្រទេសថៃច្រើនណាស់។ រហូតនៅពេលគាត់ត្រលប់ មកវិញនៅឆ្នាំ១៩៩១ គាត់នៅកំពង់សោម និងគាត់បានណែនាំអោយបងប្អូនជាច្រើន អោយស្គាល់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ប៉ុន្តែនេះទាំងអស់ គាត់អាចធ្វើបានដោយសារអ្វី? ដោយសារគាត់លះបង់ចោលអ្វីៗទាំងអស់ គាត់តស៊ូ គាត់មិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន។ គាត់ថា គាត់នៅទីនេះសម្រាប់បងប្អូនខ្មែរ ជាច្រើនដែលព្រះជាម្ចាស់អោយគាត់គាត់បានបម្រើអស់ពីកំលាំងកាយកំលាំងចិត្ត។បងប្អូនដែលស្គាល់លោកតានៅទីនេះ ពួកគាត់ស្រលាញ់លោកតាដូចជាព្រះ។ នេះគឺជាលទ្ធផលនៃសេចក្តីស្រលាញ់ មេត្តាករុណាដែលគាត់មាន។

## ១ ផលផ្លែផ្កាពីមេត្តាករុណា

មេត្តាករុណានៅក្នុងជីវិតរបស់យើង មានផ្លែអ្វីខ្លះ? ប្រសិនបើឥតមានផ្លែ នោះមេត្តាករុណាគ្រាន់តែជាពាក្យដែលយើងនិយាយតែប៉ុណ្ណឹង។ ជាគំនិតដែលយើងមាន ជាពាក្យដែលយើងអប់រំគ្នាទៅវិញទៅមកអស្ចារ្យៗ ប៉ុន្តែយើងត្រូវការពិនិត្យមើល តើនៅក្នុងជីវិតរបស់យើង ធម៌មេត្តាករុណាដែលយើងទទួលពីព្រះជាម្ចាស់ ដោយយើងទទួលអគ្គសញ្ញា ដោយការអធិដ្ឋាន លះបង់ចោល បម្រើអ្នកដទៃ រស់នៅតាមគុណធម៌ទាំងបួន តើនេះទាំងអស់មានផ្លែរឺអត់?។

**លិទ្ធិនៃគ្រីស្តសាសនាតាមព្រះហគមន៍កាតូលិក**

១៨២៩ អ្នកមានចិត្តស្រលាញ់បង្កើតផល ដូចជាអំណរ សេចក្តីសុខសាន្ត និងធម៌មេត្តាករុណា អ្នកមាន ចិត្តស្រលាញ់យោគយល់ និងចេះជួយកែលំអគ្នាទៅវិញទៅមកដូចជាបងប្អូន អ្នកមានចិត្តស្រលាញ់ចេះអធ្យាស្រ័យ ធ្វើអោយគេស្រលាញ់វិញ មិនគិតអំពីផលប្រយោជន៍ផ្ទាល់មានចិត្តទូលាយ រាប់រកអ្នកដទៃ ដោយរួបរួមជាមួយគ្នា៖ កិច្ចការទាំងអស់របស់យើងបញ្ចប់ក្នុងសេចក្តីស្រលាញ់យ៉ាងស្មោះ។ ទីបំផុត យើងរត់សម្តៅទៅរកសេចក្តីស្រលាញ់នេះ។ ពេលជួបហើយ យើងក៏សម្រាកក្នុងសេចក្តីស្រលាញ់នេះ"(សន្តអូគូស្តាំង)។

ជាឱកាសមួយ ដើម្បីពិនិត្យមើលនៅក្នុងជីវិតរបស់យើង តើវាមានផ្លែឬអត់? តើយើងមានអំណរសប្បាយឬអត់?។ នៅពេលថ្មីនេះសម្តេចប៉ាប ហ្វ្រង់ស៊ីស្គូ បានសរសេរសារលិខិតដែលមានចំណងជើងថា អំណរសប្បាយនៃដំណឹងល្អ ។ គាត់សរសេរៈ

ចំនុចទីមួយ យើងជាគ្រីស្តបរិស័ទ យើងត្រូវតែបង្ហាញអំណរសប្បាយដែលយើងទទួលបានពីព្រះយេស៊ូផ្ទាល់ដល់អ្នកដទៃ ដោយសារដំណឹងល្អគឺព្រះយេស៊ូ។ នៅពេលព្រះយេស៊ូបានប្រសូត ណែនាំអោយពិភពលោកទាំងមូល ត្រូវតែមានអំណរសប្បាយ ជាឱកាសមួយដើម្បីនឹកឃើញ រួមជាមួយព្រះនាងម៉ារី ដំណឹងល្អអស្ចារ្យសម្រាប់ពិភពលោកទាំងមូល គឺព្រះយេស៊ូយាងមកដើម្បីអោយមនុស្សទាំងអស់មានជីវិតថ្មី។ បងប្អូនដែលជាគ្រីស្តបរិស័ទនៅកំពង់គោ ពីសម័យដើមគេមានសេចក្តីសុខ ក្នុងការរីកចម្រើនក្នុងការធ្វើកសិកម្ម ការអប់រំមានមណ្ឌលសុខភាព ជាមួយបងស្រីឧបការៈគុណ។ មានលោកសង្ឃដែលជិះកាណូតមកទីនេះ និងលោកតាវ៉ាន់ណោទទួលស្វាគមន៍ និងមានបងស្រីព្យាបាលជំងឺអោយគេ។ ដូច្នេះនេះទាំងអស់ណែនាំអោយបងប្អូនរីកចម្រើន និងមានអំណរសប្បាយមានសេចក្តីសុខ នៅក្នុងជីវិតមានអំណរសប្បាយថ្មីមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានណែនាំអោយយើងទទួលជីវិតថ្មី។ យើងត្រូវមើល តើនៅក្នុងជីវិតខ្ញុំតើខ្ញុំមានអំណរនិងអំណរនេះតើខ្ញុំព្រមចែកជាមួយអ្នកដទៃឬទេ? តើក្នុងជីវិតរបស់ខ្ញុំ តើខ្ញុំសេចក្តីសុខសាន្តឬអត់? តើក្នុងជីវិតរបស់ខ្ញុំ ខ្ញុំមានធម៌មេត្តាករុណា ដែលខ្ញុំបានចែករំលែកជាមួយបងប្អូនឯទៀតៗឬអត់? នេះជាចំនុចទីមួយ គឺអំណរ សេចក្តីសុខសាន្ត មេត្តាករុណា។

ចំនុចទីពីរ អ្នកមានចិត្តស្រលាញ់ណែនាំអោយចេះយោគយល់ ចេះជួយគេលំអរគ្នាទៅវិញទៅមកដូចជាបងប្អូន។ ជួយដើម្បីលំអរ មានន័យថាយើងត្រូវការអប់រំគ្នាទៅវិញទៅមក យើងជាបងប្អូន នៅក្នុងព្រះសហគមន៍របស់យើង នេះជាការអស្ចារ្យមួយ យើងលែងនៅឯកោ យើងទីពឹងលើគ្នាទៅវិញទៅមក។ យើងកុំភ្លេច បងប្អូនដែលបានធ្វើជំហានទីមួយ យើងបានប្រកាសថា យើងយកព្រះគ្រីស្តជាទីពឹង ព្រះគម្ពីរជាទីពឹង និងព្រះសហគមន៍ជាទីពឹង។ ព្រះសហគមន៍ជាយើងទាំងអស់គ្នា មានន័យថាយើងទីពឹងលើគ្នាទៅវិញទៅមក យើងត្រូវអប់រំគ្នាទៅវិញទៅមក។ កែលំអរ គឺដើម្បីជួយអោយបងប្អូនរបស់យើងរីកចម្រើន មិនមែនជួយយើងផ្ទាល់ ប៉ុន្តែអោយបងប្អូនរបស់យើងមានការរីកចម្រើន។ ព្រះយេស៊ូមានព្រះបន្ទូលថា *យើងពូកែមើលធូលីនៅក្នុងភ្នែករបស់គេ ប៉ុន្តែអ្វីដែលនៅក្នុងភ្នែករបស់យើងមើលមិនឃើញ។* យើងពូកែរិះគន់គេ យើងមើលឃើញ ដូច្នេះយើងត្រូវកែខ្លួនយើងសិនក្រោយមកយើងត្រូវការជួយកែគេ។ ព្រះយេស៊ូមានព្រះបន្ទូលទៀតថា *អ្នកខ្វាក់ ដឹកនាំអ្នកខ្វាក់ដូចម្តេចបាន?* អ្នកដែលមើលមិនឃើញ ដឹកនាំអ្នកដែលមើលមិន ឃើញដូចម្តេចនឹងបាន? ដូច្នេះសម្រាប់

យើង យើងត្រូវការទទួលពន្លឺពីព្រះយេស៊ូ ម្នាក់ៗយើងត្រូវការជួយគ្នាទៅវិញទៅមកនៅក្នុងការអប់រំ មិនមែនដើម្បីរិះគុណ មិនមែនដើម្បីជិះជាន់ មិនមែនដើម្បីអួតថាយើងល្អជាងគេ ប៉ុន្តែដើម្បីណែនាំអោយអ្នកដទៃកែលំអរ ដើម្បីយើងបង្កើតក្រុមគ្រួសារនៅក្នុងព្រះគ្រីស្ត។

ចំនុចទីបី អ្នកមានចិត្តស្រលាញ់ត្រូវមានចិត្តចេះអាស្រ័យ ធ្វើអោយគេស្រលាញ់វិញ មិនគិតពីផលប្រយោជន៍ផ្ទាល់ នឹងមានចិត្តទូលំទូលាយ។ យើងលើកលែងទោសអោយដោយលះបង់ចោលនិងដោយមានចិត្តទូលំទូលាយ។ មនុស្សយើងមានចិត្តចង្អៀតចង្អល់ គិតអំពីផ្ទាល់ខ្លួនគិតពីបងប្អូនផ្ទាល់ខ្លួន ប៉ុន្តែនៅក្នុងព្រះគ្រីស្តយើងត្រូវការបើកទូលំទូលាយ នៅក្នុងបេះដូងព្រះយេស៊ូ ព្រះហឬទ័យរបស់ព្រះយេស៊ូធំណាស់។ តើយើងត្រូវធ្វើដូចម្តេច ដើម្បីអោយមានសេចក្តីស្រលាញ់យ៉ាង តិចត្រឹម១%នៅក្នុងព្រះជាម្ចាស់ មិនអាចមាន១០០%ទេ មានតែ១%គ្រប់គ្រាន់ហើយ។ យើងមើលទៅសមុទ្រ ឃើញវាទូលំទូលាយមែនទែន អត់មានអ្វីមករារាំង មិនដឹងថាសមុទ្រទៅដល់ទីណា យើងនឹកឃើញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ទូលំទូលាយណាស់អត់មានព្រំដែនទេ អត់មានអីសោះដែលរារាំង អត់មានដើម អត់មានកោះអត់មានអីរាំង។ នៅពេលយើងមើលសមុទ្រ យើងត្រូវនឹកដល់ព្រះហឬទ័យរបស់ព្រះជាម្ចាស់។ យើងមិនចេះតែអធ្យាស្រ័យដោយមិនដឹងខ្លួន ប៉ុន្តែយើងចេះកែលំអរគ្នាទៅវិញទៅមក។ ពេលយើងទទួលអគ្គសញ្ញាលើកលែងទោស គឺជាអ្វីមួយដើម្បីអោយយើងនឹកឃើញដែរ ព្រះជាម្ចាស់លើកលែងទោសអោយខ្ញុំនៅពេលខ្ញុំសុខចិត្តកែប្រែចិត្តគំនិត ប្រសិនបើខ្ញុំមិនកែប្រែចិត្តគំនិត ព្រះជាម្ចាស់ក៏មិនលើកលែងទោសអោយខ្ញុំដែរនេះយើងត្រូវការគិតពិចារណា ដូច្នេះថ្ងៃនេះ យើងត្រូវមើលពីធម៌មេត្តាករុណា។

## ២ សេចក្តីស្រលាញ់ចំពោះអ្នកក្រីក្រ

### សេរីភាព ២២,២០-២៦

មិនត្រូវជិះជាន់ឬសង្កត់សង្កិនជនបរទេស ដែលរស់នៅជាមួយអ្នកឡើយដ្បិតអ្នករាល់គ្នា ក៏ធ្លាប់ជាជន បរទេសនៅស្រុកអេស៊ីបដែរ។ មិនត្រូវធ្វើបាបស្រ្តីមេម៉ាយឬក្មេងកំព្រាឡើយ។ប្រសិនបើអ្នកធ្វើបាបពួកគេហើយពួ កគេស្រែកហៅយើងយើងប្រាកដជាស្តាប់សំរែករបស់ពួកគេ។យើងនឹងខឹងអ្នករាល់គ្នាយ៉ាងខ្លាំងយើងនឹងប្រហារអ្នករាល់គ្នាដោយមុខដាវប្រពន្ធរបស់អ្នករាល់គ្នា នឹងទៅជាស្ត្រីមេម៉ាយហើយកូនរបស់អ្នករាល់គ្នានឹងទៅជាក្មេងកំព្រា។ ប្រសិនបើអ្នកអោយជនទុគ៌តណាម្នាក់ ក្នុងចំណោមប្រជាជនរបស់យើងខ្ចីប្រាក់មិនត្រូវប្រព្រឹត្តចំពោះគេដូចជាអ្នក ចងការប្រាក់ឡើយគឺកុំទារការប្រាក់ពីគេជាដាច់ខាត។ប្រសិនបើអ្នករាល់គ្នាទទួលអាវធំដែលអ្នកដទៃយកមកបញ្ចាំត្រូវប្រគល់ទៅគេវិញមុនពេលថ្ងៃលិច ដ្បិតអ្នកនោះគ្មានអ្វីផ្សេងទៀតដណ្តប់ទេបើគ្មានអាវធំតើបានអ្វីដណ្តប់នៅ ពេលដេក?ប្រសិនបើគេស្រែករកយើងយើងនឹងស្តាប់ពាក្យគេដ្បិតយើងមានចិត្តអាណិតមេត្តា។

ពេលយើងជួយគឺយើងជួយ យើងមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន។នឹកឃើញដល់ព្រះជាម្ចាស់គង់នៅជាមួយយើង និងខិតខំនឹកឃើញដល់សេចក្តីស្រលាញ់ ដែលយើងបានទទួលពីព្រះជាម្ចាស់។ យើងម្នាក់ជាគ្រីស្តបរិស័ទ ដែលជាឧបករណ៍នៃការសង្គ្រោះរបស់ព្រះជាម្ចាស់។ព្រះជាម្ចាស់អត់មានយើង ព្រះអង្គប្រទានការសង្គ្រោះមិនបាន។យើងគឺជាឧបករណ៍របស់ព្រះជាម្ចាស់ ជាដៃ ជាភ្នែក ជាមាត់របស់ព្រះជាម្ចាស់ ដើម្បីអោយយើងណែនាំអោយអ្នកដទៃមានសេចក្តីសុខ ដើម្បីណែនាំអោយអ្នកដទៃមានសេចក្តីសង្ឃឹម។ ដូច្នេះសូមយើងគិតម្នាក់ៗ តើខ្ញុំមានទស្សនៈអ្វីខ្លះសម្រាប់ជីវិតរបស់ខ្ញុំ? ខ្ញុំចង់ជោគជ័យអ្វីខ្លះ? ខ្ញុំចង់ធ្វើអ្វីខ្លះ? ដើម្បីជីវិតរបស់ខ្ញុំជាគ្រីស្តបរិស័ទដោយធ្វើជាឧបករណ៍របស់ព្រះជាម្ចាស់អាចមានឥទ្ធិពលទៅលើមនុស្សលោកទាំងអស់ក្នុងពិភពលោកទាំងមូល។សូមម្នាក់ៗគិតទស្សនៈផ្ទាល់ខ្លួនដែលជាគ្រីស្តបរិស័ទ ជីវិតរបស់ខ្ញុំជាសាវ័ករបស់ព្រះយេស៊ូ ជីវិតរបស់ខ្ញុំជាគ្រីស្តទូតរបស់ព្រះជាម្ចាស់។ ពេលលោកតាវ៉ាន់ណោមកដល់ទីនេះ គិតទស្សនៈរបស់គាត់ គឺត្រូវធ្វើដូចម្តេច ដើម្បីអោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅដល់ប្រជាជនខ្មែរ។ ទីពីរពេលយើងមានទស្សនៈរបស់យើងហើយយើងត្រូវការមានចិត្តស្រលាញ់ដល់កំពូល ចិត្តស្រលាញ់ដោយយកចិត្តទុកដាក់។ ដោយសារទស្សនៈរបស់យើង យើងអនុវត្តមិនបានប្រសិនបើយើងធ្វើមិនបានស្រលាញ់អ្វីដែលយើងបានធ្វើ។ លោកតាវ៉ាន់ណោ គាត់សង្កេតមើលទុក្ខលំបាករបស់ប្រជាជននៅកំពង់គោពិបាកធ្វើស្រែការចិញ្ចឹមជីវិត បញ្ហាលិចទឹក បញ្ហាការសិក្សា បញ្ហាសុខភាព។ ដូច្នេះដោយសេចក្តីស្រលាញ់គាត់ខិតខំដោយយកចិត្តទុកដាក់អស់ពីសមត្ថភាពគាត់។ នៅពេលគាត់នៅជុំរុំនៅប្រទេសថៃគាត់អាណិតប្រជាជនទាំងអស់នោះណាស់ ដោយសារគាត់បានភ្ជាប់បងប្អូន ដោយអស់ពីសេចក្តីស្រលាញ់ដោយយកចិត្តទុកដាក់របស់គាត់។ យើងមានទស្សនៈរបស់យើង ក្រោយមកយើងត្រូវការមានសេចក្តីស្រលាញ់ដោយយកចិត្តទុកដាក់ ដោយសារបើឥតមានសេចក្តីស្រលាញ់ជាអ្វីដែលយើងស្តាប់លោកប៉ូលគាត់ថា គ្មានសេចក្តីស្រលាញ់យើងអាចធ្វើអ្វីក៏បានប៉ុន្តែវាឥតមានន័យ។ សេចក្តីស្រលាញ់ គឺមកពីព្រះជាម្ចាស់មិនមែនជាសេចក្តីស្រលាញ់តូចៗរបស់យើង ប៉ុន្តែគឺជាសេចក្តីស្រលាញ់ដ៏ធំទូលំទូលាយដែលគ្មានព្រំដែនដូចមហាសមុទ្រ។ទីបីគឺអោយយើងអនុវត្តយ៉ាងសកម្ម ដោយសារពេលយើងមានទស្សនៈ មានសេចក្តីស្រលាញ់អស់ពីកម្លាំងកាយកម្លាំងចិត្តអោយយើងអនុវត្ត។ កុំអោយយើងចេះតែនិយាយ ចេះតែថាប៉ុន្តែយើងមិនអនុវត្ត។ ដូចនេះយើងត្រូវអនុវត្តដូចព្រះយេស៊ូ យើងត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នា។ ដូចព្រះយេស៊ូស្រលាញ់អ្នកក្រីក្រ ស្រលាញ់កូនក្មេងក្មេងកំព្រា ជនពិការ ស្ត្រីមេម៉ា ដូចព្រះយេស៊ូយកនំប៉័ង មកកាន់ហើយមានព្រះបន្ទូលថា " នេះជាព្រះកាយរបស់ខ្ញុំ ដែលត្រូវបូជារួសំរាប់អ្នករាល់ " នេះមិនមែនតែជាព្រះបន្ទូលតែប៉ុណ្ណឹង តែ

ពីរថ្ងៃក្រោយព្រះយេស៊ូបានសោយទិវង្គនៅលើឈើឆ្កាង។ ដូច្នេះព្រះយេស៊ូថា នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជារួជីវិតហើយព្រះអង្គបានអនុវត្តតាម។ សម្រាប់យើងក៏ដូចគ្នា ធ្វើដូចម្ដេចដើម្បីអនុវត្តយ៉ាងសកម្ម អ្វីដែលយើងបានសម្រេចចិត្តសម្រាប់ជីវិតរបស់យើង?។ យើងត្រូវការគិតតាមជីវិតរបស់យើងបច្ចុប្បន្ននេះ តាមបទពិសោធរបស់យើង សម្រាប់ឆ្នាំ២០១៥នេះ យើងជាយុវជនតាមមណ្ឌលរបស់យើង តើយើងមានទស្សនៈអ្វីខ្លះសម្រាប់ក្រុមយុវជនរបស់យើងក្នុងព្រះសហគមន៍យើង? តើយើងសុខចិត្តបញ្ចេញអោយអស់ពីកំលាំងកាយកំលាំងចិត្តរបស់យើងរឺអត់? តើយើងសុខចិត្តអនុវត្តដូចម្ដេច?។ ជីវិតរបស់យើងម្នាក់ៗ យើងមិនមែនជាលោកតាវ៉ាន់ណោទេ ប៉ុន្តែយើងធ្វើដូចម្ដេច ធ្វើអោយយើងមានកំលាំងនៅក្នុងជីវិតរបស់យើង អោយយើងដឹងថាខ្ញុំគឺជាគ្រីស្តបរិស័ទដើម្បីធ្វើជាគំនូរសំរាប់បងប្អូនខ្ញុំ សំរាប់ព្រះសហគមន៍របស់ខ្ញុំ និងសម្រាប់ព្រះសហគមន៍ក្នុងប្រទេសកម្ពុជាទាំងមូល។

# VII. " គម្រោងសកម្មភាព "

## របាយការណ៍ពីមហាសន្និបាតគ្រីស្ទបរិស័ទ
## ២៥-២៨ កញ្ញា ២០១៤

ចូរសរសេររៀបរាប់ពីភាពក្រីក្រដែលអ្នកមើលឃើញនៅកន្លែងរស់នៅកន្លែងធ្វើការរបស់អ្នក ?

### ១. មណ្ឌលសកម្មភាពភ្នំពេញថ្មី និងតាខ្មៅ

- ខ្វះទីជំរក (អ្នករើសអេតចាយ និងមើលគោ)
- ខ្វះចំណេះដឹង
- ខ្វះការយកចិត្តទុកដាក់ និងភាពកក់ក្ដៅ
- ខ្វះចំណីអាហារ
- ខ្វះការងារធ្វើ មនុស្សចំណាកស្រុក
- ឪពុកម្ដាយលែងលះគ្នា
- គ្រួសារមានកូនច្រើន
- លេងល្បែង ផឹកស្រា
- ខ្វះការអប់រំកូន
- ខ្វះការគោរពសិទ្ធិកុមារ កូនទៅធ្វើការមានអាយុតិច
- ស្ត្រីមានផ្ទៃពោះនៅក្មេងពេក ចាប់មានស្នេហា
- ខ្ជិលច្រអូស

### ២. មណ្ឌលសកម្មភាពភ្នំពេញខាងជើង

- ខ្វះខាតសម្ភារៈ ៖ គ្មានថវិការដើម្បីរៀន អត់មានដីដើម្បីធ្វើផ្ទះ គ្មានលុយទិញអាហារយុវជន គ្មានការងារធ្វើ
- ខ្វះខាងវិញ្ញាណ៖ មានការអាក់អន់ចិត្តព្រះសហគមន៍មិនជួយលើកទឹកចិត្តខ្វះទំនាក់ទំនងនៅក្នុងក្រុមគ្រួសារ គ្រីស្ទបរិស័ទមួយចំនួនបោះបង់ជំនឿ ការអប់រំជំនឿនៅមានភាពទន់ខ្សោយ ខ្វះការសួរសុខទុកអ្នកក្រីក្រតាមផ្ទះ
- ខ្វះខាងសីលធម៌៖ ប្រើប្រាស់គ្រឿងញៀន ផឹកស្រា លេងល្បែង និងមានភាពខ្ជិលច្រអូស

### ៣. មណ្ឌលសកម្មភាពបាសាក់

- ជក់ថ្នាំញៀន
- ខ្វះធនធានមនុស្ស
- ខ្វះជំរក
- ខ្វះលទ្ធភាពបញ្ជូនកូនទៅសាលារៀន
- ខ្វះចំណេះដឹង
- ខ្វះគ្រូបង្រៀន
- ខ្វះថវិការជួសជុលផ្ទះ
- ខ្វះជំនឿ

## ៤. មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង

- **តំបន់ចាក់អង្រែក្រោម៖** លិចទឹក ពិបាកធ្វើដំណើរ ៩០% (៣០០គ្រួសារ=១៣៨០នាក់)ក្រពេលឈឺអត់លុយទៅមន្ទីរពេទ្យ សាលារៀនសិក្សាពុកផុយ (អក្សរខ្មែរនិងវៀតណាម)
- **តំបន់ទូតាំង៖** ជំលោះខ្មែរនិងវៀតណាម សាលាខ្មែរសិស្សតិច តែសាលាវៀតណាមមានសិស្សច្រើន ខ្វះការអប់រំ ជំលោះពាក្យសំដី ៥០%ជាខ្មែរ និង៥០%ជាវៀតណាម ខ្វះមុខរបរ ខ្វះអាហារហូប លួចប្លន់ អសន្តិសុខសង្គម
- **តំបន់កោះនរា៖** ឈឺអត់លុយព្យាបាល ទីលំនៅមិនច្បាស់លាស់ (ស្នាក់នៅលើទូកគេដេញទៅដេញមក) អត់មានអត្តសញ្ញាប័ត្រ ស្ត្រីរកស៊ីផ្លូវភេទ ១០% គ្រឿងញៀន
- **តំបន់បឹងទំពុន៖** ឪពុកម្តាយអត់ចេះអក្សរ ឬតិចតួច រស់នៅលើបឹងដោយរកស៊ីបេះត្រកួន ចំណូលមិនគ្រប់គ្រាន់ ខ្ចីលុយគេដោយកូនឈឺ ជួលផ្ទះឬដីគេ ខ្វះអនាម័យដោយប្រើទឹកបឹង និងតំលៃទឹកភ្លើងថ្លៃសម្រាប់ពួកគាត់ (ទឹក១គីប=4000៛ ភ្លើង១គីឡូ=2000៛)
- **តំបន់ចំការដូង៖** ក្នុងភូមិមានក្មេងស្ទាវច្រើន ល្បែងស៊ីសង ប្តីរកស៊ី ប្រពន្ធលេងល្បែងខ្វះការណែនាំកូន បណ្តោយតាមកូន ខ្វះការអប់រំ គ្រួសារខ្លះក្ររហូតដេកតាមសំយាបផ្ទះ របស់គេ អ្នកខ្លះវង្វេងវង្វាន់ ជំពាក់បំណុល គ្រួសារក្រតាំងពីជំនាន់ដើមរហូតដល់ជំនាន់ថ្មី ចំពោះកម្មកររោងចក្រគ្មានអ្នកមើលថែទាំកូន ឪពុកម្តាយមានជំងឺ ផ្គត់ផ្គង់កូនបានរៀនត្រឹម ថ្នាក់ទី៤ ឬទី៥ ធ្វើការថែមម៉ោងច្រើនទាំងពេលមានជំងឺ ផ្ញើកូនឲ្យគេមើល។

## ៥. មណ្ឌលសកម្មភាពកំពង់សោម

### ក. ខាងសីលធម៌

- ឪពុកម្តាយប្រឹងប្រែងរកស៊ី មិនរវីរវល់ក្នុងការណែនាំកូន
- កង្វះការសិក្សា
- យុវជនសេពគ្រឿងញៀន
- គ្មានទំនាក់ទំនងល្អរវាងគ្នានិងគ្នា

### ខ. សំភារៈ

- គ្មានផ្លូវ គ្មានភ្លើង សាលារៀនមិនគ្រប់គ្រាន់
- ផ្ទះចាស់ មិនមាំ

### គ. ខាងវិញ្ញាណ

- គ្រូជំរុញឲ្យសិស្សឡើងថ្នាក់ដោយសារខ្លាចថ្នាក់លើ
- ឪពុកម្តាយមិនសូវណែនាំកូន
- គ្រីស្តបរិស័ទមិនបើកភ្នែក មិនបើកចិត្តមើលអ្នកដទៃ
- គ្រីស្តបរិស័ទធ្វើឲ្យអ្នកដទៃវង្វេងជំនឿ

## ៦. មណ្ឌលសកម្មភាពមេគង្គ

**ក. ចំប៉ា**

- ខ្វះខាតខាងការសិក្សា
- ខ្វះថវិការព្យាបាលជំងឺ
- យុវជនសេពគ្រឿងញៀន ល្បែង
- មិនសូវទៅព្រះវិហារ
- ខ្វះសេចក្ដីស្រឡាញ់

**ខ. ផ្លូវត្រី**

- មិនសូវទៅព្រះវិហារ
- មិនជំរុញកូនឲ្យទៅរៀន

**គ. កំពង់ចំលង**

- ល្បែងស៊ីសង និងជក់ម៉ា

**ឃ. ព្រៃដាច់**

- ក្មេងបោះបង់ការសិក្សាព្រោះជួយធ្វើការឪពុកម្ដាយ

**ង. សំរោងធំ**

- មានកូនច្រើន
- ខ្វះការងារ
- ថវិការប្រចាំខែទាប
- មិនរស់នឹងគ្រួសារ
- ការបាក់ដី ខ្វះលំនៅដ្ឋាន ខ្វះថវិការជួយអ្នកជំងឺ
- យុវជនពេលទំនេរ មិនចេះជួយធ្វើកិច្ចការ និងបញ្ហាល្បែងស៊ីសង
- គ្មានចិត្តសប្បុរសចំពោះអ្នកក្រីក្រ ខ្វះសេចក្ដីស្រឡាញ់
- ខ្វះការអប់រំខាងផ្លូវវិញ្ញាណ

**ច. រោងចក្រ**

- ចាស់ជរាច្រើន កូនមិនថែរក្សា
- យុវជនប្រើប្រាស់គ្រឿងញៀន ល្បែង
- អ្នកនៅក្នុងភូមិមិនយកចិត្តទុកដាក់រវាងគ្នានឹងគ្នា និងជាមួយអ្នកក្រក្រី

## ៧. មណ្ឌលសកម្មភាពកំពត-កែប

- ខ្វះសាលារៀន
- ខ្វះមន្ទីពេទ្យរដ្ឋ
- ខ្វះការយកចិត្តទុកដាក់ ការអប់រំ និងការទំនាក់ទំនង ពីឪពុកម្ដាយ
- ខ្វះដី និងផ្ទះសម្រាប់ស្នាក់នៅ
- ខ្វះអនាម័យបណ្ដាលយឲ្យមានជំងឺ
- មានអំពើហឹងស្សា
- ញៀនថ្នាំ និងស្រាបៀ
- គ្មានការងារធ្វើ នាំឲ្យចំណាកស្រុកច្រើន
- ខ្វះការសន្សំសម្ចៃ (ចាយលុយខុសទិសដៅ)
- ខ្វះសន្តិសុខ (ចោរប្លន់ បាត់សំភារៈ)
- ខ្វះសីលធម៌ និយាយកុហក
- អំពើពុករលួល (ការរៀនគួរ ដីធ្លី)
- ខ្វះសេចក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ ការចែករំលែក
- ខ្វះការលើក ស្ទួយលើផលដំណាំនៅជនបទ

## ៨. មណ្ឌលសកម្មភាពតាកែវ

**ក. ខាងសំភារៈ**
- ចាស់ជរាគ្មានទីពឹង
- ក្មេងអាណាថា គ្មានទីពឹង
- ខ្វះជម្រក
- ចំណីអាហារមិនគ្រប់គ្រាន់ ខ្វះសំលៀកបំពាក់
- ពិការភាព
- ជំងឺរាំរៃ (សុខភាបទ្រុឌទ្រោម)
- ខ្វះការអប់រំ និងជំនាញវិជ្ជាជីវៈពិតប្រាកដ
- ខ្វះការងារធ្វើ ប្រាក់ចំណូលប្រចាំខែមិនគ្រប់គ្រាន់

**ខ. ខាងសីលធម៌**
- ក្មេងទំនើង លេងល្បែងស៊ីសង
- ប្រើប្រាស់គ្រឿងញៀន ផឹកស្រារហូតក្លាយជាមនុស្សប្រមឹក
- គ្រួសារមិនចុះសម្រុងគ្នា អំពើហិង្សាក្នុងគ្រួសារនិងសង្គម
- ខ្វះភាពស្មោះត្រង់
- អំនួត (មើលងាយអ្នកដទៃ)
- ជំងឺសង្គម

**គ. ខាងវិញ្ញាណ**
- ខ្វះការលើកទឹកចិត្ត
- ផ្តល់សេចក្តីសង្ឃឹម
- ខ្វះការទំនាក់ទំនង
- ខ្វះភាពកក់ក្តៅក្នុងគ្រួសារ+សង្គម
- ខ្វះទំនុកចិត្ត
- ខ្វះភាពក្លាហាន
- ខ្វះការយកចិត្តទុកដាក់
- អាត្មានិយម
- ខ្វះសេចក្តីស្រឡាញ់
- ខ្វះការតស៊ូព្យាយាម

## ៩. ការិយាល័យ និងមណ្ឌលនិស្សិត

- ខ្វះទំនាក់ទំនង
- អាត្មានិយម
- ខ្វះការអប់រំ (ខាងអនាម័យ សុជីវធម៌)
- ជំនឿជ្រុលនិយម (ខ្វះការយល់ដឹង)
- ខ្វះជំនាញ
- ខ្វះការលើកទឹកចិត្ត ការគាំទ្រ
- ខ្វះការអប់រំ (ខាងប្រព័ន្ធផ្សព្វផ្សាយ ទាក់ទងសាសនា)
- ធនធានមនុស្ស (ផ្លាស់ប្តូរថ្មី)
- ខ្វះយុត្តិធម៌សង្គម (គ្រួសារនិយម អំពើពុករលួយ)
- ខ្វះការគោរពសិទ្ធិគ្នា (ចរាចរណ៍)
- ខ្វះភាពសាមគ្គីគ្នា
- ខ្វះការស្គាល់គ្នារវាងគ្នា និងគ្នា
- ខ្វះការទទួលស្គាល់
- ខ្វះការផ្តល់ឱកាស ខ្វះទំនុកចិត្ត
- ជម្លោះ មិនសូវចុះសម្រុងគ្នា ខ្វះវិន័យ និយាយដើមគ្នា
- ខ្វះក្តីស្រឡាញ់
- ខ្វះការដឹងគុណ
- ខ្វះផ្លូវវិញ្ញាណក្នុងការបញ្ចេញសកម្មភាព (Spiritual of Mission)

## ១០. បុព្វជិត បុព្វជីតា អង្គការមនុស្សធម៌

- ខ្វះការអប់រំ
- ខ្វះការងារធ្វើ ( មុខរបរ )
- ខ្វះសិទ្ធិកុមារ ( ការអប់រំ ការរស់នៅចំពោះជនជាតិវៀតណាម )
- ខ្វះជំរក ខ្វះអាហារ ( មូលដ្ឋានគ្រឹះក្នុងការរស់នៅ )
- ឪពុកម្តាយខ្វះចំណេះដឹង
- សិស្សគ្មានលទ្ធភាពបង់ការសិក្សា
- ខ្វះទំនាក់ទំនង
- ខ្វះសីលធម៌ក្នុងការប្រើប្រាស់ពាក្យសំដី
- ធ្វើការថែមម៉ោងច្រើន ( កម្មកររោងចក្រ ) ការកេងប្រវ័ញ្ចកំលាំងពលកម្ម
- ខ្វះការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំ
- ខ្វះលទ្ធភាពបន្តការសិក្សា
- គ្មានជំនឿពិតប្រាកដ ( សាសនា )
- ខ្វះភាពកក់ក្តៅ និងសេចក្តីស្រឡាញ់
- ខ្វះការលើកទឹកចិត្ត ( ជនពិការ )
- ខ្វះទំនុកចិត្ត
- ខ្វះការអប់រំខាងសីលធម៌
- ខ្វះមធ្យោបាយ
- ខ្វះការទទួលពត៌មាន ខាងសុខភាព និងពត៌មានទូទៅ
- ឪពុកម្តាយបាក់ទឹកចិត្តក្នុងការថែរក្សាកូនដែលឈឺ ឬពិការ
- ខ្វះក្រមសីលធម៌ក្នុងការងារ
- ខ្វះការតស៊ូ
- ខ្វះការផ្តល់តម្លៃលើខ្លួនឯង
- ខ្វះការលើកទឹកចិត្តពីឪពុកម្តាយ
- សំភារៈនិយម
- ខ្វះគោលដៅក្នុងជីវិត

យើងជាព្រះសហគមន៍ ត្រូវតែជំរុញឲ្យមានការអប់រំក្រុមគ្រួសារ។ ក្រុមគ្រួសារជាសង្គមតូចបំផុត ដែលក្នុងនោះមានឪពុក មានម្តាយ មានកូនៗ លោកតា លោកយាយរស់នៅជាមួយគ្នា។ គ្រួសារនីមួយៗរួមគ្នាទៅជាសង្គមធំមួយ។ ព្រះសហគមន៍កាតូលិកបានទទួលស្គាល់ថា គ្រួសារគឺជាសង្គមតូចបំផុតហើយសំខាន់បំផុត។ប្រសិនបើគ្រួសារមួយបូកនឹងគ្រួសារមួយទៀតមានអំណរសប្បាយ មានសេចក្តីសុខ ណែនាំឲ្យសង្គមទាំងមូលមានអំណរសប្បាយ និងសេចក្តីសុខ ដោយសារគ្រួសារនីមួយៗមានឥទ្ធិពលលើសង្គមទាំងមូល។ ហេតុនេះហើយបានជាព្រះសហគមន៍ ឲ្យយើងគិតអំពីការអប់រំដល់គ្រួសារនីមួយៗ ដើម្បីឲ្យសង្គមគ្រួសារដែលមានកូនក្មេង យុវជន លោកឪពុក អ្នកម្តាយអាចរីកចម្រើនបាន ហើយនេះជាអ្វីដែលយើងអាចធ្វើបាន តាមរយៈក្រុមយុវជន ដែលមានការិយាល័យយុវជនជាអ្នកសម្របសម្រួល។

ចំណុចមួយទៀតទាក់ទងនឹងអនាម័យ ដែលយើងត្រូវតែគិតឲ្យបានទូលំទូលាយ។ យើងធ្លាប់គិតអំពីអនាម័យខាងរូកាយ ដែលទាក់ទងនឹងសុខភាពរបស់យើង បើគ្មានអនាម័យនាំឲ្យយើងឈឺ ប៉ុន្តែយើងមិនដែលបានចាប់អារម្មណ៍អំពីអនាម័យខាងធម្មជាតិ ដែលទាក់ទងនឹងបរិដ្ឋានទេ។ តាមពិតធម្មជាតិ ក៏ត្រូវការអនាម័យដែរ ដូចជាបញ្ហាសំរាម បញ្ហាការពារសម្បត្តិធម្មជាតិជាដើម...។ ប្រសិនបើយើងនិយាយអំពីរឿងអនាម័យនេះ ដោយគិតពីការសាងមន្ទីរពេទ្យធំៗ ពីការកសាងផ្លូវកៅស៊ូ កសាងមហាវិទ្យាល័យ... នោះយើងជាគណៈកម្មការសង្គហៈគ្មានលទ្ធភាពធ្វើទេ យើងធ្លាប់ធ្វើតែផ្លូវតូចៗ មន្ទីរសុខភាពតូចៗ តាមភូមិនានាតាមសមត្ថភាពរបស់យើងប៉ុណ្ណោះ។ ប៉ុន្តែការអប់រំក្រុមគ្រួសារ អំពីអនាម័យខាងរាងកាយ និងអនាម័យដល់ធម្មជាតិ នោះយើងអាចធ្វើបាន ព្រោះវាមិនទាមទារអ្វីដែលលើសពីសមត្ថភាពរបស់យើងទេ។

ចំណុចមួយទៀត សព្វថ្ងៃនៅក្នុងទីក្រុងភ្នំពេញ តាកែវ កំពង់សោម យើងឃើញមានរោងចក្រថ្មីៗជាច្រើនកើតឡើង ដែលមានកម្មករកម្មការិនីសរុបទាំងអស់ប្រហែល ៦០ ទៅ ៧០ ម៉ឺននាក់។ តើយើងមើលឃើញ និងស្តាប់ពីជីវិតរបស់ពួកគេប្រចាំថ្ងៃយ៉ាងណា? គេត្រូវការអ្វីខ្លះ? គេមានបញ្ហាអ្វីខ្លះ?។ យើងមានបងស្រីដែលធ្វើការជាមួយកម្មកររោងចក្រ យើងមានការិយាល័យកម្មករដែលថែរក្សាកម្មករកម្មការិនី។ តាមការមើលឃើញ និងស្តាប់ព្

យើងមានការិយាល័យកម្មករដែលថែរក្សាកម្មករកម្មការិនី។ តាមការមើលឃើញ និងស្តាប់ព្
របស់យើង គឺកម្មករកម្មការិនីគេរស់នៅក្នុងបរិយាកាសលំបាកណាស់។ ដូច្នេះខ្ញុំគិតថា យើងដែលជាគណៈកម្មការសង្គហៈ ដែលជាក្រុមនៃធម៌មេត្តាករុណា ដែលជាគ្រីស្តបរិស័ទ ត្រូវតែបើកភ្នែកថែមទៀតចំពោះបញ្ហាដ៏សំខាន់នេះ។

នៅក្នុងទីក្រុងភ្នំពេញមានកូនក្មេងអនាថាច្រើនណាស់ នៅជុំវិញនេះមានប៉ុន្មានគ្រួសារដែលរស់នៅយ៉ាងវេទនា។ ដូច្នេះយើងជាគណៈកម្មការ សង្គហៈត្រូវតែបើកភ្នែកដើម្បីចាប់អារម្មណ៍ ដើម្បីយកចិត្តទុកដាក់នូវអ្វីៗ ដែលនៅជុំវិញយើង និងបន្ទាប់មកយើងត្រូវធ្វើជាស្ពានសម្រាប់ពួកគេ ដោយនាំពួកគេឲ្យទៅជួបនឹងអ្នកដែលអាចជួយពួកគេបាន ដ្បិតថាយើងមិនអាចសង្គ្រោះមនុស្សទាំងអស់បានទេ ប៉ុន្តែយើងអាចធ្វើជាស្ពានបាន ដែលនេះគឺជាតួនាទីមួយទៀតរបស់យើង។ ឧទាហរណ៍ ក្នុងគណៈកម្មការពលករ ប្រសិនបើយើងស្គាល់កម្មករណាម្នាក់ដែលកំពុងជួបនឹងការលំបាកយ៉ាងខ្លាំង នោះចូរឲ្យយើងនាំគេទៅជួបនឹងអ្នកដែលអាចជួយគេបាន ធ្វើដូច្នេះយើងនឹងទៅជាស្ពានរបស់ពួកគេ។ ឧទាហរណ៍ផ្សេងខ្លះទៀត ពេល

យើងឃើញកុមារកំព្រាម្នាក់ដែលអត់មានកន្លែងស្នាក់នៅ យើងអាចធ្វើជាស្ពានដោយនាំកុមារនោះឲ្យទៅស្គាល់បងស្រីមេត្តាករុណា។ ពេលយើងឃើញគ្រួសារមួយដែលក្រីក្រទាំងមានកូនច្រើននាក់ ហើយចង់ឲ្យកូនៗទាំងនោះទៅរៀន យើងមិនអាចដោះស្រាយបានទេ ប៉ុន្តែយើងអាចធ្វើជាស្ពានដោយឲ្យគ្រួសារនោះស្គាល់សាលាដុនបូស្កូ។ ប្រសិនបើឃើញយុវជនម្នាក់នៅតាមភូមិ ហើយគាត់អត់ដឹងធ្វើអ្វី យើងត្រូវណែនាំឲ្យគាត់ស្គាល់អង្គការការីតាស ដែលមានសាលាជំនាញផ្សេងៗដែលគាត់អាចចូលរៀនបាន។

## ១ ទី ១ ឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក

ក្នុងភូមិភាគភ្នំពេញរបស់យើង សូមឲ្យយើងយកចិត្តទុកដាក់បើកភ្នែកមើលឃើញនូវអ្វីៗដែលមាននៅជុំវិញយើង។ ក្នុងអង្គប្រជុំយើងនៅពេលនេះ មានតំណាងអង្គការនានាមកចូលរួម ដែលណែនាំឲ្យអង្គប្រជុំរបស់យើងបានស្គាល់ ដើម្បីឲ្យយើងអាចធ្វើជាស្ពានដល់យុវជនដែលយើងឃើញ ដល់កូនក្មេងដែលយើងស្គាល់ ដល់បងប្អូនយើងដែលជួបការលំបាក ដើម្បីឲ្យគេទៅកន្លែងមួយដែលអាចជួយគេបាន។ រចនាសម្ព័ន្ធនៃព្រះសហគមន៍កាតូលិកក្នុងភូមិភាគភ្នំពេញរបស់យើង សម្រាប់មេត្តាករុណាធំណាស់។ ឥឡូវនេះ យើងកំពុងរៀបចំសៀវភៅមួយស្តីអំពីអង្គការកាតូលិកនីមួយៗ មានសមត្ថភាពអ្វី មានសកម្មភាពអ្វី និងមានលេខទូរស័ព្ទសម្រាប់ទាក់ទងផង។ យើងនឹងចែកសៀវភៅនោះដល់គណៈកម្មការនីមួយៗ

ដើម្បីឲ្យអាចធ្វើជាស្ពានបាន។ សូមបងប្អូនបើកភ្នែកគ្រប់ពេលវេលា ចូរឲ្យភ្នែករបស់យើងទៅជាភ្នែកបង្គង ដែលមើលឃើញគ្រប់ទិសទី កុំឲ្យភ្នែករបស់យើងមើលឃើញទៅតែខាងមុខខាងស្តាំ ឬខាងឆ្វេងតែប៉ុណ្ណោះ។ យើងត្រូវសម្អាតភ្នែកឲ្យបានល្អដើម្បីមើលឃើញ យើងត្រូវសម្អាតត្រចៀកដើម្បីស្តាប់ឮ ដែលជាគន្លឹះដើម្បីធ្វើជាស្ពានដ៏ល្អ។

## ២ ទី ២ ឲ្យយើងចេះ ស្រឡាញ់អ្នកឯទៀត។

ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាផ្ទះរបស់អ្នកក្រីក្រ នោះយើងជាព្រះសហគមន៍ត្រូវរួមគ្នាទៅជាគ្រួសារតែមួយ ឲ្យយើងបង្កើតមិត្តភាពដែលយើងទៅជាបងប្អូនគ្នាពិតមែន និងឲ្យយើងខិតខំធ្វើឲ្យគណៈកម្មការសង្គហៈរបស់យើងតាមព្រះសហគមន៍នីមួយៗ មានជីវិត

យ៉ាងរស់រវើកឡើង ទៅជាគណៈកម្មការសង្គហៈដែលយកព្រះបន្ទូលជាប្រភព នៃសកម្មភាពរបស់ខ្លួន ដោយទី ១ ត្រូវរកពេលវេលាអធិដ្ឋានដើម្បីស្ដាប់ព្រះបន្ទូល ទី ២ ត្រូវបើកភ្នែកដើម្បី មើលឃើញនិងទី ៣ ត្រូវចុះទៅសួរសុខទុក្ខយ៉ាងពិតប្រាកដដើម្បីស្គាល់អស់អ្នកដែលយើងជួយ និងទី ៤ ត្រូវជួយដោយធ្វើសកម្មភាពជាក់ស្ដែងដើម្បីរួមសុខទុក្ខជាមួយអ្នក ដែលយើងបានជួយ។

## ៣ ទី ៣ សេចក្ដីស្រឡាញ់ធម៌មេត្តាករុណា ណែនាំឲ្យយើងមានគំនិតថ្មីៗគ្រប់ពេលវេលា

ជីវិតរបស់សត្វឃ្មុំពិសេសណាស់ ដោយវារៀបចំរចនាសម្ព័ន្ធយ៉ាងច្បាស់លាស់ក្នុងសំបុករបស់វា ដែលមានម្ចាស់ស្រ្តីជាអ្នកណែនាំ មានកម្មករដែលធ្វើការងារ មានទាហាន ដែលការពារ...។ ខ្ញុំគិតថា ព្រះសហគមន៍របស់យើងក៏ត្រូវតែទៅជាសំបុកឃ្មុំមួយដែរ គឺសំបុកឃ្មុំនៃសេចក្ដីស្រឡាញ់ មិនមែនជាសត្វឃ្មុំដែលទិចគេឯងឲ្យឈឺចាប់នោះទេ។ យើងត្រូវទៅគ្រប់ទីកន្លែងដូចសត្វឃ្មុំ ដើម្បីបង្ហាញសញ្ញានៃធម៌មេត្តាករុណា។ ចូរឲ្យយើងម្នាក់ៗ និងព្រះសហគមន៍នីមួយ ៗ កុំនៅស្ងៀមស្ងាត់។ ពីព្រឹកដល់យប់ ចូរឲ្យយើងភ្ញាក់ស្មារតីថា តើយើងត្រូវធ្វើដូចម្ដេចដើម្បីនាំឲ្យអ្នកដទៃមានសុភមង្គល និងទទួលសេចក្ដីស្រឡាញ់ពីយើង ?។ ឃ្មុំវាអត់នៅស្ងៀមទេ វាចេញចូលរហូត។

# VIII. " សំណួរដើម្បីរិះគិតបន្ថែម "

១. ចូរសរសេររៀបរាប់ពីភាពក្រីក្រដែលអ្នកមើលឃើញនៅកន្លែងរស់នៅ ឬកន្លែងធ្វើការរបស់អ្នក ?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

២. យ៉ាងសំខាន់ដែលយើងត្រូវតែចាំ និងសួរខ្លួនឯងថា តើខ្ញុំបណ្តោយអោយព្រះជាម្ចាស់ដាក់មេត្តាករុណាក្នុងចិត្តខ្ញុំដូចម្តេច ?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

៣. មើលក្នុងព្រះសហគមន៍ផ្ទាល់ខ្លួន តើគណៈកម្មការសង្គហៈមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ ?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

៤. តើមានសំណើរ ឬ អនុសាសន៍អ្វីខ្លះ ដើម្បីឲ្យគណៈកម្មការសង្គហៈរបស់យើងមានការរីកចម្រើនថែមទៀត?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៥. តើមានអទិភាពអ្វីខ្លះ ដែលអ្នកចង់ឲ្យគណៈកម្មការសង្គហៈរបស់យើងអនុវត្តបានសម្រេចនៅក្នុងឆ្នាំ ២០១៥ នេះ?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

៦. ខ្ញុំជាឧបករណ៍របស់ព្រះជាម្ចាស់ដើម្បីការងារមេត្តាករុណា៖

\+ អត្តទស្សនៈរបស់ខ្ញុំ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

\+ សេចក្ដីស្រឡាញ់ដោយយកចិត្តទុកដាក់របស់ខ្ញុំ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

+ ការអនុវត្តន៍យ៉ាងសកម្មរបស់ខ្ញុំ ?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................






# " យើងសម្តែង មេត្តាករុណា "

## "CHARITY IN ACTION"